សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Science Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការទាមទារសំណងការខូចខាតក្នុងរឿងក្តីព្រហ្មទណ្ឌ

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ក.សុន រចនា**

សាស្ត្រាចារ្យណែនាំ
លោក **រុន ពណ្ណារិទ្ធ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២០

ឆ្នាំចូលសិក្សា ២០១៦
ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំ **សុន រចនា** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី ២០ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា២០១៦-២០២០ បានសរសេរសារណា ដើម្បីបញ្ចប់ការសិក្សាក្រោមប្រធានបទស្តីពី "**ការទាមទារសំណងការខូចខាតក្នុងរឿងក្តីព្រហ្មទណ្ឌ**"។

**សូមលំឱនកាយគោរពដឹងគុណយ៉ាងជ្រាលជ្រៅពិសេសចំពោះ**

លោកឪពុក **ថាន់ សុខខេម** និងអ្នកម្តាយ **ឆេង ឡាត់** ដោយលោកអ្នកមានគុណទាំងពីរបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា អប់រំ ទូន្មាន ប្រៀនប្រដៅ ណែនាំ ផ្តល់ដំបូន្មាន និងទម្រុកបម្រុងដល់រូបកូនគ្រប់បែបយ៉ាង ទាំងកម្លាំងកាយ ទាំងកម្លាំងចិត្ត ទាំងផ្នែកស្មារតី និងផ្នែកសម្ភារៈ តាំងពីកូនចាប់កំណើតមកដល់កូនធំពេញវ័យ ដើម្បីឱ្យកូនបានសិក្សារៀនសូត្ររហូតបានបញ្ចប់បរិញ្ញាបត្រនេះ។ គុណូបការៈយ៉ាងធំអរណេកនេះ រូបកូននឹងចងចាំជានិច្ច ហើយគ្មានថ្ងៃបំភ្លេចឡើយ។

ឯកឧត្តម **លុយ ចណ្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ព្រមទាំងគណៈគ្រប់គ្រង សាស្ត្រចារ្យទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានជួយជម្រុញ ផ្តល់ការលើកទឹកចិត្ត ជាពិសេសគឺការផ្តល់នូវចំណេះដឹង បទពិសោធន៍ល្អៗយ៉ាងច្រើនក្នុងរយៈពេល ៤(បួន)ឆ្នាំកន្លងមកនេះ ដែលបានធ្វើឱ្យនាងខ្ញុំក្លាយជានិស្សិតល្អ មិត្តល្អ និងជាពលរដ្ឋល្អនៅក្នុងសង្គមជាតិ ព្រមទាំងអាចធ្វើឱ្យចំណេះដឹងដែលនាងខ្ញុំទទួលបានពីសាកលវិទ្យាភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចនេះ យកទៅបម្រើសង្គមជាតិផងដែរ។

សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរចំពោះ លោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** ព្រមទាំងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការដឹកនាំសារណាមួយនេះ ដោយលោកទាំងពីរបានផ្តល់នូវដំបូន្មាន និងចំណេះដឹងបន្ថែមប្រកបដោយបទពិសោធន៍ ព្រមទាំងផ្តល់ការកែសម្រួលលើប្រធានបទមួយនេះ យ៉ាងអស់ពីកម្លាំងកាយកម្លាំងចិត្ត ប្រាជ្ញាស្មារតី ក្នុងគោលបំណងដើម្បីឱ្យសារណាបញ្ចប់ការសិក្សាមួយនេះ ប្រកបដោយភាពជោគជ័យ និងល្អឥតខ្ចោះ សម្រាប់ជាប្រយោជន៍ដល់អ្នកអាន និងអ្នកសិក្សាជំនាន់ក្រោយបានស្វែងយល់ផងដែរ។

ជាចុងក្រោយនាងខ្ញុំសូមគោរពជូនពរដល់លោកអ្នកមានគុណទាំងពីរ ឯកឧត្តម លោក-លោកស្រីសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូទាំងអស់ឱ្យជួបនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ជាការពិតណាស់ នៅក្នុងសង្គមមួយតែងជៀសមិនផុតពីការកើតឡើងនូវបទល្មើស ដែលនាំឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គម និងសិទ្ធិសេរីរបស់បុគ្គលឯកជនផងដែរ។ ក៏មិនខុសប្លែកពីប្រទេសកម្ពុជាដែរ នៅពេលដែលមានបទល្មើសកើតឡើង មន្ត្រីអនុវត្តច្បាប់ដែលមានសមត្ថកិច្ចក្នុងការដោះស្រាយតែងតែ ធ្វើការដោះស្រាយនូវបទល្មើសនោះដោយគោរពទៅតាមវិធាននៃក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមព្រហ្មទណ្ឌ ក្នុងគោលបំណងជួសជុលសណ្តាប់ធ្នាប់សង្គម និងផ្តន្ទាទោសបុគ្គលដែលរំលោភបំពានច្បាប់នោះ តាមច្បាប់កំណត់។ ប៉ុន្តែពេលខ្លះបទល្មើសមួយកើតឡើងមិនត្រឹមតែធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គមប៉ុណ្ណោះទេ តែក៏បណ្តាលឱ្យមានព្យសនកម្មដល់ជនរងគ្រោះផងដែរ ដូចនេះហើយទើបក្រមនីតិវិធីព្រហ្មទណ្ឌបើកឱ្យមានបណ្តឹងរដ្ឋប្បវេណីនេះឡើងមក ក្នុងគោលបំណងសម្រាប់ឱ្យជនរងគ្រោះមានទទួលនូវសំណងនៃការខូចខាត ដែលបណ្តាលមកពីអំពើល្មើស។ ទោះបីជាក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់សិទ្ធិឱ្យជនរងគ្រោះក្នុងទាមទារនូវការជួសជុលព្យសនកម្មដែលបណ្តាលមកពីបទល្មើសពិតមែន ប៉ុន្តែការទទួលបាននូវសំណងការខូចខាតនោះ មិនមែនសុទ្ធតែទទួលបានការទាមទាររហូតនោះទេ។ ដោយមានបុព្វហេតុទាំងនេះហើយ ទើបធ្វើឱ្យនាងខ្ញុំសម្រេចចិត្តជ្រើសរើសនូវប្រធានបទផ្នែកព្រហ្មទណ្ឌមួយក្រោមចំណងជើងថា "**ការទាមទារសំណងការខូចខាតក្នុងរឿងក្តីព្រហ្មទណ្ឌ**" មករៀបរៀងជាសារណាបញ្ចប់ការសិក្សា បន្ទាប់ពីបានឆ្លងកាត់ការសិក្សារយៈពេល ៤(បួន) ឆ្នាំ កន្លងមកទៅលើមុខជំនាញនីតិសាស្ត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

នាងខ្ញុំសង្ឃឹមថា សារណាបញ្ចប់ការសិក្សាមួយនេះ នឹងក្លាយជាឯកសារដ៏មានតម្លៃអាចឱ្យនាងខ្ញុំយកមកប្រើប្រាស់សម្រាប់ជាប្រយោជន៍ខ្លួនឯងផ្ទាល់ និងសង្គមជាតិ ព្រមទាំងអាចក្លាយជាផ្នែកមួយដែលជួយដល់ស្មារតីក្នុងការស្រាវជ្រាវរបស់សិស្ស និស្សិតជំនាន់ក្រោយ ក្នុងការស្វែងយល់បន្ថែមអំពីការទទួលបានសំណងការខូចខាតក្នុងរឿងក្តីព្រហ្មទណ្ឌនេះ។

ជាចុងក្រោយនាងខ្ញុំដឹងថា សារណាមួយនេះនឹងមិនមានភាពល្អឥតខ្ចោះនោះទេ ប្រាកដជាមានកន្លែងខុសឆ្គង ខ្វះខាត ត្រង់អត្ថន័យ ពាក្យពេចន៍ និងអក្ខរាវិរុទ្ធត្រង់កន្លែងណាមួយជាក់ជាមិនខាន នាងខ្ញុំរីករាយ និងស្វាគមន៍ជានិច្ច នូវមតិរិះគន់ ព្រមទាំងការកែសម្រួលផ្សេងៗពីសំណាក់លោក លោកស្រីសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និងមិត្តអ្នកអានគ្រប់រូប ដោយមេត្រីភាព ដើម្បីកែលម្អសារណាមួយនេះឱ្យកាន់តែមានភាពល្អប្រសើរបន្ថែមទៀម។

# មាតិកា


ទំព័រ

សេចក្តីផ្តើម ....................................................................................................១

## ជំពូកទី១

## លក្ខខណ្ឌនៃសំណងនៃការខូចខាត

ផ្នែកទី១៖ បុគ្គលដែលមានសិទ្ធិទាមទារសំណងនៃការខូចខាត ....................................៣

១. ជនរងគ្រោះ....................................................................................................៣

២.សិទ្ធិវន្តរបស់ជនរងគ្រោះ ...................................................................................៤

៣.នីតិបុគ្គលដែលច្បាប់បានកំណត់ ...........................................................................៤

ផ្នែកទី២៖ កំហុស ...............................................................................................៥

១.កំហុសចេតនា..................................................................................................៦

២.កំហុសអចេតនា................................................................................................៦

ផ្នែកទី៣៖ ព្យសនកម្មដែលបង្កឡើងដោយបទល្មើស ..................................................៧

១. ព្យសនកម្មខាងសម្ភារៈ ....................................................................................៨

២. ព្យសនកម្មខាងរូបកាយ ....................................................................................៩

៣. ព្យសនកម្មផ្លូវចិត្ត .........................................................................................១០

## ជំពូកទី២

## នីតិវិធីអនុវត្តចំពោះបណ្តឹងទាមទារឱ្យសងសំណងនៃការខូចខាត

ផ្នែកទី១៖ បណ្តឹងសុំទាមទារសំណងការខូចខាត....................................................១៣

១.ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី.....................................................................១៣

១.១ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅដំណាក់កាលស៊ើបអង្កេត .............១៣

១.២ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមផ្លូវអន្តរាគមន៍.............................១៣

១.៣ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមផ្លូវបណ្តឹង ...................................១៤

ក. ការសម្រេចអំពីការបើកការស៊ើបសួរ ....................................................១៥

ខ. ប្រាក់តម្កល់ធានារឿងក្តី...........................................................................១៥

ខ.១ ការសម្រេចអំពីពិន័យរដ្ឋប្បវេណី...............................................................១៦

ខ.២ បណ្តឹងទាមទារឱ្យជួសជុលការខូចខាត .......................................................១៦

គ. បណ្ដឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ............................... ១៦
១.៤ ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងពេលសវនាការ ..................... ១៨
២.ចុងចម្លើយនៃបណ្ដឹងរដ្ឋប្បវេណី........................................................................ ១៩
ផ្នែកទី២៖ ការសម្រេចសេចក្ដីលើសំណងនៃការខូចខាត.........................................២១
១. ការសម្រេចសេចក្ដីអំពីពិរុទ្ធភាព.....................................................................២១
២. ជម្រើសនៃការតវ៉ាលើសេចក្ដីសម្រេចអំពីប្រយោជន៍ផ្នែករដ្ឋប្បវេណី ................២២
២.១.បណ្ដឹងទាស់ចំពោះសាលក្រមផ្នែករដ្ឋប្បវេណី.............................................២២
២.២ បណ្ដឹងឧទ្ធរណ៍ចំពោះសេចក្ដីសម្រេចផ្នែករដ្ឋប្បវេណី ..................................២៣
២.៣ បណ្ដឹងទាស់ចំពោះសាលដីកាផ្នែករដ្ឋប្បវេណី..............................................២៥
២.៤ បណ្ដឹងសាទុក្ខទៅតុលាការកំពូល ....................................................................២៦

## ជំពូកទី៣

## ការអនុវត្តសេចក្ដីសម្រេចអំពីសំណងនៃការខូចខាតក្នុងរឿងក្ដីព្រហ្មទណ្ឌ

ផ្នែកទី១៖ ការអនុវត្តសេចក្ដីសម្រេចតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណី...២៨
១.នីតិវិធីនៃការលក់ដោយបង្ខំលើអចលនវត្ថុ.......................................................២៨
ក.ពាក្យសុំអនុវត្តរបស់ម្ចាស់បំណុល(ដើមបណ្ដឹងរដ្ឋប្បវេណី) ........................២៩
ខ.ដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំ ..............................................................២៩
គ.អានុភាពនៃការរឹបអូស.......................................................................................២៩
ឃ.ដីកាសម្រេចកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក .៣០
២.ការចាប់ផ្ដើមអនុវត្តដោយបង្ខំចំពោះចលនវត្ថុ.................................................៣១
ក.វិធីរឹបអូស .............................................................................................................៣១
ខ.ការថែរក្សាគ្រប់គ្រងទ្រព្យសម្បត្តិដែលបានរឹបអូស.........................................៣២
គ.អានុភាពនៃការរឹបអូស.......................................................................................៣២
ឃ.ការអនុវត្តការលក់ដោយបង្ខំ ............................................................................ ៣៣
ផ្នែកទី២៖ ការបង្ខំដល់រូបកាយ ...............................................................................៣៤
១. នីតិវិធីអនុវត្តលើទណ្ឌិតដោយការបង្ខំដល់រូបកាយ.........................................៣៥
១.១ ការអនុវត្តការសងដោយស្ម័គ្រចិត្ត......................................................................៣៥
១.២ ការអនុវត្តការបង្ខំដល់រូបកាយ ...........................................................................៣៦

ក.ថិរវេលានៃការបង្ខំដល់រូបកាយ.....................................................................៣៧

ខ.ភាពមិនអាចរួចផុតពីបំណុល ......................................................................៣៨

២. ការរួចផុតពីការបង្ខំដល់រូបកាយ.................................................................................៣៨

២.១ ស្ថានភាពបុគ្គលដែលមិនអាចធ្វើការបង្ខំដល់រូបកាយ .......................................៣៨

២.២ ការដោះលែងឱ្យមានសេរីភាពវិញ..............................................................៣៨

**សេចក្ដីសន្និដ្ឋាន** ........................................................................................ ៤០

**អនុសាសន៍** ................................................................................................ ៤១

**ឯកសារពិគ្រោះ**

**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

ការកើតឡើងនូវបទល្មើសព្រហ្មទណ្ឌមួយតែងនាំឱ្យមានការខូចខាតដល់សណ្ដាប់ធ្នាប់សង្គម ពេលខ្លះអាចបង្កជាព្យសនកម្មដល់រូបរាងកាយ ព្យសនកម្មផ្លូវចិត្ត និងព្យសនកម្មផ្នែកសម្ភារៈលើជនរងគ្រោះថែមទៀតផង ជាហេតុតម្រូវឱ្យមានការទទួលខុសត្រូវចំពោះបទល្មើសនោះ ដូចជាការផ្ដន្ទាទោសតាមច្បាប់ និងការសងសំណងនៃការខូចខាតជាដើម។ នៅក្នុងរឿងក្ដីព្រហ្មទណ្ឌ បណ្ដឹងដែលកើតមានឡើងមាន២ប្រភេទ ដូចបានកំណត់យ៉ាងជាក់លាក់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ គឺ*បណ្ដឹងអាជ្ញា* និង*បណ្ដឹងរដ្ឋប្បវេណី*។ បណ្ដឹងអាជ្ញា គឺជាបណ្ដឹងដែលមានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឱ្យឃើញពិរុទ្ធភាពនៃជនល្មើស និងផ្ដន្ទាទោសជននោះតាមច្បាប់។ ចំណែកបណ្ដឹងរដ្ឋប្បវេណីវិញ គឺជាបណ្ដឹងដែលមានគោលបំណងធ្វើឱ្យបានជួសជុលការខូចខាត ដែលបណ្ដាលមកពីអំពើល្មើសដល់ជនរងគ្រោះ ហើយក្នុងគោលបំណង ឱ្យអ្នករងគ្រោះបានទទួលសំណងជម្ងឺចិត្តជូនល្មមនឹងព្យសនកម្មដែលខ្លួនបានទទួល។ ដោយហេតុថារឿងក្ដីព្រហ្មទណ្ឌអាចបង្កឱ្យមានព្យសនកម្មដែលបណ្ដាលមកពីបទល្មើសចំពោះជនរងគ្រោះ ដូចនេះទើបក្រមនីតិវិធីព្រហ្មទណ្ឌបានអនុញ្ញាតបើកសិទ្ធិឱ្យបុគ្គលដែលរងគ្រោះពីបទល្មើសធ្វើការទាមទារនូវសំណងនៃការខូចខាតក្នុងរឿងក្ដីព្រហ្មទណ្ឌបានតាមរយៈការធ្វើបណ្ដឹងរដ្ឋប្បវេណី។ ដើម្បីឱ្យការបកស្រាយនូវប្រធានបទនេះកាន់តែមានភាពច្បាស់លាស់ជាដំបូងនាងខ្ញុំសូមធ្វើការពន្យល់នូវពាក្យគន្លឹះមួយគឺ *សំណងនៃការខូចខាត*។ ដោយអនុលោមតាមវចនានុក្រមខ្មែររបស់សម្ដេចព្រះសង្ឃរាជ ជួន ណាត ពាក្យថា *សំណង* មានន័យថា ប្រាក់ ឬរបស់ដែលសង ឬដែលគេសង ឬសងគេ។ ចំណែកឯពាក្យថា *ខូច* វិញមានន័យថា វិនាស អន្តរាយ។ ចំពោះពាក្យថា *ខាត* គឺ ថយពីពីចំនួនដើម មិនពេញ មិនចំណេញ។ តាមអត្ថន័យបញ្ចូលគ្នានៃពាក្យទាំងនេះ *សំណងនៃការខូចខាត* សំដៅទៅលើប្រាក់ ឬរបស់ទាំងឡាយណាដែលត្រូវសងទៅគេវិញ ដោយសារសេចក្ដីវិនាស ឬមិនបានចំណេញ។

ជាការពិតណាស់ ជនរងគ្រោះអាចទទួលបាននូវសំណងនៃការខូចខាតបាន ទោះបីជាព្យសនកម្មនោះបណ្ដាលមកពីអំពើល្មើសក្នុងរឿងក្ដីព្រហ្មទណ្ឌក៏ដោយ ប៉ុន្តែតើត្រូវមានលក្ខខណ្ឌអ្វីខ្លះ ដើម្បីមានសិទ្ធិក្នុងការទាមទារនូវសំណងនៃការខូចខាតនោះ? ក្នុងករណីការគណនានូវចំនួនសំណងនៃការខូចខាតផ្អែកលើមូលដ្ឋាននៃការទទួលខុសត្រូវក្រៅកិច្ចសន្យា និងអំពើអនីត្យានុកូលនោះ តើតុលាការព្រហ្មទណ្ឌមានសមត្ថកិច្ចក្នុងការទទួលពាក្យបណ្ដឹង និងដោះស្រាយលើបណ្ដឹងសុំទាមទារសំណងនៃការខូចខាតក្នុងរឿងព្រហ្មទណ្ឌដែលឬទេ? ហើយបើសិនជាទណ្ឌិតមិនព្រមសងសំណងនៃការខូចខាតដល់ជនរងគ្រោះតាមសេចក្ដីសម្រេចទេនោះ តើមានវិធានការបែបណាសម្រាប់ដោះស្រាយលើបញ្ហានេះ?

ការស្រាវជ្រាវអំពីប្រធានបទ "ការទាមទារសំណងនៃការខូចខាតក្នុងរឿងក្តីព្រហ្មទណ្ឌ" នេះ មានគោលបំណងដើម្បីសិក្សា និងកំណត់ឱ្យច្បាស់លាស់នូវកម្រិតនៃការទាមទារនូវសំណងនៃការខូចខាត រួមទាំងនីតិវិធីនៃការដំណើរការលើបណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តីព្រហ្មទណ្ឌ ចាប់តាំងពីការដាក់ពាក្យបណ្តឹងសុំទាមទារសំណងនៃការខូចខាត រហូតដល់ការអនុវត្តសេចក្តីសម្រេចផងដែរ។ តាមរយៈការសិក្សាស្រាវជ្រាវលើសារណាមួយនេះ ខ្លឹមសារដែលត្រូវបានរំលេចឡើងក្នុងសារណានេះ នឹងអាចធ្វើឱ្យអ្នកអនុវត្ត ក៏ដូចជាអ្នកសិស្ស និស្សិតដែលចាប់អារម្មណ៍ និងបានសិក្សាលើវិស័យច្បាប់អាចយល់ឱ្យកាន់តែច្បាស់ពី ការទាមទារសំណងនៃការខូចខាតក្នុងរឿងក្តីព្រហ្មទណ្ឌនេះ។ ខ្លឹមសារនៃសារណានេះ នាងខ្ញុំនឹងបង្ហាញត្រឹមកម្រិតនៃការទាមទារនូវសំណងនៃការខូចខាតដោយដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ ចំពោះកិច្ចផ្សេងៗដែលទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងនៃកិច្ចដំណើរការរឿងក្តីព្រហ្មទណ្ឌនាងខ្ញុំសូមមិនធ្វើការបកស្រាយឡើយ។ ដោយសារការទាមទារសំណងនៃការខូចខាតក្នុងរឿងក្តីព្រហ្មទណ្ឌ ត្រូវធ្វើឡើងតាមរយៈការដាក់បណ្តឹងរដ្ឋប្បវេណី ដែលជាបណ្តឹងធ្វើឡើងដោយបុគ្គលឯកជន ដូច្នេះមូលដ្ឋាននៃការវិនិច្ឆ័យលើសំណងនៃការខូចខាតនេះ គឺត្រូវអនុវត្តតាមបទដ្ឋានគតិយុត្តិដែលកំណត់អំពីទំនាក់ទំនងបុគ្គលឯកជន ពោលគឺក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ គន្ថីទី៥ ជំពូកទី១៦ "អំពើអនីត្យនុកូល"។

ដើម្បីការពារជនរងគ្រោះ និងការទទួលបាននូវសំណងធួនល្មមជាមួយព្យសនកម្មដែលបានកើតឡើង ដូច្នេះហើយ ជាបឋមចំពោះការសិក្សាពីខ្លឹមសារ និងការឆ្លុះបញ្ចាំងពីប្រធានបទមួយនេះ ក៏ដូចជាការឆ្លើយតបនូវចំណោទបញ្ហាខាងលើ នាងខ្ញុំសូមបង្ហាញពីរចនាសម្ព័ន្ធនៃសារណានេះ ដែលត្រូវបានបែកចែកជា ៣(បី) ជំពូកធំគឺៈ

**ជំពូកទី១ៈ លក្ខខណ្ឌនៃសំណងនៃការខូចខាត**

**ផ្នែកទី១ៈ បុគ្គលដែលមានសិទ្ធិទាមទារសំណងនៃការខូចខាត**

**ផ្នែកទី២ៈ កំហុស**

**ផ្នែកទី៣ៈ ព្យសនកម្មដែលបង្កឡើងដោយបទល្មើស**

**ជំពូកទី២ៈ នីតិវិធីអនុវត្តចំពោះបណ្តឹងទាមទារឱ្យសងសំណងនៃការខូចខាត**

**ផ្នែកទី១ៈ បណ្តឹងសុំទាមទារសំណងការខូចខាត**

**ផ្នែកទី២ៈ ការសម្រេចសេចក្តីលើសំណងនៃការខូចខាត**

**ជំពូកទី៣ៈ ការអនុវត្តសេចក្តីសម្រេចអំពីសំណងនៃការខូចខាតក្នុងរឿងក្តីព្រហ្មទណ្ឌ**

**ផ្នែកទី១ៈ ការអនុវត្តសេចក្តីសម្រេចតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណី**

**ផ្នែកទី២ៈ ការបង្ខំដល់រូបកាយ**

# ជំពូកទី១
# លក្ខខណ្ឌនៃសំណងនៃការខូចខាត

# ជំពូកទី១
# លក្ខខណ្ឌនៃសំណងនៃការខូចខាត

ទណ្ឌកម្មផ្នែករដ្ឋប្បវេណីនៅក្នុងរឿងក្តីព្រហ្មទណ្ឌ គឺជាសំណងនៃការខូចខាត ដែលមានគោលដៅធ្វើយ៉ាងណាឱ្យអ្នកដែលបានប្រព្រឹត្តបទល្មើស ទទួលខុសត្រូវសងការខូចខាតដល់ជនរងគ្រោះ ដោយការជួលជុលនូវការខូចខាត ទោះបីជាការជួសជុលលើព្យសនកម្មនោះជាប្រាក់ក្តី មិនមែនជាប្រាក់ក្តី។ មិនត្រឹមតែប៉ុណ្ណោះសំណងនៃការខូចខាតគឺ មានគោលបំណងធ្វើយ៉ាងណាឱ្យជនរងគ្រោះមានភាពស្ងប់ចិត្ត ក្រោយពីចារីបានប្រព្រឹត្តបទល្មើសដែលនាំឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈផង និងប្រយោជន៍ឯកជនផងដែរ។ ជនរងគ្រោះអាចទទួលបានការជួសជុលនូវព្យសនកម្មបានលុះត្រាតែ ព្យសនកម្មនោះ ជាផលវិបាកផលនៃបទល្មើសហើយជាព្យសនកម្មផ្ទាល់ ជាពិសេសព្យសនកម្មនោះបានកើតឡើងនៅក្នុងពេលបច្ចុប្បន្នតែប៉ុណ្ណោះ ។ ព្យសនកម្មដែលត្រូវជួសជុលនោះ អាចជាព្យសនកម្មខាងផ្លូវចិត្ត ព្យសនខាងកម្មផ្លូវកាយ ឬជាព្យសនកម្មខាងសម្ភារៈ។[1] ទោះបីជាសំណងនៃការខូចខាតត្រូវបានកើតឡើងនៅពេលដែលព្យសនកម្មកើតឡើងទៅលើសិទ្ធិរបស់បុគ្គលឯកជនដែលជាប្រធាននៃទំនាក់ទំនងរដ្ឋប្បវេណីក៏ដោយ ប៉ុន្តែដោយហេតុថា ព្យសនកម្មនេះកើតឡើងពីបទល្មើសព្រហ្មទណ្ឌ ដូចនេះហើយលក្ខខណ្ឌនៃការទាមទារសំណងនៃការខូចខាតក៏ត្រូវផ្អែកលើមូលដ្ឋានច្បាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌផងដែរ។

## ផ្នែកទី១៖ បុគ្គលដែលមានសិទ្ធិទាមទារសំណងនៃការខូចខាត

ការទាមទារនូវសំណងនៃការខូចខាតក្នុងរឿងក្តីព្រហ្មទណ្ឌត្រូវធ្វើឡើងតាមរយៈការដាក់បណ្តឹងរដ្ឋប្បវេណី។ តើបុគ្គលណាខ្លះដែលមានសិទ្ធិក្នុងការទាមទារសំណងនៃការខូចខាត?

### ១. ជនរងគ្រោះ

បណ្តឹងរដ្ឋប្បវេណី ត្រូវអនុវត្តដោយជនរងគ្រោះនៃបទល្មើស[2] ដែលច្បាប់ឱ្យឈ្មោះថា ជាដើមបណ្តឹងរដ្ឋប្បវេណី។ ប៉ុន្តែមិនមែនគ្រប់ជនរងគ្រោះទាំងអស់សុទ្ធតែអាចធ្វើបណ្តឹងទាមទារសំណងនៃការខូចខាតបាននោះទេព្រោះថាជនរងគ្រោះមួយចំនួនអាចជាអនីតិជនដែលមានអាយុក្រោម ១៨(ដប់ប្រាំបី)ឆ្នាំ ឬជនដែលស្ថិតនៅក្រោមរបបច្បាប់ការពារ ដែលជនទាំងនេះត្រូវបានកម្រិតនៅសមត្ថភាពក្នុងការធ្វើបណ្តឹង ពោលគឺមិនអាចធ្វើបណ្តឹងទាមទារសំណងនៃការខូចខាតបាននោះទេ ដូចនេះហើយដើម្បីជៀសវាងការមិនទទួលបានការជួសជុលព្យសនកម្មពីចារី ក្រមនីតិវិធីព្រហ្មទណ្ឌបានអនុញ្ញាតឱ្យអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះធ្វើបណ្តឹងរដ្ឋប្បវេណីដើម្បីទាមទារសំណងនៃការខូចខាតជំនួសជនរងគ្រោះបាន។[3]

---

[1] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា១៣

[2] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា១៣ កថាខណ្ឌទី១

[3] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា១៤

## ២.សិទ្ធិវន្តរបស់ជនរងគ្រោះ

ជាគោលការណ៍បណ្តឹងរដ្ឋប្បវេណីត្រូវអនុវត្តដោយជនរងគ្រោះ ប៉ុន្តែក្នុងករណីមរណភាពនៃជនរងគ្រោះ បណ្តឹងរដ្ឋប្បវេណីអាចត្រូវបានផ្តើមធ្វើ ឬ បន្តបានដោយសិទ្ធិវន្ត[4]។ សិទ្ធិវន្ត មានន័យថា ជាបុគ្គលដែលមានសិទ្ធិបន្តពីជនរងគ្រោះ ។ ប្រសិនបើសិទ្ធិវន្ត មិនអាចបង្ហាញថា ជនរងគ្រោះបានដាក់ពាក្យបណ្តឹងរដ្ឋប្បវេណី មុនពេលទទួលមរណភាព សិទ្ធិវន្តរូបនោះអាចដាក់ពាក្យបណ្តឹងក្នុងនាមខ្លួនឯង ដើម្បីទាមទារសំណងនៃខូចខាតផ្ទាល់ខ្លួន ដោយសារមរណភាពនៃជនរងគ្រោះនេះបាន ដរាបណាមរណភាពរបស់ជនរងគ្រោះជាប់ទាក់ទងផ្ទាល់នឹងបទល្មើស ដែលជនត្រូវចោទត្រូវបានចោទប្រកាន់ និងក្នុងករណីដែលជនរងគ្រោះបានធ្វើបណ្តឹងរដ្ឋប្បវេណីដើម្បីទាមទារសំណងនៃការខូចខាតមុនពេលទទួលមរណភាព បណ្តឹងរដ្ឋប្បវេណីនោះអាចផ្ទេរទៅឱ្យសិទ្ធិវន្តរបស់មរណជននោះបាន។

## ៣.នីតិបុគ្គលដែលច្បាប់បានកំណត់

ដោយសង្កេតឃើញថានៅពេលដែលមានបទល្មើសមួយកើតឡើងដែលប៉ះពាល់ដល់សិទ្ធិសេរីភាព និងផលប្រយោជន៍ឯកជន ជនរងគ្រោះភាគច្រើនតែងតែផ្តល់សិទ្ធិក្នុងការទាមទាររបស់ខ្លួនទៅឱ្យសមាគមមួយចំនួន ដោយសារជនរងគ្រោះមិនមានលទ្ធភាព គ្រប់គ្រាន់ក្នុងការធ្វើនីតិវិធី ឬដោយសារតែការខ្វះខាតនូវចំណេះដឹង មិនមានលទ្ធភាពក្នុងការយល់ដឹងពីផ្លូវច្បាប់ ឬដោយកត្តាផ្សេងៗទៀត ដើម្បីឱ្យសមាគមនោះជួយស្វែងរកយុត្តិធម៌ និងទាមទារនូវសំណងនៃការខូចខាតជំនួសខ្លួនដែលជាជនរងគ្រោះ។ ដោយឈរលើបញ្ហានេះហើយទើប ក្រមនីតិវិធីព្រហ្មទណ្ឌបានអនុញ្ញាតឱ្យជនរងគ្រោះអំពីអំពើល្មើសអាចប្រគល់សិទ្ធិក្នុងការទាមទាររបស់ខ្លួនដល់នីតិបុគ្គលដែលគាំពារលើជនរងគ្រោះនោះ ដើម្បីធ្វើការទាមទារសំណងនៃការខូចខាតជំនួសជនរងគ្រោះ។ នីតិបុគ្គលទាំងនោះមានដូចជា៖

- សមាគមប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាខាងផ្លូវភេទ អំពើហិង្សាក្នុងគ្រួសារ ឬអំពើហិង្សាប្រឆាំងនឹងកុមារ

គ្រប់សមាគមដែលបានប្រកាសដោយត្រឹមត្រូវ យ៉ាងតិចបំផុតតាំងពី៣(បី)ឆ្នាំ មុនកាលបរិច្ឆេទនៃបទល្មើស ហើយដែលកម្មវត្ថុនៃលក្ខន្តិកៈរបស់ខ្លួន រួមមានការតស៊ូប្រឆាំងនឹងអំពើហិង្សាខាងផ្លូវភេទ អំពើហិង្សាក្នុងគ្រួសារ ឬអំពើហិង្សាប្រឆាំងនឹងកុមារ នោះអាចប្រើប្រាស់សិទ្ធិដែលទទួលស្គាល់ដល់ដើមបណ្តឹងរដ្ឋប្បវេណីចំពោះប្រភេទបទល្មើដូចតទៅៈ

- ការបៀតបៀនដោយចេតនាដល់អាយុជីវិត
- ការបៀតបៀនដល់បូរណភាពនៃបុគ្គល

[4] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា១៦

- ការបៀតបៀនខាងផ្លូវភេទ[5]

➢ សមាគមប្រយុទ្ធប្រឆាំងនឹងការចាប់ពង្រាត់ ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ

គ្រប់សមាគមដែលបានប្រកាសដោយត្រឹមត្រូវ យ៉ាងតិចបំផុតតាំងពី៣(បី)ឆ្នាំ មុនកាលបរិច្ឆេទនៃបទល្មើស ហើយដែលកម្មវត្ថុនៃលក្ខន្តិកៈ រួមមានការតស៊ូប្រឆាំងនឹងការចាប់ពង្រាត់ ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ អាចប្រើប្រាស់សិទ្ធិដែលទទួលស្គាល់ដល់ដើមបណ្ដឹងរដ្ឋប្បវេណី ចំពោះបទល្មើសដែលបានបញ្ញត្តិដោយច្បាប់ ដែលពាក់ព័ន្ធនឹងការប្រឆាំងការចាប់ពង្រាត់ ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ។[6]

➢ សមាគមប្រយុទ្ធប្រឆាំងនឹងការប្រកាន់ពូជសាសន៍ និងការរើសអើង

គ្រប់សមាគមដែលបានប្រកាសដោយត្រឹមត្រូវ យ៉ាងតិចបំផុតតាំងពី៣(បី)ឆ្នាំ មុនកាលបរិច្ឆេទនៃបទល្មើស ហើយដែលកម្មវត្ថុនៃលក្ខន្តិកៈ រួមមានការតស៊ូប្រឆាំងនឹងការប្រកាន់ពូជសាសន៍ និងការឧបត្ថម្ភដល់ជនរងគ្រោះនៃការរើសអើងស្ដីពីដើមកំណើតជាតិ ជាតិពន្ធុ ពូជសាសន៍សាសនា អាចប្រើប្រាស់សិទ្ធិដែលទទួលស្គាល់ដល់ដើមបណ្ដឹងរដ្ឋប្បវេណី ចំពោះបទល្មើសដូចបានកំណត់ខាងក្រោម កាលណាបទល្មើសនោះ ត្រូវបានប្រព្រឹត្តដោយមូលហេតុដើមកំណើតជាតិនៃបុគ្គលណាម្នាក់ ឬ ដោយមូលហេតុថា បុគ្គលនោះជាសមាជិកពិតប្រាកដ ឬដោយស្មាននៃជាតិពន្ធុ ពូជសាសន៍ ឬ សាសនាណាមួយជាកំណត់ៈ

- ការរើសអើង
- ការបៀតបៀនដោយចេតនា ដល់អាយុជីវិត ឬបូរណភាពបុគ្គល
- ការបំផ្លាញ និងធ្វើឱ្យខូចខាត។[7]

បណ្ដឹងរបស់សមាគមដូចរៀបរាប់ខាងលើនេះ អាចទទួលយកបានលុះត្រាតែមានភស្តុតាងបញ្ជាក់ថា បានទទួលការយល់ព្រមអំពីសិទ្ធិពីជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់នៃជននេះ។ ក្នុងករណីបៀតបៀនដល់អាយុជីវិត បណ្ដឹងរបស់សមាគមអាចទទួលយកបាន លុះត្រាតែសមាគមបានបង្ហាញភស្តុតាងបញ្ជាក់ថា បានទទួលការយល់ព្រមអំពីសិទ្ធិពីសិទ្ធិវន្តនៃជនរងគ្រោះ។[8]

## ផ្នែកទី២ កំហុស

កំហុសគឺជាលក្ខខណ្ឌមួយដែលនាំឱ្យជនរងគ្រោះអាចធ្វើការទាមទារនូវសំណងនៃការខូចខាតបានដោយផ្អែកលើកំហុសរបស់ចារី។ ដោយសាតែការខូចខាតកើតឡើងពីបទល្មើសព្រហ្មទណ្ឌ ដូចនេះហើយកំហុសនៅត្រង់ចំណុចនេះក៏មិនខុសប្លែកគ្នាពីធាតុអត្តនោម័តនៃធាតុផ្សំបទល្មើសព្រហ្មទណ្ឌទេ។ ជាទូទៅ អំពើល្មើសនឹង

[5] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា១៧
[6] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា១៨
[7] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា១៩
[8] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា២០

ច្បាប់ព្រហ្មទណ្ឌទាំងឡាយសុទ្ធតែបណ្តាលមកពីកំហុស។ ជាគោលការណ៍ កំហុសត្រូវកើតចេញពីចេតនារបស់ជនល្មើស ប៉ុន្តែអាចចេញមកពីការភ្លេចភ្លាំង ការមិនប្រុងប្រយ័ត្ន ឬការធ្វេសប្រហែសដូចគ្នាផងដែរ។

ម្យ៉ាងទៀតអាចឱ្យនិយមន័យកំហុសបានថា គឺជាស្ថានភាពផ្លូវចិត្តរបស់ចារីដោយការបានព្យាករទុកជាមុនអំពីការកើតឡើងនូវលទ្ធផល ហើយទទួលយកការកើតឡើងនៃលទ្ធផលនោះ។

យោងតាមមាត្រា៧៤២ នៃក្រមរដ្ឋប្បវេណី កំហុសត្រូវបានបែងចែកជា២គឺ កំហុសចេតនា និងកំហុសអចេតនា៖

## ១.កំហុសចេតនា

កំហុសចេតនា មានន័យថា នៅពេលដែលចារីប្រព្រឹត្តអំពើអ្វីមួយ ជននោះយល់ដឹង ឬអាចព្យាករបានអំពីរបស់ខ្លួននឹងបង្កឱ្យមានលទ្ធផល គឺជាអន្តរាយដល់អ្នកដទៃ ហើយខ្លួនព្រមទទួលយកការកើតឡើងនូវលទ្ធផលនោះ ទោះបីជាគោលការណ៍នៃអំពើមិនប្រាកដថាត្រូវបង្កអន្តរាយក្តី។ មិនតែប៉ុណ្ណោះ ជនប្រព្រឹត្តបានដឹងច្បាស់ថា អំពើនោះជាបទល្មើសដែលនឹងត្រូវផ្តន្ទាទោសតាមច្បាប់ តែទោះជាយ៉ាងនេះក៏ដោយ ជនល្មើសនៅតែចង់ឱ្យអំពើនោះ កើតឡើងទាល់តែបាន មិនគិតពីលទ្ធផលចុងក្រោយនៃអំពើដែលខ្លួនបានប្រព្រឹត្តិនោះទេ ដោយហេតុថា ចង់បានផលប្រយោជន៍ពីអ្នកដទៃ ដូចជា ការប្លន់ លួច ឆក់ ជាដើម។ អំពើទាំងអស់នេះហើយបង្ហាញពីកំហុសចេតនា។

**ឧទាហរណ៍១៖** **ក** មានជម្លោះជាមួយ **ខ**។ ភ្លាមៗនោះ **ក** ក៏បានដកកាំភ្លើងបាញ់ចំដើមទ្រូងរបស់ **ខ** បណ្តាលឱ្យស្លាប់។ តាមឧទាហរណ៍នេះ យើងអាចសង្កេតបានថា **ក** មានការយល់ដឹងអាចព្យាករទុកជាមុនបានថា ការបាញ់ចំកណ្តាលដើមទ្រូងបុគ្គលណាម្នាក់អាចបណ្តាលឱ្យស្លាប់។ នេះបញ្ជាក់ឱ្យឃើញថា អំពើរបស់ **ក** ជាអំពើដែលបង្កឡើងដោយកំហុសចេតនាផងដែរ។ ក្នុងករណីដូចឧទាហរណ៍ខាងលើនេះ សិទ្ធវន្តរបស់ **ខ** អាចធ្វើការទាមទារសំណងនៃការខូចខាតបាន ដោយសារការបង្កនូវព្យសនកម្មផ្លូវចិត្តជាដើម ដែលបណ្តាលមកពីការបាត់បង់នូវសមាជិកគ្រួសារ -ល-។

**ឧទាហរណ៍២៖** យុវជនពីរនាក់ បានជិះម៉ូតូមួយគ្រឿង ទៅឆក់កាបូបនារីម្នាក់ដែលកំពុងជិះម៉ូតូឆ្លងផ្លូវ បណ្តាលឱ្យនារីនោះ ដួលនិងរងរបួស។

## ២.កំហុសអចេតនា

កំហុសអចេតនា មានន័យថា ជាការបំពានលើករណីប្រុងប្រយ័ត្ន យកចិត្តទុកដាក់ដែលច្បាប់បានកំណត់ ពោលគឺអំពើដែលតាមប្រក្រតីបុគ្គលិកដែលមានឋានៈនៃការងារ ឬបទពិសោធន៍ស្មើគ្នានឹងអ្នកធ្វើអំពើនោះ នៅតែពុំបានព្យាករទុកជាមុនអំពីការកើតឡើងនៃលទ្ធផលនោះ ដោយសារការធ្វេសប្រហែស មិនប្រុង

ប្រយត្ន័ ហើយទោះបីជាមានករណីកិច្ចជៀសវាងនូវលទ្ធផលនោះក៏ដោយ ក៏នៅតែប្រព្រឹត្តផ្ទុយនឹងករណីកិច្ចនោះ។

**ឧទាហរណ៍៖** ករណីគ្រោះថ្នាក់ចរាចរណ៍ជាដើម ចារីគ្មានបំណងបង្កឱ្យមានកំហុសនោះទេ ប៉ុន្តែដោយសារការខ្វះខាតភាពប្រុងប្រយត្ន័ ឬធ្វេសប្រហែសក្នុងការបំពេញកាតព្វកិច្ច ឬសកម្មភាពអ្វីមួយ ដែលច្បាប់បានកំណត់ហើយបង្កឱ្យមានព្យសនកម្មដល់ជនរងគ្រោះ ដូច្នេះចារីត្រូវតែទទួលខុសត្រូវចំពោះសំណងនៃការខូចខាតដែលខ្លួនបានបង្កឡើងដល់ជនរងគ្រោះ។

បើគ្មានអំពើបង្កឡើងឱ្យមានការខូចខាតកើតឡើងទេ ក៏កំហុសពុំកើតមានដែរ ដូច្នេះចាត់ទុកជាកំហុសបាន ត្រូវតែមានច្បាប់ទុកជាមុនច្បាស់លាស់អាចបង្ខំឱ្យចារី ទទួលខុសត្រូវចំពោះកំហុសនោះបាន។ ប៉ុន្តែការទទួលខុសត្រូវលើសំណងនៃការខូចខាតដែលបណ្តាលមកពីបទល្មើសនេះ អាចនាំឱ្យមានការទទួលខុសត្រូវចំពោះកំហុសផ្ទាល់ខ្លួនដែលផ្អែកលើកំហុសចេតនា អចេតនារបស់ចារី ឬកាលៈទេសៈខ្លះ ធ្វើឱ្យមានការទទួលខុសត្រូវចំពោះ ព្យសនកម្មដែលកើតឡើងអំពីកំហុសរបស់អ្នកដទៃ ដោយខ្លួនមិនមែនជាអ្នកប្រព្រឹត្តិផ្ទាល់នោះទេ តែខ្លួនមានកំហុសដោយប្រយោល ដោយកំហុសនេះហើយបង្កឱ្យមានការខូចខាតកើតឡើងចំពោះជនរងគ្រោះ (ការទទួលខុសត្រូវចំពោះកំហុសមិនផ្ទាល់)។

### ផ្នែកទី៣៖ ព្យសនកម្មដែលបង្កឡើងដោយបទល្មើស

ជាធម្មតា ព្យសនកម្មកើតឡើងពីកំហុសចេតនា ឬកំហុសអចេតនារបស់ចារី ដែលកំហុសទាំងនោះបានធ្វើឱ្យមានផលប៉ះពាល់ដល់សិទ្ធិ នឹងផលប្រយោជន៍អ្នកដទៃទៀត។ ដើម្បីទទួលបានការជួសជុលនូវសំណងនៃការខូចខាត ព្យសនកម្មត្រូវតែជាលទ្ធផលនៃអំពើរបស់ជនល្មើស ឬជនជាប់ចោទ មានន័យថាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវតែបង្ហាញនូវព្យសនកម្មដែលខ្លួនទទួលបានពីជនល្មើស ឬជនជាប់ចោទដែលស្ថិតនៅក្នុងការស៊ើបអង្កេត។ ចៅក្រមអាចធ្វើការច្រានចោលពាក្យសុំដែលពុំបានបង្ហាញថា ដើមបណ្តឹងរដ្ឋប្បវេណីទទួលរងព្យសនកម្មពីអំពើល្មើសនោះ។

ដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែបង្ហាញផលវិបាកផ្ទាល់នៃបទល្មើស ទើបអាចមានសិទ្ធិក្នុងការទាមទារសំណងបាន។ រីឯចៅក្រមអាចធ្វើការច្រានចោលពាក្យសុំ ដែលពុំបានបង្ហាញនូវព្យសនកម្ម ដោយផ្ទាល់ ប្រសិនបើចៅក្រមរកឃើញថាពាក្យសុំទាំងនោះពុំបានបង្ហាញផលវិបាកដោយផ្ទាល់ពី សកម្មភាពដែលត្រូវបានចោទប្រកាន់លើជនត្រូវចោទ។

មួយវិញទៀតព្យសនកម្មនោះ ត្រូវតែជាព្យសនកម្មដែលកើតឡើង និងនៅក្នុងពេលបច្ចុប្បន្នតែប៉ុណ្ណោះ[9] មានន័យថានៅពេលដែលមានបទល្មើសកើតឡើង ហើយបណ្តាលឱ្យមានការខូចខាតកើតឡើងចំពោះជនរង

[9] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា១៣

គ្រោះ ការខូចខាតនេះត្រូវតែមាននៅពេលដែលអំពើនោះបានកើតឡើងភ្លាម ពោលគឺនៅពេលបច្ចុប្បន្ន។ តែក៏មានព្យសនកម្មមួយចំនួន អាចកើតឡើងនៅពេលអនាគតផងដែរ ហើយព្យសនកម្មនោះ ជាបច្ច័យចេញពីអំពើនោះផ្ទាល់ ហើយព្យសនកម្មប្រភេទនេះត្រូវបានច្បាប់ទទួលស្គាល់ផងដែរ ថាជាព្យសនកម្ម ក្នុងករណីបន្ទុកក្នុងការបង្ហាញភស្តុតាងធ្លាក់ទៅលើជនរងគ្រោះ។

ការខូចខាតដែលបណ្តាលមកពីបទល្មើស អាចបង្កឱ្យមានព្យសនកម្ម ៣(បី)ប្រភេទ៖

**១. ព្យសនកម្មខាងសម្ភារៈ**

នៅពេលដែលចារីបានប្រព្រឹត្តបទល្មើស អំពើរបស់ចារីបណ្តាលឱ្យមានការប៉ះពាល់ដល់ទ្រព្យសម្បត្តិ និងមានការខូចខាតច្រើន ដែលអំពើនោះបង្កឱ្យមានព្យសនកម្មផ្នែកសម្ភារៈដល់ជនរងគ្រោះ។ ករណីនេះជនរងគ្រោះអាចទាមទារសំណងដើម្បីជួសជុសព្យសនកម្ម ដែលខ្លួនបានទទួលដោយសារព្យសនកម្មដែលបានបង្កនោះ។

ព្យសនកម្មខាងសម្ភារៈរួមបញ្ចូលទាំងការបាត់បង់ទ្រព្យសម្បត្តិ ឬចំណូល។ ព្យសនកម្មនេះអាចធ្វើការទាមទារទៅតាមការខូចខាត។ ចំពោះព្យសនកម្មលើសម្ភារៈ គេមិនត្រឹមតែបញ្ចូលព្យសនកម្មដោយផ្ទាល់ប៉ុណ្ណោះទេ តែគេថែមទាំងយល់ឃើញថា ព្យសនកម្មដែលបង្កឱ្យមានការប៉ះពាល់ដល់កេរ្តិ៍ឈ្មោះ ដូចជា កេរ្តិ៍ឈ្មោះរបស់តួសម្តែង និងសិល្បករ ជាដើម។ ការខូចខាតបែបនេះអាចជះឥទ្ធិពលដល់ការប្រកបវិជ្ជាជីវៈរបស់ពួកគេ និងអាចបណ្តាលឱ្យពួកគេបាត់បង់វិជ្ជាជីវៈរបស់គេថែមទៀតផង។[10]

**ឧទាហរណ៍៖** បទល្មើសលួចដោយមានស្ថានទម្ងន់ទោស ដោយសារការកាប់គាស់ទម្លុះទម្លាយ បណ្តាលឱ្យខូចខាតនូវសម្ភារៈគេហដ្ឋានជាច្រើន ព្រមទាំងបាត់បង់នូវសម្ភារៈប្រើប្រាស់ផងដែរ។

ជនរងគ្រោះភាគច្រើនតែងតែធ្វើការទាមទារនូវសំណងនៃការខូចខាត របស់ខ្លួនត្រលប់មកវិញនៅចំពោះមុខតុលាការ ប៉ុន្តែក៏មានជនរងគ្រោះមួយចំនួនមិនទាមទារឱ្យមានសំណងនៃការខូចខាតនោះទេ។

**ឧទាហរណ៍៖** តាមរយៈកំណត់ហេតុស្តាប់ចម្លើយរបស់ឈ្មោះ **គ** ស្តីពីបទល្មើសលួចដោយមានស្ថានទម្ងន់ទោស ដោយសារការកាប់គាស់ទម្លុះទម្លាយ "ក្នុងពេលនេះនាងខ្ញុំសុំទាមទារប្រាក់ដើមចំនួន ២៣០០ ដុល្លា និងមិនទាមទារបន្ថែមទៀតនោះទេ"។ ដើមបណ្តឹងរដ្ឋប្បវេណីគប្បីដាក់ភស្តុតាងជាឯកសារបញ្ជាក់ពីតម្លៃនៃសម្ភារៈដែលបានបាត់បង់ រួមទាំងការខូចខាតផ្សេងទៀតដែលបណ្តាលមកពីបទល្មើសនោះ ហើយការទាមទារនូវសំណងត្រូវមានភាពធនល្មមនឹងព្យសនកម្មដែលមានកើតឡើង។

- **ការគណនាសំណងការខូចខាតផ្នែកសម្ភារៈ**

[10] សាយ បូរី, នីតិរដ្ឋបាលទូទៅ បោះពុម្ពលើកទី៣ ឆ្នាំ២០០៦ ទំព័រ៣៥៧

ក្នុងករណីនេះ ត្រូវធ្វើការពិនិត្យមើលទៅលើភាពខុសគ្នារវាងស្ថានភាពពីរ គឺ ស្ថានភាពនៃទ្រព្យសម្បត្តិ ដែលអាចនឹងមាន ប្រសិនបើគ្មានអំពើល្មើសកើតឡើង ជាមួយនឹងស្ថានភាពដែលមានក្រោយពេលកើតឡើងនូវអំពើល្មើស។ ការពិនិត្យទៅលើស្ថានភាពទាំងពីរនេះ មានគោលបំណងស្វែងរកនូវការខូចខាត ដែលបានកើតឡើងទៅលើជនរងគ្រោះ តែការស្វែងរកនេះត្រូវផ្អែកលើភស្តុតាងជាឯកសារ ដែលអាចឱ្យចៅក្រមជឿជាក់ថា មានការបាត់បង់នូវទ្រព្យសម្បត្តិរបស់ជនរងគ្រោះមែន នោះចៅក្រមអាចធ្វើការវាយតម្លៃចំនួនទឹកប្រាក់ ក្នុងការផ្តល់នូវសំណងការខូចខាតបាន។ សំណងនៃការខូចខាតផ្នែកសម្ភារៈ ត្រូវផ្អែកលើកត្តា ៣(បី)សំខាន់ៗ គឺៈ

**ទី១.ព្យសនកម្មដោយផ្ទាល់ (ទ្រព្យសម្បត្តិ និងក្រៅពីទ្រព្យសម្បត្តិ)ៈ** ដូចជាការបាត់បង់ទ្រព្យសម្បត្តិ ការបែកបាក់ ការរបួស មរណភាព ជាអាទិ៍។

**ទី២.ការចំណាយនានាបន្ទាប់អំពីបទល្មើសបានកើតឡើងៈ** សោហ៊ុយព្យាបាល សោហ៊ុយធ្វើដំណើរទៅមន្ទីពេទ្យ ការចំណាយផ្សេងអំឡុងពេលសម្រាកនៅមន្ទីពេទ្យ សោហ៊ុយបុណ្យសព សោហ៊ុយព្យាបាលនានា ដែលអាចកើតឡើងនាពេលអនាគត ជាអាទិ៍។

**ទី៣.ផលប្រយោជន៍នានាដែលត្រូវទទួលបាន ប្រសិនបើគ្មានការខូចខាតដែលបណ្តាលមកពីបទល្មើសៈ** ក្នុងករណីដែលជនរងគ្រោះមានការងារធ្វើ ប៉ុន្តែមិនអាចធ្វើការបានក្នុងអំឡុងពេលដែលសម្រាកព្យាបាល ឬទទួលមរណភាពជាដើម ការពិចារណាពីចំណូលមូលដ្ឋាន (ចំណូលដែលត្រូវទទួលពីការងារ អំឡុងពេលអវត្តមាន ឬប្រពន្ធ កូន និងប្រសិនបើ ជនរងគ្រោះបានស្លាប់) ជារឿងសំខាន់ណាស់ ដែលចំណូលនេះ ជាចំណូលដែលត្រូវទទួលបានជាមូលដ្ឋានជាប្រចាំថ្ងៃ ឬប្រចាំខែជាអាទិ៍។ ចំពោះពេលវេលា ក៏ជារឿងសំខាន់ដែរ ដែលត្រូវយកមកគិតពិចារណាពីប្រយោជន៍ដែលជនរងគ្រោះត្រូវបានទទួលបាន ដែលពេលវេលានេះ ត្រូវចាត់ទុកថា ជាអំឡុងពេលដែលជនរងគ្រោះអាចធ្វើការបានរហូតដល់ចូលនិវត្តន៍។

## ២. ព្យសនកម្មខាងរូបកាយ

ព្យសនកម្មលើរូបរាងកាយ គឺជាព្យសនកម្មដែលងាយស្រួលយល់ និងអាចប៉ានប្រមាណបាន ដោយអាចដឹងពីទំហំនៃព្យសនកម្មដែលអាចងាយស្រួលក្នុងការជួសជុលព្យសនកម្មដែលបានកើតឡើងនោះប្រសិនបើប្រៀបធៀបជាមួយព្យសនកម្មខាងផ្លូវចិត្ត។

ព្យសនកម្មលើរូបរាងកាយ គឺជាការខូចខាត ឬប៉ះពាល់ដែលធ្វើឱ្យមានរបួសស្នាម បាក់ខូចរាងកាយមនុស្ស ទោះធ្ងន់ ឬស្រាលក៏ដោយ។ ព្យសនកម្មប្រភេទនេះអាចធ្វើការវាយតម្លៃបានតាមរយៈការ ភ្ជាប់ឯកសារថ្លៃចំណាយនានា ឬលិខិតបញ្ជាក់ពីអ្នកជំនាញបាន ដើម្បីអាចទុកឱ្យតុលាការវិនិច្ឆ័យ និងធ្វើការវាយតម្លៃបាន។ ការភ្ជាប់ឯកសារថ្លៃចំណាយនានា ឬលិខិតបញ្ជាក់ពីអ្នកជំនាញជាភស្តុតាងបង្ហាញអំពីព្យសនកម្មខាងរូបកាយ។ ប៉ុន្តែជាការខ្វះខាតការយកចិត្តទុកដាក់មួយរបស់ជនរងគ្រោះដែលជាអនីតិជន ឬជនរងគ្រោះដែលមិនបានយល់

ច្បាស់អំពីការបង្ហាញភស្តុតាង គឺមិនបានដាក់ឯកសារគ្រប់គ្រាន់សម្រាប់ចៅក្រម យកមកធ្វើជាមូលដ្ឋានក្នុងការវាយតម្លៃអំពីព្យសនកម្មនោះទេ។

**ឧទាហរណ៍៖** បទល្មើសបង្ករបួសស្នាម គឺជាព្យសនកម្មកើតឡើងលើរូបកាយជនរងគ្រោះ ហើយការកំណត់របួសធ្ងន់ ឬស្រាល គឺអាចប្រើប្រាស់ការធ្វើកោសលវិច័យ ដែលមានគ្រូពេទ្យជំនាញមកបញ្ជាក់ទំហំនៃការខូចខាត ឬតម្លៃទ្រព្យសម្បត្តិ។

### ៣. ព្យសនកម្មផ្លូវចិត្ត

ព្យសនកម្មខាងផ្លូវចិត្ត គឺជាព្យសនកម្មដែលពិបាកក្នុងការកត់សម្គាល់ និងអាចបង្ហាញឱ្យបានដឹង ថាតើព្យសនកម្មបែបនោះស្ថិតក្នុងកម្រិតបែបណា និងគោរពតាមបទដ្ឋានណាមួយ ដើម្បីឱ្យចៅក្រមយកមកពិចារណាក្នុងការវាយតម្លៃនៃការខូចខាត។ ដូច្នេះ ទាមទារឱ្យមានការកំណត់ជាក់លាក់ពីអ្នកជំនាញ និងអាស្រ័យទៅតាមកាលៈទេសៈជុំវិញ និងកត្តាដែលនាំឱ្យមានការខូចខាត។[11]

ព្យសនកម្មខាងផ្លូវចិត្តអាចរួមបញ្ចូលទាំងវិល្លាសស្មារតី ឬជំងឺផ្លូវចិត្ត ឬសតិអារម្មណ៍លើចិត្តរបស់ជនរងគ្រោះ ដូចជាជំងឺបាក់ស្បាត ជាដើម។ សំណងជំងឺចិត្តចាត់ទុកជាការជួសជុលព្យសនកម្មផងដែរ គឺជាការជួសជុលព្យសនកម្មខាងផ្លូវចិត្ត។ នៅពេលដែលអំពើល្មើសមួយកើតឡើង វាមិនត្រឹមតែបង្កនូវគ្រោះថ្នាក់ និងខូចខាតដល់រូបរាងកាយ ទ្រព្យសម្បត្តិជនរងគ្រោះ ឬក្រុមគ្រួសារជនរងគ្រោះប៉ុណ្ណោះទេ តែក៏អាចបង្កជាវិបត្តិផ្នែកផ្លូវចិត្តដែលអាចបន្សល់ទុកដល់ជនរងគ្រោះនៅថ្ងៃមុខថែមទៀតផង។ សម្រាប់តុលាការបារាំង បានសម្រេចទទួលយល់ព្រមឱ្យមានសំណង ជាប្រាក់ដល់ព្យសនកម្មផ្លូវចិត្ត ដែលកើតពីទុក្ខសោក បើទោះបីជាគ្មានការខូចខាតផ្លូវកាយ ឬខូចខាតសម្ភារៈអ្វីមួយក៏ដោយ។[12] ការផ្តល់សំណងបែបនេះ ទំនងជាអាចធ្វើទៅបាន តែចំពោះអ្នកដែលមានទំនាក់ទំនងញាតិជាមួយជនរងគ្រោះ ឬដោយជនរងគ្រោះដោយផ្ទាល់នៃអំពើនោះតែប៉ុណ្ណា។ នៅពេលដែលជនរងគ្រោះទាមទារនូវសំណងផ្លូវចិត្ត មិនតម្រូវឱ្យបង្ហាញភស្តុតាងជាក់លាក់អំពីចំនួននៃសំណងនោះទេ ពីព្រោះការកំណត់សម្គាល់ថាជនរងគ្រោះទទួលរងនូវព្យសនកម្មផ្លូវចិត្តឬអត់តាមរយៈការដាក់ភស្តុតាង ហាក់មិនអាចទៅរួច។ ហើយចំនួនជាក់លាក់ត្រូវកំណត់ដោយតុលាការ ប៉ុន្តែជនរងគ្រោះ ឬអ្នកមានសិទ្ធិទាមទារ ត្រូវបង្ហាញពីភាពឈឺចាប់ ទំនាក់ទំនងគ្រួសារ សកម្មភាពនានាដែលជា អនុស្សាវរីយ៍ជាមួយគ្នាពីមុនមក រូបភាពខ្សែវីដេអូ អារម្មណ៍ខ្លោចផ្សារ ការបាក់ទឹកចិត្ត ជាអាទិ៍។

[11] ក្រមរដ្ឋប្បវេណី,លេខ នស/រកម១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ មាត្រា៤០២

[12] សាយ បូរី, នីតិរដ្ឋបាលទូទៅ បោះពុម្ពលើកទី៣ ឆ្នាំ២០០៦ ទំព័រ៣៥៩

**ឧទាហរណ៍៖** មានបទល្មើសឆបោក គឺជនរងគ្រោះត្រូវតែបង្ហាញថា តើការឆបោកមកលើខ្លួនមានការប៉ះពាល់ផ្លូវចិត្ត ថាខ្លួនទទួលរងការឈឺចាប់ ឬការបំពានបែបណាខ្លះ ទើបអាចឱ្យចៅក្រមយកមកធ្វើជាមូលដ្ឋានក្នុងការយកមកធ្វើការវាយតម្លៃផ្នែកចិត្តសាស្ត្របាន។

**ឧទាហរណ៍៖** លោក **ក** ជាអ្នករត់ម៉ូតូឌុប នៅរាជធានីភ្នំពេញ ជាបង្គោលគ្រួសារ។ ជាធម្មតា លោក **ក** អាចទទួលបានចំណូលជាមធ្យម ១០០០០០រ(ដប់ម៉ឺន)រៀល ក្នុងមួយថ្ងៃ។ នៅថ្ងៃមួយលោក **ក** មានជម្លោះជាមួយលោក **ខ** ឈានដល់ការប្រើប្រាស់ហិង្សាដោយមានអាវុធ(ដាវ)។ លោក **ក** ត្រូវបានលោក **ខ** កាប់ចំជើងបណ្ដាលឱ្យពិការជើងមួយជើងខាងស្ដាំ ហើយម៉ូតូសម្រាប់រត់ឌុបនោះក៏ត្រូវលោក **ខ** កាប់ខ្ទិចខុសពីសភាពដើមដែរ តាមស្ថានភាពនៃរូបរាងកាយ នឹងសម្ភារៈសម្រាប់ប្រកបរបររកស៊ី ធ្វើឱ្យលោក **ក** មិនអាចប្រកបមុខរបររត់ម៉ូតូឌុបបានទៀតទេ។ តាមឧទាហរណ៍នេះអាចបកស្រាយបានថា មុនពេលមានបទល្មើសកើតឡើងស្ថានភាពទ្រព្យសម្បត្តិរបស់លោក **ក** អាចរកចំណូលបាន ១០០០០០រ(ដប់ម៉ឺន)រៀល ក្នុងមួយថ្ងៃ ប៉ុន្តែក្រោយពេលបទល្មើសកើតឡើង លោក **ក** ត្រូវបាត់បង់ប្រាក់ចំណូលជាមធ្យម ១០០០០០រ(ដប់ម៉ឺន)រៀល ក្នុងមួយថ្ងៃ ហើយត្រូវចំណាយប្រាក់ផ្សេងៗទៀត ដូចជាថ្លៃព្យាបាលជាដើម។ ដូចនេះលោក **ខ** ត្រូវទទួលខុសត្រូវ ក្នុងការផ្ដល់នូវសំណងនៃការខូចខាត ទៅលើទ្រព្យសម្បត្តិដែលលោក **ក** បានបាត់បង់ ដូចជាម៉ូតូ ក៏ដូចជាទ្រព្យសម្បត្តិដែលមានដូចជា ប្រាក់ចំណូលប្រចាំថ្ងៃរបស់លោក **ក** ១០០០០០រ(ដប់ម៉ឺន)រៀល ក្នុងមួយថ្ងៃ និងសំណងលើព្យសនកម្មខាងរូបកាយ និងការចំណាយផ្សេងៗទៀតក្រោយពីមានបទល្មើស។

# ជំពូកទី២
# នីតិវិធីអនុវត្តចំពោះបណ្ដឹងទាមទារ
# ឱ្យសងសំណងនៃការខូចខាត

## ជំពូកទី២

## នីតិវិធីអនុវត្តចំពោះបណ្ដឹងទាមទារឱ្យសងសំណងនៃការខូចខាត

នៅពេលដែលរឿងក្តីព្រហ្មទណ្ឌកំពុងដំណើរការ ជនរងគ្រោះអាចចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ដើម្បីសុំទាមទារសំណងនៃការខូចខាតបាន មានន័យថាបណ្តឹងសុំទាមទារសំណងនៃការខូចខាត (បណ្តឹងរដ្ឋប្បវេណី) អាចធ្វើឡើងក្នុងពេលជាមួយគ្នានឹងបណ្តឹងអាជ្ញា នៅចំពោះមុខសាលាជម្រះក្តីព្រហ្មទណ្ឌតែម្តង ហើយបណ្តឹងរដ្ឋប្បវេណីនេះទៀតសោតក៏អាចធ្វើបានផងដែរនៅចំពោះមុខសាលាជម្រះក្តីរដ្ឋប្បវេណី ប្រសិនបើជនរងគ្រោះមិនបានទាមទារសំណងនៃការខូចខាតនៅចំពោះមុខសាលាជម្រះក្តីព្រហ្មទណ្ឌ។ ប៉ុន្តែដោយសារតែបណ្តឹងទាំងពីរនេះពាក់ព័ន្ធនឹងអង្គហេតុតែមួយ ប្រសិនជនរងគ្រោះបានធ្វើការទាមទារឱ្យជួសជុលព្យសនកម្មនៅសាលាជម្រះក្តីរដ្ឋប្បវេណី ហើយតុលាការព្រហ្មទណ្ឌកំពុងចាត់ចែងទៅលើបណ្តឹងអាជ្ញាចំពោះអង្គហេតុនោះ ក្នុងករណីនេះតុលាការរដ្ឋប្បវេណីត្រូវផ្អាកការដំណើរការនីតិវិធីចំពោះបណ្តឹងទាមទារសំណងនៃការខូចខាតសិន (រឿងព្រហ្មទណ្ឌបង្អង់រឿងរដ្ឋប្បវេណីទុកមួយអន្លើសិន)។ ទោះបីជាយ៉ាងណាមិនថា ការទាមទារសំណងនៃការខូចខាតនោះ ធ្វើនៅសាលាជម្រះក្តីព្រហ្មទណ្ឌ ឬសាលាជម្រះក្តីរដ្ឋប្បវេណី ក៏ការសម្រេចអំពីសំណងនៃការខូចខាត ត្រូវព្យួរសិនដរាបណាមិនទាន់មានសេចក្តីសម្រេចស្ថាពរមួយ ត្រូវបានប្រកាសលើបណ្តឹងអាជ្ញា[13]។ ជាគំនិតមួយជនរងគ្រោះគួរតែធ្វើការទាមទារនូវសំណងនៃការខូចខាតដែលកើតឡើងពីបទល្មើសនោះ នៅសាលាជម្រះក្តីព្រហ្មទណ្ឌតែម្តង ជៀសវាងការខាតបង់ពេលវេលា នឹងប្រាក់ផងដែរព្រោះថា បណ្តឹងដែលដាក់នៅសាលាជម្រះក្តីរដ្ឋប្បវេណីតម្រូវឱ្យជនរងគ្រោះបង់ប្រដាប់ក្តីលើពាក្យបណ្តឹងនោះទើបនីតិវិធីអាចដំណើរការបាន មួយវិញទៀតសេចក្តីសម្រេចរបស់សាលាជម្រះក្តីព្រហ្មទណ្ឌដែលសម្រេចអំពីសំណងរដ្ឋប្បវេណីមានអានុភាពអាចអនុវត្តតាមប្បញ្ញត្តិនៃក្រមនីតិរដ្ឋប្បវេណី និងអាចបង្ខំដល់រូបកាយលើទណ្ឌិតបាន ផ្ទុយពីសេចក្តីសម្រេចដែលចេញដោយសាលាជម្រះក្តីរដ្ឋប្បវេណីអាចអនុវត្តបានតែតាមប្បញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីតែប៉ុណ្ណោះ មិនអាចអនុវត្តបង្ខំដល់រូបកាយលើទណ្ឌិតបានឡើយ។ ម៉្យាងវិញទៀតការទទួលបាននូវសំណងនៃការខូចខាតអាចធ្វើទៅបានលុះត្រាតែបណ្តឹងទាមទារនោះធ្វើឡើងក្នុងអំឡុងពេលដែលអាជ្ញាយុកាលមិនទាន់ផុតរលត់។ តាមមាត្រា ២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ថា "បណ្តឹងរដ្ឋប្បវេណីត្រូវផុតអាជ្ញាយុកាលតាមវិធាននៃក្រមរដ្ឋប្បវេណី។ ប៉ុន្តែបណ្តឹងរដ្ឋប្បវេណីនេះមិនអាចធ្វើបានទៀតទេនៅមុខតុលាការព្រហ្មទណ្ឌ ក្រោយការផុតចិរវេលានៃអាជ្ញាយុកាលរបស់បណ្តឹងអាជ្ញា"។ យោងតាមក្រមរដ្ឋប្បវេណីមាត្រា៧៦៥ ការទាមទារសំណងនៃការខូចខាត ដោយផ្អែកលើអំពើអនីត្យានុកូល អាជ្ញាយុកាលមានរយៈពេល៣ ឆ្នាំ និង១០ឆ្នាំ និងការទាមទារសំណងនៃការខូចខាតដោយផ្អែកលើសិទ្ធិលើបំណុល តាមមាត្រា ៤៨២ នៃក្រមរដ្ឋប្បវេណី កំណត់អាជ្ញាយុកាលនៃការទាមទារសិទ្ធិលើ

[13] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា២២

បំណុលចំនួន ៥ឆ្នាំ។ ក្នុងករណីនេះ ប្រសិនបើអាជ្ញាយុកាលផ្អែករដ្ឋប្បវេណីកំណត់ដោយក្រមរដ្ឋប្បវេណីមានរយៈពេល វែងជាងអាជ្ញាយុកាលនៃបណ្តឹងអាជ្ញា ការផុតអាជ្ញាយុកាលនៃបទល្មើសពុំអាចជាឧបសគ្គរាំងដល់ជនរងគ្រោះប្តឹងទៅតុលាការរដ្ឋប្បវេណីដើម្បីទាមទារសំណងនោះទេ។

សូមបញ្ជាក់ផងដែរថា នីតិវិធីអនុវត្តចំពោះបណ្តឹងទាមទារសំណងនៃការខូចខាត ត្រង់ចំណុចនេះ គឺបកស្រាយតែនីតិវិធីអនុវត្តនៅសាលាជម្រះក្តីព្រហ្មទណ្ឌតែប៉ុណ្ណោះ។

## ផ្នែកទី១៖ បណ្តឹងសុំទាមទារសំណងការខូចខាត

### ១.ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីអាចដាក់ពាក្យប្តឹងសុំទាមទារសំណងនៃការខូចខាតទៅសាលាជម្រះក្តីព្រហ្មទណ្ឌនៅ ៤(បួន) ដំណាក់កាលនៃនីតិវិធី ដូចជា៖

#### ១.១ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅដំណាក់កាលស៊ើបអង្កេត

ជាជំហានដំបូងបុគ្គលគ្រប់រូបដែលប្រកាសថា ខ្លួនជាអ្នករងគ្រោះនៃបទល្មើស អាចដាក់ពាក្យបណ្តឹងបាន ទៅមន្ត្រីនគរបាលយុត្តិធម៌ ឬដាក់ទៅតុលាការដែលមានសមត្ថកិច្ចផ្ទាល់ក៏បាន។ ប៉ុន្តែជាគោលការណ៍ បណ្តឹងរបស់ជនរងគ្រោះគ្រាន់តែជាបណ្តឹងទាមទារ ឬហៅថាបណ្តឹងសាមញ្ញតែប៉ុណ្ណោះ គ្មានអានុភាពនាំឱ្យធ្វើការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌឡើយ[14] មានតែព្រះរាជអាជ្ញាតែប៉ុណ្ណោះដែលអាចធ្វើការចោទប្រកាន់ចំពោះបទល្មើស។ នៅក្នុងបណ្តឹងទាមទាររបស់ជនរងគ្រោះនេះផងដែរ ជនរងគ្រោះអាចធ្វើការទាមទារនូវសំណងនៃការខូចខាតបាននៅក្នុងពាក្យបណ្តឹង។ តាមការអនុវត្តនៅតាមសាលាជម្រះក្តីជាន់ទាប ជនរងគ្រោះតែងតែទាមទារសំណងនៃការខូចខាត ជាមួយនឹងការរាយការណ៍អំពីបទល្មើសតែម្តង ដោយមិនធ្វើពាក្យបណ្តឹងដាច់ដោយឡែកនោះទេ កាលណាការទាមទារសំណងនៃការខូចខាតធ្វើឡើងដោយផ្ទាល់មាត់ មន្ត្រីនគរបាលយុត្តិធម៌ ឬតំណាងអយ្យការត្រូវធ្វើកត់ការទាមទារនោះ ចូលទៅក្នុងកំណត់ហេតុ។ ក្នុងករណីដែលជនរងគ្រោះខកខានមិនបានធ្វើការទាមទារនូវសំណងនៃការខូចខាតនៅពេលដាក់ពាក្យបណ្តឹងទេនោះ ជនរងគ្រោះនៅមានសិទ្ធិក្នុងការទាមទារនូវសំណងនៃការខូចខាតបានដដែល ដោយការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមផ្លូវអន្តរាគមន៍ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមផ្លូវបណ្តឹង និងជាចុងក្រោយជនរងគ្រោះអាចធ្វើការទាមទារនូវសំណងនៃការខូចខាតបានដោយការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងពេលសវនាការ។

#### ១.២ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមផ្លូវអន្តរាគមន៍

ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមផ្លូវអន្តរាគមន៍ គឺសំដៅដល់ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅពេលដែលការស៊ើបសួរត្រូវបានបើក ដោយការប្តឹងសុំឱ្យបើកការស៊ើបសួររបស់ព្រះរាជអាជ្ញា (ដីកា

[14] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា៦ កថាខណ្ឌទី១

សន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ) រហូតដល់ការស៊ើបសួរត្រូវបានបិទ ជនរងគ្រោះមិនអាចធ្វើការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរបានទៀតឡើយ ខុសពី វិធាន២៣ស្ទួននៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកម្ពុជា ក្នុងខ្លឹមសារដែលថាជនរងគ្រោះដែលចង់ចូលរួមក្នុងរឿងក្តី ក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរមិនឱ្យលើសពី១៥(ដប់ប្រាំ)ថ្ងៃ បន្ទាប់ពីចៅក្រមស៊ើបសួរជូនដំណឹងទៅភាគីអំពីការបិទការស៊ើបសួរ។ វិធាននេះ ក៏បានចែងដែលថា ចៅក្រមស៊ើបសួរត្រូវជូនដំណឹងទៅព្រះរាជអាជ្ញា និងជនត្រូវចោទអំពីពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែត្រូវអនុវត្តវិធាននេះ ដោយពិចារណាលើភាពចាំបាច់នៃការការពារជនរងគ្រោះ។[15] ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះ ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថា កាលណាការស៊ើបសួរត្រូវបានបើក បុគ្គលគ្រប់រូបដែលបានប្រកាសខ្លួនថា ជាជនរងគ្រោះអាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរបានគ្រប់ពេលវេលា។ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមផ្លូវអន្តរាគមន៍ ធ្វើឡើងដោយគ្មានតម្រូវតាមទម្រង់ណាមួយឡើយ។ កាលណាការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានធ្វើឡើងតាមរយៈលិខិត លិខិតនោះត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង។ កាលណាការតាំងខ្លួនត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុ។ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងអំពីការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទេនេះដល់ព្រះរាជអាជ្ញា និងដល់ជនត្រូវចោទ។[16] នេះជាយន្តមួយដែលផ្តល់សិទ្ធិឱ្យជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិក្នុងការទាមទារនូវសំណងនៃការខូចខាត នៅពេលដែលខ្លួនខកខានការទាមទារនៅដំណាក់កាលស៊ើបអង្កេត។

### ១.៣ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមផ្លូវបណ្តឹង

ជាគោលការណ៍បណ្តឹងរបស់ជនរងគ្រោះគ្រាន់តែជាបណ្តឹងទាមទារ ឬហៅថាបណ្តឹងសាមញ្ញតែប៉ុណ្ណោះ គ្មានអានុភាពនាំឱ្យធ្វើការចោទប្រកាន់បទព្រហ្មទណ្ឌឡើយ មានតែព្រះរាជអាជ្ញាតែប៉ុណ្ណោះដែលអាចធ្វើឱ្យបណ្តឹងមានចលនាបាន។ ជាអញ្ញត្រកម្មមួយ ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម អាចដាក់បណ្តឹងអាជ្ញាឱ្យមានចលនាបានតាមរយៈការបើកការស៊ើបសួររបស់ចៅក្រមស៊ើបសួរដោយការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបសួរផ្ទាល់តែម្តង[17] ក្នុងករណីដែលបណ្តឹងរបស់ជនរងគ្រោះស្ថិតនៅភាពដែលគ្មានចម្លើយ (មិនទាន់បើកការស៊ើបសួរ) ឬព្រះរាជអាជ្ញាធ្វើការតម្កល់រឿងទុកឥតចាត់ការ។

[15] សេចក្តីពន្យល់នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា៖ សេចក្តីពន្យល់ចំពោះករណីយុត្តិសាស្ត្រ អ.វ.ត.ក និងអន្តរជាតិ បោះពុម្ពផ្សាយលើកទី១ នៅខែមិនា ឆ្នាំ២០១៤ ទំព័រ៦៦

[16] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា១៣៧

[17] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា៥

### ក. ការសម្រេចអំពីការបើកការស៊ើបសួរ

ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម អាចដាក់ពាក្យប្ដឹងជូនដល់ចៅក្រមស៊ើបសួរមានសមត្ថកិច្ច ដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។ ពាក្យប្ដឹងអាចដាក់ក្នុងនាមជនរងគ្រោះដោយមេធាវី។[18] បើកាលណាចៅក្រមស៊ើបសួរទទួលពាក្យបណ្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចៅក្រមស៊ើបសួរត្រូវអនុវត្តកាតព្វកិច្ចធ្វើការកត់សម្គាល់នូវពាក្យបណ្ដឹង ដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនោះតាមរយៈដីកា ហើយចៅក្រមស៊ើបសួរត្រូវបញ្ជូនបណ្ដឹងនោះទៅកាន់ព្រះរាជអាជ្ញា។ ក្រោយពីបានឃើញពាក្យបណ្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរួចមក ព្រះរាជអាជ្ញាត្រូវប្ដឹងទៅចៅក្រមស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដោយដីកានេះ អាចធ្វើឡើងប្រឆាំងនឹងអញ្ញាតជនទោះបីជាបណ្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចោទទៅលើបុគ្គលម្នាក់ ឬច្រើននាក់ក៏ដោយ។

ព្រះរាជអាជ្ញាអាចសុំឱ្យចៅក្រមស៊ើបសួរកុំឱ្យស៊ើបសួរ ប្រសិនបើបណ្ដឹងអាជ្ញាត្រូវបានផុតរលត់ ឬប្រសិនអំពើនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌ។ ហើយនៅពេលដែលចៅក្រមស៊ើបសួរសម្រេចមិនបើកការស៊ើបសួរ ចៅក្រមរូបនោះត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ ដែលត្រូវជូនដំណឹងជាបន្ទាប់ដល់ដើមបណ្ដឹងរដ្ឋប្បវេណី។ នៅក្នុងករណីដែលចៅក្រមស៊ើបសួរ នៅតែសម្រេចស៊ើបសួរវិញនោះ ចៅក្រមស៊ើបសួររូបនោះត្រូវចេញដីកាសម្រេចដែលមានសំអាងហេតុ ហើយត្រូវជូនដំណឹងបន្ទាប់ដល់ព្រះរាជអាជ្ញា។[19]

### ខ. ប្រាក់តម្កល់ធានារឿងក្ដី

នៅក្នុងករណីដែលចៅក្រមស៊ើបសួរសម្រេចបើកការស៊ើបសួរតាមរយៈបណ្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបង់ប្រាក់តម្កល់ទុកដើម្បីធានាដល់ដំណើរការរឿងក្ដី។ ដោយផ្អែកទៅលើធនធាននៃដើមបណ្ដឹងរដ្ឋប្បវេណី និងទៅលើការលំបាកនៃរឿងដែលអាចមើលឃើញជាមុន ចៅក្រមស៊ើបសួរកំណត់តាមដីកាសម្រេចនូវចំនួនទឹកប្រាក់ដែលដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបង់ ព្រមទាំងរយៈពេលដែលត្រូវបង់ប្រាក់នេះផងដែរ។ ប្រសិនបើដើមបណ្ដឹងរដ្ឋប្បវេណីពុំមានលទ្ធភាពអាចបង់ប្រាក់តម្កល់ទុកបានទេ ចៅក្រមស៊ើបសួរអាចលើកលែងមិនឱ្យបង់ប្រាក់នោះបាន។ ដីកានេះត្រូវជូនដំណឹងជាបន្ទាន់ដល់ដើមបណ្ដឹងរដ្ឋប្បវេណី។ ក្នុងករណីដែលមានការបង់ប្រាក់តម្កល់ទុក ដើមបណ្ដឹងរដ្ឋប្បវេណីទទួលបង្កាន់ដៃដែលមានចុះហត្ថលេខាដោយប្រធានតុលាការ ព្រះរាជអាជ្ញា និងក្រឡាបញ្ជី។ ប្រសិនប្រាក់តម្កល់ទុក មិនត្រូវបានបង់នៅក្នុងរយៈពេលដែលកំណត់ដោយចៅក្រមស៊ើបសួរទេ ពាក្យប្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវប្រកាសថាមិនអាចទទួលបានដោយចៅក្រមស៊ើបសួរ។ ចៅក្រមស៊ើបសួរនេះ សម្រេចតាមដីកាដែលត្រូវជូនដំណឹងជាបន្ទាន់

[18] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា១៣៨

[19] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា១៣៩

ដល់ដើមបណ្តឹងរដ្ឋប្បវេណី។ ប្រាក់តម្កល់ទុកត្រូវតម្កល់ទុកនៅក្នុងករណីពិសេស ដែលបើកដោយធនាគារ ឬរក្សាទុកនៅក្នុងទីកន្លែងដែលមានការធានាសន្តិសុខយ៉ាងរឹងមាំ។ ទីកន្លែងនេះត្រូវបានជ្រើសរើសតាមការព្រមព្រៀងគ្នារបស់ប្រធានតុលាការ និងព្រះរាជអាជ្ញា។

**ខ.១ ការសម្រេចអំពីពិន័យរដ្ឋប្បវេណី**

ប្រាក់តម្កល់ទុកត្រូវបង្វិលទៅសាមីខ្លួននៅពេលបញ្ចប់នីតិវិធី លើកលែងក្នុងករណីដែលការស៊ើបសួរដែលបានបើកបន្ទាប់ពីមានពាក្យប្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានបិទតាមដីកាលើកលែងចោទប្រកាន់ ហើយប្រសិនបើចៅក្រមស៊ើបសួរ យល់ឃើញថា នីតិវិធីធ្វើឡើងដោយរំលោភ ឬដោយអូសបន្លាយពេលវេលា នោះចៅក្រមស៊ើបសួរ អាចសម្រេចតាមដីកាសម្រេចឱ្យដើមបណ្តឹងរដ្ឋប្បវេណីបង់ប្រាក់ពិន័យរដ្ឋប្បវេណី។ ចំនួនប្រាក់ពិន័យមិនអាចលើសចំនួនទឹកប្រាក់តម្កល់ឡើយ។ ដីកាសម្រេចឱ្យបង់ប្រាក់ពិន័យនេះ ត្រូវឱ្យដំណឹងដល់សាមីខ្លួនជាបន្ទាន់។[20]

**ខ.២ បណ្តឹងទាមទារឱ្យជួសជុលការខូចខាត**

កាលណាការស៊ើបសួរដែលបើកបន្ទាប់ពីមានពាក្យប្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានបិទតាមដីកាលើកលែងចោទប្រកាន់ចូលជាស្ថាពរ បុគ្គលដែលមានឈ្មោះនៅក្នុងពាក្យបណ្តឹង អាចប្តឹងសុំការជួសជុលសំណងពីអ្នកដែលប្តឹងពីខ្លួនប្រសិនបើនីតិវិធីធ្វើឡើងដោយឈ្មោះ ដោយរំលោភ ឬដោយអូសបន្លាយពេលវេលា។ ពាក្យប្តឹងសុំការជួសជុលនេះ ត្រូវដាក់ជូនដល់តុលាការជាន់ដំបូងដែលមានរឿងត្រូវបានស៊ើបសួរ។ តុលាការអាចសុំឱ្យគេបញ្ជូនសំណុំរឿងមកពិនិត្យ។[21]

**គ. បណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ**

ចៅក្រមស៊ើបសួរអាចបើកការស៊ើបសួរបានលុះត្រាតែមានការប្តឹងសុំឱ្យបើកការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាតែប៉ុណ្ណោះ ប៉ុន្តែដូចបានជម្រាបខាងលើ ចៅក្រមស៊ើបសួរអាចបើកការស៊ើបសួរបានដែរ ប្រសិនបើមានបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីពីជនរងគ្រោះ (ការដាក់បណ្តឹងអាជ្ញាឱ្យមានចលនាដោយជនរងគ្រោះ) ទោះបីជាគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរពីព្រះរាជអាជ្ញាក៏ដោយ។ ប៉ុន្តែការស៊ើបសួរតាមរយៈបណ្តឹងរបស់ជនរងគ្រោះនេះ ហាក់ចងកាតព្វកិច្ចឱ្យចៅក្រមស៊ើបសួរកត់សម្គាល់នូវបណ្តឹងនោះឱ្យបានដិតដល់បំផុតមុនឈានដល់ការសម្រេចបើកការស៊ើបសួរ ជៀសវាងការប៉ះពាល់ និងខាតពេលវេលាចំពោះការដំណើរការរឿងក្តី ដូចនេះហើយចៅក្រមស៊ើបសួរអាចសម្រេចមិនបើកការស៊ើបសួរបានតាមរយៈដីកាសម្រេច ឬប្រកាសមិនទទួលបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋ

[20] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា១៤១

[21] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា១៤២

ប្បវេណីតែម្តង ក្នុងករណីដែលដើមបណ្តឹងរដ្ឋប្បវេណីមិនបានបង់ប្រាក់តម្កល់ទុក។ ជាមួយគ្នានោះដែរ ច្បាប់ក៏បានផ្តល់សិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីប្តឹងទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ដែលមានសមត្ថកិច្ចលើដីកាសម្រេចរបស់ចៅក្រមស៊ើបសួរផងដែរ ក្នុងករណី៖

- ចៅក្រមស៊ើបសួរ ចេញដីកាមិនព្រមស៊ើបសួរ
- ចៅក្រមស៊ើបសួរ ចេញដីកាប្រកាសមិនទទួលពាក្យបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី
- និង ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីមិនពេញចិត្តនឹងការកំណត់ចំនួនប្រាក់តម្កល់ទុក ដែលចៅក្រមស៊ើបសួរបានកំណត់នៅក្នុងដីកាសម្រេច។[22]

ដើមបណ្តឹងរដ្ឋប្បវេណីអាចប្តឹងទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ដែលមានសមត្ថកិច្ច ក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃ គិតពីថ្ងៃជូនដំណឹងអំពីដីកា។ ប្រសិនបើការជូនដំណឹងធ្វើឡើងដោយការប្រគល់សេចក្តីចម្លងនៃដីកាដែលមានចំណារទទួល នោះរយៈពេលបណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ ផ្តើមគិតពីការបរិច្ឆេទនៃចំណារទទួលនោះ។[23] បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវធ្វើតាមការប្រកាសប្តឹង នៅក្រឡាបញ្ជីនៃតុលាការជាន់ដំបូង។ កាលណាបានទទួលបណ្តឹងឧទ្ធរណ៍ ក្រឡាបញ្ជីនៅតុលាការជាន់ដំបូងជូនដំណឹងភ្លាមដល់ចៅក្រមស៊ើបសួរដែលទទួលបន្ទុក ហើយក្រឡាបញ្ជីនៃចៅក្រមស៊ើបសួរនោះត្រូវរៀបចំ និងបញ្ជូនសំណុំរឿងទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ ដោយមានសេចក្តីចម្លងនៃលិខិតប្តឹងឧទ្ធរណ៍ភ្ជាប់ជាមួយផង។

- **នីតិវិធីអនុវត្តនៅចំពោះមុខសភាស៊ើបសួរសាលាឧទ្ធរណ៍**

តាមការកត់សម្គាល់នូវការអនុវត្តជាក់ស្តែង នៅពេលដែលសំណុំរឿងបានមកដល់សភាស៊ើបសួរហើយនោះ ប្រធានសភាស៊ើបសួរចាត់តាំងចៅក្រមមួយ(១)រូប ដើម្បីធ្វើចំណាត់ការលើសំណុំរឿងនោះ។ នីតិវិធីអនុវត្តលើបណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរដោយដើមបណ្តឹងរដ្ឋប្បវេណី របស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ ឃើញថាមិនមានភាពស្មុគស្មាញច្រើននោះទេ ពោលគឺក្រឡាបញ្ជីនៃចៅក្រមទទួលបន្ទុកត្រូវធ្វើការជូនដំណឹងអំពីកាលបរិច្ឆេទសវនាការទៅដើមបណ្តឹងរដ្ឋប្បវេណីតាមការកំណត់របស់ចៅក្រម។ សវនាការលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹរដ្ឋប្បវេណីត្រូវធ្វើឡើងជាអសាធារណៈ ព្រោះខ្លាចប៉ះពាល់ដល់កិច្ចដំណើរការនីតិវិធីរបស់ចៅក្រមស៊ើបសួរ ដោយហេតុថា ទោះបីជាមានបណ្តឹងមកសភាស៊ើបសួរក៏ដោយក្រៅពីដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរនៅតែបន្តការស៊ើបសួររបស់ខ្លួនដដែល លើកលែងតែមានសេចក្តីផ្អុយពីប្រធានសភា

[22] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា២៦៨

[23] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា២៧០

ស៊ើបសួរ[24] ។ ហើយការជំនុំជម្រះត្រូវធ្វើឡើងជាក្រុមប្រឹក្សា ដោយមានចៅក្រម ១(មួយ)រូប ជាប្រធានក្រុមប្រឹក្សា និងពីរ (២)រូបជាចៅក្រមប្រឹក្សា និងមានវត្តមានរបស់តំណាងមហាអយ្យការចូលរួមផងដែរ។ បន្ទាប់ពីអាននូវរបាយការណ៍ និងការកត់សម្គាល់របស់តំណាងមហាអយ្យការចប់ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវរៀបរាប់អំពីហេតុដែលនាំឱ្យមានការមិនពេញចិត្តចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរនោះ ទៅក្រុមប្រឹក្សាដើម្បីធ្វើការសម្រេច។ ក្រោយការសម្រេចសេចក្តីលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីរួចមក សាលដីការបស់សភាស៊ើបសួរត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរដែលទទួលបន្ទុកដើម្បីអនុវត្តតាមសេចក្តីសម្រេចនោះ។ ដើមបណ្តឹងរដ្ឋប្បវេណីអាចប្តឹងសាទុក្ខនឹងសេចក្តីសម្រេចរបស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍បាន។

### ១.៤ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងពេលសវនាការ

ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីខកខានមិនបានទាមទារសំណងនៃការខូចខាត នៅដំណាក់កាលស៊ើបសួរអង្កេត និងនៅចំពោះមុខចៅក្រមស៊ើបសួរ (ទាំងការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមផ្លូវបណ្តឹង និងការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមផ្លូវអន្តរាគមន៍) ឬនៅក្នុងករណីខ្លះ មិនឆ្លងកាត់ការស៊ើបសួររបស់ចៅក្រមស៊ើបសួរនោះ ឧទាហរណ៍ដូចជា បទល្មើសមួយចំនួនមិនមានលក្ខណៈស្មុគស្មាញ ហើយមានលក្ខខណ្ឌពេញលេញដើម្បីឱ្យព្រះរាជអាជ្ញាធ្វើនីតិវិធីបង្ហាញខ្លួនភ្លាម ឬបញ្ជូនទៅជម្រះផ្ទាល់តែម្តង ដូច្នេះក្នុងកាលៈទេសៈទាំងនេះជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីអាចប្តឹងសុំទាមទារសំណងនៃការខូចខាតបាននៅចំពោះមុខចៅក្រមជំនុំជម្រះ នៅពេលសវនាការតែម្តងបាន។

ក្នុងពេលសវនាការ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីធ្វើតាមការប្រកាសប្តឹងសាមញ្ញចំពោះមុខក្រឡាបញ្ជី។ ការប្រកាសប្តឹងនេះត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុនៃសវនាការ។ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មិនអាចទទួលបានទេ ក្រោយពីសេចក្តីសន្និដ្ឋានសុំរបស់ព្រះរាជអាជ្ញាលើអង្គសេចក្តី។ ចំពោះជនរងគ្រោះដែលបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរួចហើយ នៅពេលស៊ើបសួរនោះមិនចាំបាច់បំពេញទម្រង់ការនេះជាថ្មីទៀតទេមុខតុលាការ។[25]

ដើមបណ្តឹងរដ្ឋប្បវេណីក៏អាចត្រូវបានអមដោយមេធាវីដែលខ្លួនបានជ្រើសរើស។ ដើមបណ្តឹងរដ្ឋប្បវេណីក៏អាចត្រូវបានតំណាងដោយមេធាវី សហព័ទ្ធ ឬ ញាតិលោហិតផ្ទាល់ដែរ។ អ្នកតំណាងដែលមិនមែនជាមេធាវី ត្រូវមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ។[26]

[24] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា២៧៥

[25] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា៣១១

[26] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា៣១៣

## ២. ចុងចម្លើយនៃបណ្តឹងរដ្ឋប្បវេណី

ចុងចម្លើយនៃបណ្តឹងរដ្ឋប្បវេណី គឺជាអ្នកដែលត្រូវទទួលខុសត្រូវសងសំណងនៃការខូចខាតទៅជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី។ បណ្តឹងរដ្ឋប្បវេណី អាចធ្វើឡើងប្រឆាំងនឹងជនទាំងអស់ដែលត្រូវជួសជុលព្យសនកម្មបណ្តាលមកពីបទល្មើសរួមមាន៖

- ចារី សហចារីនៃបទល្មើស

ចំពោះបុគ្គលណាដែលប្រព្រឹត្តបទល្មើសដែលត្រូវចោទប្រកាន់។ ត្រូវចាត់ទុកជាចារីផងដែរ ចំពោះបុគ្គលណាដែលប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬ ក្នុងករណីដែលច្បាប់ចែង ចំពោះបទមជ្ឈិម។ **ឧទាហរណ៍៖** ឈ្មោះ **ក** បានប្រើហិង្សា ទៅលើឈ្មោះ **ខ** ដោយសារមានគំនុំក្នុងរបររកស៊ី។ ដូច្នេះឈ្មោះ **ក** ជាចារី។

ត្រូវចាត់ទុកជាសហចារី កាលណាមានបុគ្គលច្រើននាក់ បានព្រមព្រៀងគ្នាប្រព្រឹត្តបទល្មើសរួមគ្នាដោយផ្ទាល់។ ត្រូវចាត់ទុកជាសហចារីផងដែរ កាលណាមានបុគ្គលច្រើននាក់បានព្រមព្រៀងប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយផ្ទាល់ក្នុងករណីដែលច្បាប់មានចែងទុក។ **ឧទាហរណ៍៖** ឈ្មោះ **ក. ខ. គ.** បានរួមដៃគ្នាវាយ ហិង្សាទៅលើឈ្មោះ **ឃ.។** ក្នុងសកម្មភាពបែបនេះ ឈ្មោះ **ក. ខ. គ.** ជាសហចារីនៃបទល្មើស។

- អ្នកផ្តើមគំនិត អ្នកសមគំនិត

ត្រូវចាត់ទុកជាអ្នកផ្តើមគំនិត ក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិម ចំពោះបុគ្គលណាដែល៖

- ជំរុញឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ តាមការណែនាំ ឬ ការបញ្ជា
- បង្ករឱ្យមានបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ ដោយផ្តល់អំណោយ ដោយការសន្យា ឬការគំរាមកំហែង ការញុះញង់ ការលួងលោម ឬក៏ដោយការរំលោភអាជ្ញា ឬអំណាចរបស់ខ្លួន។ អ្នកផ្តើមគំនិតនឹងអាចត្រូវផ្តន្ទាទោសបានលុះត្រាតែបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវបានសម្រេច ឬបានប៉ុនប៉ង។ អ្នកផ្តើមគំនិតនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវបានផ្តន្ទាដូចគ្នានឹងចារីដែរ។

ត្រូវចាត់ទុកជាអ្នកសមគំនិតក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិម ចំពោះបុគ្គលណាដែលជួយសម្រួលដោយចេតនា ដល់ការប៉ុនប៉ង ឬការសម្រេចបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ ដោយផ្តល់ជំនួយ ឬ ការឧបត្ថម្ភរបស់ខ្លួន។ អ្នកសមគំនិតនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវផ្តន្ទាទោសដូចគ្នានឹងចារីដែរ។

- អ្នកទទួលខុសត្រូវរដ្ឋប្បវេណី[27]

អ្នកទទួលខុសត្រូវរដ្ឋប្បវេណី សំដៅដល់បុគ្គលដទៃទៀតក្រៅពី ចារី សហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត ដែលអ្នកទាំងនោះមានកាតព្វកិច្ចសងសំណងនៃការខូចខាតដល់ជនរងគ្រោះ ជំនួសចារី។ អ្នកទទួលខុសត្រូវរដ្ឋប្បវេណីរួមមាន ៖

[27] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា២១

**ឪពុកម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកគ្រប់គ្រង និងត្រួតពិនិត្យលើជនដែលមានវិបត្តិផ្នែកបញ្ញាស្មារតី** យោងតាមមាត្រា ៧៤៦ នៃក្រមរដ្ឋប្បវេណីបានកំណត់ថា៖

១/ បុគ្គលដែលមានករណីកិច្ចដែលបានកំណត់ដោយច្បាប់ក្នុងការត្រួតពិនិត្យអនីតិជនអាយុក្រោម ១៤ (ដប់បួន)ឆ្នាំ ឬបុគ្គលដែលស្ថិតក្នុងស្ថានភាពដែលមិនអាចយល់ដឹង និងវិនិច្ឆ័យបាន អំពីការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកស្មារតី ឬមូលហេតុផ្សេងទៀត មានករណីកិច្ចសងការខូចខាតរបស់អ្នកដទៃ ដែលកើតឡើង ដោយអំពើបំពានរបស់បុគ្គលនៅក្រោមការត្រួតពិនិត្យរបស់ខ្លួននេះ។

២/ បុគ្គលដែលមានករណីកិច្ចដែលបានកំណត់ដោយច្បាប់ក្នុងការត្រួតពិនិត្យអនីតិជនអាយុចាប់ពី ១៤(ដប់បួន)ឆ្នាំ ឡើងទៅ ត្រូវទទួលខុសត្រូវដោយសាមគ្គីភាពជាមួយអនីតិជន ចំពោះការខូចខាតរបស់អ្នកដទៃដែលកើតឡើង ដោយអំពើអនីត្យានុកូលរបស់អនីតិជននោះ។

៣/ បុគ្គលដែលមានករណីកិច្ចត្រួតពិនិត្យ ដែលទទួលខុសត្រូវក្នុងការសងការខូចខាត តាមចំណុចទី២ ខាងលើនេះ អាចរួចខ្លួនពីការទទួលខុសត្រូវក្នុងការសងសំណងការខូចខាតបានដោយបញ្ជាក់បង្ហាញថា ខ្លួនបានបំពេញករណីកិច្ចត្រួតពិនិត្យជាប្រក្រតី។

**និយោជក** យោងតាមមាត្រា ៧៤៧ នៃក្រមរដ្ឋប្បវេណីបានកំណត់ថា៖

១/ បុគ្គលដែលប្រើនិយោជិកដើម្បីអនុវត្តកិច្ចការ ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលនិយោជិកបានបង្កដល់អ្នកដទៃដោយខុសច្បាប់ ដោយកំហុសចេតនា ឬដោយកំហុសអចេតនា ក្នុងការអនុវត្តកិច្ចការនោះ។

២/ បុគ្គលដែលស្ថិតក្នុងឋានៈត្រូវត្រួតពិនិត្យនិយោជិកជំនួសនិយោជក ត្រូវទទួលខុសត្រូវដូចគ្នានឹងនិយោជកដែរ លើកលែងតែករណីដែលបុគ្គលនោះបានត្រួតពិនិត្យត្រឹមត្រូវ។

៣/ និយោជក ឬអ្នកត្រួតពិនិត្យជំនួស អាចទាមទារសំណងពីនិយោជិកបានដោយយោងទៅតាមកម្រិតនៃកំហុស របស់និយោជិកនោះ។

**និតិបុគ្គល** ជាទូទៅ គេរមែងគិតថា ការទទួលខុសត្រូវលើសំណងអាចមានសម្រាប់តែរូបវន្តបុគ្គលតែប៉ុណ្ណោះ តែជាការពិតក្រមរដ្ឋប្បវេណីក៏ទទួលស្គាល់ការទទួលខុសត្រូវរដ្ឋប្បវេណីរបស់នីតិបុគ្គលដែរ។ តាមបញ្ញត្តិនៃមាត្រា ៧៤៨ នៃក្រមរដ្ឋប្បវេណីបានកំណត់ថា:

១/ នីតិបុគ្គលត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត ដែលសមាជិកគណៈកម្មការនាយក ឬអ្នកតំណាងឯទៀត បានបង្កដល់អ្នកដទៃទៀតដោយខុសច្បាប់ ដោយកំហុសចេតនា ឬដោយកំហុសអចេតនា ក្នុងការអនុវត្តភារកិច្ច។

២/ បើបានសងការខូចខាតដូចការកំណត់ខាងលើនេះ នីតិបុគ្គលអាចទាមទារសំណងពីអ្នកតំណាង ដែលបានប្រព្រឹត្តអំពើបង្កការខូចខាត។

ដើមបណ្ដឹងរដ្ឋប្បវេណី ក៏អាចសុំឱ្យមានការជួសជុលព្យសនកម្មពីសិទ្ធិវន្តនៃជនជាប់ចោទបាន ប្រសិន បើជនជាប់ចោទនោះទទួលមរណភាពនៅក្នុងដំណើរការរឿងក្ដីព្រហ្មទណ្ឌ។[28]

## ផ្នែកទី២៖ ការសម្រេចសេចក្ដីលើសំណងនៃការខូចខាត

### ១. ការសម្រេចសេចក្ដីអំពីពិរុទ្ធភាព

ទោះបីជាបណ្ដឹងទាមទារសំណងនៃការខូចខាតដាច់ដោយឡែកពីបណ្ដឹងអាជ្ញា ប៉ុន្តែការសម្រេចសេចក្ដីអំពីបណ្ដឹងអាជ្ញាមានសារៈសំខាន់ណាស់ចំពោះបណ្ដឹងទាមទារសំណងនៃការខូចខាត។

តុលាការអាចសម្រេចអំពីការជួសជុលព្យសនកម្មបាន លុះត្រាតែបានពិនិត្យជាមុននៃបទល្មើសព្រហ្មទណ្ឌ ហើយប្រកាសថា ជនជាប់ចោទត្រូវមានពិរុទ្ធជាមុនសិន។[29] តុលាការធ្វើការប្រកាសអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ ក្នុងលិខិតសាលក្រម នៅពេលសវនាការ។ ដើម្បីកំណត់អំពីពិរុទ្ធភាពរបស់ជនជាប់ចោទបានតុលាការត្រូវពិនិត្យមើលទៅលើ៖

- អំពើនោះជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ
- ជនជាប់ចោទបានប្រព្រឹត្តអំពើដែលចោទប្រកាន់លើខ្លួនឬទេ។

ប្រសិនបើតុលាការយល់ឃើញថាអំពីនោះមិនមែនជាបទល្មើសទេ ឬក៏ជនជាប់ចោទគ្មានកំហុសទេនោះ ជនជាប់ចោទត្រូវបានរួចខ្លួនពីបទចោទ។ ផ្ទុយមកវិញប្រសិនបើតុលាការពិនិត្យឃើញថា ជនជាប់ចោទមានពិរុទ្ធពិតមែននោះ តុលាការត្រូវប្រកាសផ្ដន្ទាទោសជនជាប់ចោទតាមបញ្ញត្តិច្បាប់[30]

ក្រោយពីការប្រកាសទទួលស្គាល់អំពីពិរុទ្ធភាពរបស់ជនជាប់ចោទរួចមក ការពិចារណាអំពីចំនួននៃសំណងនៃការខូចខាត គឺជាភាពចំបាច់មួយ។ ក្នុងករណីដែលការទាមទារសំណងនៃកាខូចខាតត្រូវបានធ្វើឡើងនៅសាលាជម្រះក្ដីព្រហ្មទណ្ឌ នៅក្នុងសាលក្រមតែមួយជាមួយរឿងក្ដីព្រហ្មទណ្ឌ តុលាការសម្រេចអំពីផលប្រយោជន៍ផ្នែករដ្ឋប្បវេណី លើកលែងតែក្នុងករណីដែលការទាមទារសំណងនៃការខូចខាតធ្វើឡើងនៅសាលាជម្រះក្ដីរដ្ឋប្បវេណី នោះការសម្រេចសេចក្ដីអំពីផលប្រយោជន៍រដ្ឋប្បវេណី និងរឿងក្ដីព្រហ្មទណ្ឌត្រូវធ្វើឡើងដោយឡែក តាមសាលាជម្រះក្ដីនីមួយៗ។ តុលាការព្រហ្មទណ្ឌវិនិច្ឆ័យអំពីភាពអាចទទួលបាននៃការតាំងខ្លួនជាដើម

[28] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា២៤ កថាខណ្ឌទី១

[29] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា២៣

[30] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា៣៥០

បណ្តឹងរដ្ឋប្បវេណី ហើយសម្រេចអំពីពាក្យប្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ទៅលើជនជាប់ចោទ និងលើអ្នកទទួលខុសត្រូវរដ្ឋប្បវេណី។[31]

**ឧទាហរណ៍៖** សាលក្រមព្រហ្មទណ្ឌដែលសម្រេចលើសំណុំរឿង *លួចមានស្ថានទម្ងន់ទោសដោយសារការកាប់គាស់ទម្លុះទម្លាយ* ប្រកាស៖

- ផ្តន្ទាទោសដាក់ពន្ធនាគារលើជនជាប់ចោទឈ្មោះ **អ.ស** រយៈពេល ០៣ឆ្នាំ និង
- បង្គាប់ឱ្យជនជាប់ចោទឈ្មោះ **អ.ស** សងជម្ងឺចិត្តចំនួន ១.០០០.០០០(មួយលាន)រៀល ទៅឱ្យឈ្មោះ **ស.រ** ជាដើមបណ្តឹងរដ្ឋប្បវេណី
- ការទាមទារលើសពីនេះបដិសេធចោល។

បើក្រឡេកទៅមើលវិធានផ្ទៃក្នុងរបស់ អង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកម្ពុជា វិញយើងសង្កេតឃើញថា *អង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកម្ពុជា* សម្រេចអំពីផលប្រយោជន៍ផ្នែករដ្ឋប្បវេណី នៅក្នុងសាលក្រម ដូចនឹងការអនុវត្តនៅសាលាជម្រះក្តីទូទៅដែរ មួយវិញទៀត **អ.វ.ក.ក** មិនត្រូវសម្រេចអំពីបណ្តឹងរដ្ឋប្បវេណីដែលផ្ទុយទៅនឹងសាលក្រមសម្រេចអំពីបណ្តឹងអាជ្ញានៅក្នុងរឿងក្តីតែមួយឡើយ។

## ២. ជម្រើសនៃការតវ៉ាលើសេចក្តីសម្រេចអំពីប្រយោជន៍ផ្នែករដ្ឋប្បវេណី

ក្រោយពេលដែលសាលក្រមត្រូវបានប្រកាស ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីមិនពេញចិត្តសេចក្តីសម្រេចអំពីផលប្រយោជន៍ផ្នែករដ្ឋប្បវេណី ដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើការប្តឹងតវ៉ាដើម្បីផ្លាស់ប្តូរការសម្រេចសេចក្តីអំពីសំណងនៃការខូចខាតបាន ក្នុងករណីដែលសាលក្រមដែលសម្រេចអំពីផលប្រយោជន៍រដ្ឋប្បវេណីនោះមិនទាន់ចូលជាស្ថាពរ។

### ២.១.បណ្តឹងទាស់ចំពោះសាលក្រមផ្នែករដ្ឋប្បវេណី

បណ្តឹងទាស់គឺជាបណ្តឹងមួយដែលធ្វើឡើងប្រឆាំងនឹងសេចក្តីសម្រេចផ្នែកព្រហ្មទណ្ឌ ឬផ្នែករដ្ឋប្បវេណី ឬអាចប្រឆាំងទៅលើសាលក្រមទាំងមូល ក្នុងករណីដែលសាលក្រមនោះជាសាលក្រមកំបាំងមុខ។ នីតិវិធីប្តឹងទាស់ត្រូវធ្វើឡើងនៅសាលាជម្រះក្តីជាន់ទាបដែលចេញសាលក្រមដដែល។ ដើមបណ្តឹងរដ្ឋប្បវេណីក៏អាចធ្វើបណ្តឹងទាស់សាលក្រមកំបាំងមុខបានដែរ តែបណ្តឹងនេះត្រូវធ្វើទៅលើតែសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីតែប៉ុណ្ណោះ។ ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីធ្វើការប្តឹងទាស់ទៅលើសេចក្តីសម្រេចផ្នែករដ្ឋប្បវេណី នោះសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីត្រូវចាត់ទុកជាអសាបង់[32] មានន័យថាការអនុវត្តសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីត្រូវព្យួរ

[31] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា៣៥៥ កថាខណ្ឌទី១

[32] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា៣៧០ កថាខណ្ឌទី៣

សិនរហូតដល់មានការសម្រេចសេចក្តីថ្មី ដោយមិនប៉ះពាល់ដល់ការអនុវត្តលើសេចក្តីសម្រេចផ្នែកព្រហ្មទណ្ឌនោះទេ។

### ក.រយៈពេលធ្វើបណ្តឹងទាស់

បណ្តឹងទាស់របស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវធ្វើឡើងក្នុងរយៈពេល១៥(ដប់ប្រាំ) ថ្ងៃ គិតពី៖

- ថ្ងៃឱ្យដំណឹងអំពីសាលក្រមកំបាំងមុខ កាលណាសាលក្រមបានប្រគល់ដើមបណ្តឹងរដ្ឋប្បវេណីដោយផ្ទាល់ដៃ ឬ
- ថ្ងៃដែលដើមបណ្តឹងរដ្ឋប្បវេណីបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម កាលណាសាលក្រមនេះ មិនបានប្រគល់ឱ្យដល់ដើមបណ្តឹងរដ្ឋប្បវេណីដោយផ្ទាល់ដៃទេ។ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានចាត់ទុកថាបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រមក្នុងករណីដែលនីតិវិធីនៃការឱ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវតាមច្បាប់។

### ខ.នីតិវិធីអនុវត្តចំពោះបណ្តឹងទាស់

ដើមបណ្តឹងរដ្ឋប្បវេណីត្រូវធ្វើពាក្យប្តឹងទាស់ជាលាយលក្ខណ៍អក្សរ នៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម។[33] នៅពេលពាក្យបណ្តឹងទាស់របស់ដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ទៅតុលាការដែលប្រកាសសាលក្រមហើយ ភាគីត្រូវចូលរួមការជំនុំជម្រះជាថ្មីម្តងទៀតលើអង្គហេតុដែលបើតុលាការពិនិត្យឃើញថាបណ្តឹងទាស់អាចទទួលយកបាន តាមការកោះហៅរបស់ព្រះរាជអាជ្ញា។ ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីទទួលបានការកោះហៅដោយត្រឹមត្រូវ តែមិនចូលបង្ហាញខ្លួននៅពេលសវនាការទេនោះ តុលាការនឹងប្រកាសថាបណ្តឹងទាស់ទុកជាឯកសារឥតបានការ ប៉ុន្តែដើមបណ្តឹងរដ្ឋប្បវេណីនៅមានភាពលទ្ធភាពក្នុងការប្តឹងឧទ្ធរណ៍លើសាលក្រមកំបាំងមុខនោះម្តងទៀត។

## ២.២ បណ្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចផ្នែករដ្ឋប្បវេណី

បណ្តឹងឧទ្ធរណ៍ គឺជាឧបាស្រ័យមួយប្រភេទដែលនាំឱ្យសំណុំរឿងត្រូវផ្ទេរទៅសាលាឧទ្ធរណ៍ដែលមានសមត្ថកិច្ចលើសាលាជម្រះក្តីជាន់ទាបដែលចេញសាលក្រម នៅក្នុងព្រំដែនដែលបានកំណត់ដោយលិខិតប្តឹងឧទ្ធរណ៍ និងតាមឋានៈរបស់អ្នកប្តឹងឧទ្ធរណ៍។ សាលាឧទ្ធរណ៍សម្រេចសេចក្តី ដោយពិនិត្យទៅលើអង្គហេតុ និងអង្គច្បាប់ដែលសាលាជម្រះថ្នាក់ក្រោមបានស្រាវជ្រាវរកឃើញ និងបានអនុវត្ត។[34] គួរបញ្ជាក់ផងដែលថា ដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើការប្តឹងឧទ្ធរណ៍បាន ដោយបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើបានតែ

[33] ច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧ មាត្រា៣៦៨ មាត្រា៣៧២ និងមាត្រា៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា៣៧២ថ្មី

[34] សៀវភៅ "នីតិវិធីព្រហ្មទណ្ឌ" រៀបរៀងដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ទំព័រទី៨០

លើផលប្រយោជន៍ផ្នែករដ្ឋប្បវេណីដែលប៉ុណ្ណោះ។ នៅមុខសាលាឧទ្ធរណ៍ ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចធ្វើពាក្យប្តឹងសុំថ្មីដែលមិនបានដាក់ជូនតុលាការពិនិត្យនោះទេ។[35]

**ក.រយៈពេលនៃការធ្វើបណ្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចផ្នែករដ្ឋប្បវេណី**

ការប្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវធ្វើឡើងក្នុងរយៈពេល៖

- រយៈពេល ១(មួយ) ខែ ផ្តើមគិតពីពេលប្រកាសសាលក្រម ក្នុងករណីសាលក្រមនោះជាសាលក្រមចំពោះមុខ
- រយៈពេល ១(មួយ) ខែ ផ្តើមគិតពីពេលទទួលដំណឹងសាលក្រម ទោះបីជាការឱ្យដំណឹងនេះធ្វើតាមវិធីណាក៏ដោយ ក្នុងករណីដែលសាលក្រមនោះជាសាលក្រមចាត់ទុកជាចំពោះមុខ
- រយៈពេល ១(មួយ) ខែ ផ្តើមគិតពីពេលផុតកំណត់ប្តឹងទាស់ ក្នុងករណីដែលសាលក្រមនោះជាសាលក្រមកំបាំងមុខ។[36]

នៅក្នុងរយៈនៃការប្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីទៅលើសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីដែលសម្រេចអំពីសំណងនៃការខូចខាតនោះ ការអនុវត្តសាលក្រមមុនត្រូវបង្អង់សិន។[37]

**ខ.នីតិវិធីអនុវត្តចំពោះបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមផ្នែករដ្ឋប្បវេណី**

នៅពេលដែលមានបណ្តឹងឧទ្ធរណ៍ដែលដាក់ដោយដើមបណ្តឹងរដ្ឋប្បវេណី ក្រឡាបញ្ជីនៃតុលាការជាន់ដំបូងរៀបចំសំណុំរឿងដើម្បីបញ្ជូនទៅសាលាឧទ្ធរណ៍។ បន្ទាប់ពីសំណុំរឿងទៅដល់សាលាឧទ្ធរណ៍ ប្រធានសភាព្រហ្មទណ្ឌពិនិត្យផ្ទៀងផ្ទាត់មើលថា ទម្រង់បែបបទនៃបណ្តឹងឧទ្ធរណ៍បានត្រឹមត្រូវឬទេ និងកំណត់កាលបរិច្ឆេទសវនាការ។ ប្រធានសភាព្រហ្មទណ្ឌធ្វើការជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការ ដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ អគ្គព្រះរាជអាជ្ញាមានតួនាទីកោះហៅដើមបណ្តឹងរដ្ឋប្បវេណីឱ្យចូលរួមសវនាការ។ នៅក្នុងចន្លោះពេលដែលមិនទាន់ដល់កាលបរិច្ឆេទសវនាការ ប្រធានសភាព្រហ្មទណ្ឌត្រូវចាត់ចៅក្រមម្នាក់ធ្វើរបាយការណ៍ ដែលរបាយការណ៍នេះមានកម្មវត្ថុរៀបរាប់អំពីដំណើររឿង ហើយនឹងធ្វើឱ្យដឹងពីសាលក្រមដែលជូនមកសាលាឧទ្ធរណ៍។ របាយការណ៍ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវដាក់នៅក្នុងសំណុំរឿង។

លុះដល់កាលបរិច្ឆេទសវនាការ ការពិភាក្សាដេញដោលលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវធ្វើជាសវនាការសាធារណៈ។ ប៉ុន្តែ ប្រសិនបើតុលាការយល់ឃើញថា ភាពជាសាធារណៈនាំឱ្យមានគ្រោះថ្នាក់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬទំនៀមទម្លាប់ តុលាការអាចបង្គាប់ឱ្យធ្វើការដេញដោលជាសម្ងាត់

[35] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា៤០២

[36] ច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧ មាត្រា៣៦៨ មាត្រា៣៧២ និងមាត្រា៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា៣៨២ថ្មី

[37] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា៣៩៨ កថាខណ្ឌទី១

ទាំងស្រុង ឬមួយផ្នែកបាន តាមសេចក្តីសម្រេចដោយមានសំអាងហេតុ។ តុលាការសម្រេចតាមសាលដីកាមួយដាច់ដោយឡែកពីសាលដីកាលើអង្គសេចក្តី ឬតាមសេចក្តីសម្រេចពិសេសនៃសាលដីកាលើអង្គសេចក្តី។

**គ.ការសម្រេចសេចក្តី**

ការសម្រេចអំពីបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ជាសមត្ថកិច្ចរបស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ដូចនេះសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍មានតួនាទីប្រកាសសាលដីកា។ សាលដីកាទៅលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី អាចជាសាលដីកាដែលសម្រេចបន្ថែមចំនួនទឹកប្រាក់សម្រាប់ជួសជុលការខូចខាតឱ្យដើមបណ្តឹងរដ្ឋប្បវេណី ឬ បន្ថយចំនួនទឹកប្រាក់នោះ។

សាលដីកាប្រកាសដោយសាលាឧទ្ធរណ៍អាចជាសាលាដីកាចំពោះមុខ សាលដីកាចាត់ទុកជាចំពោះមុខ ឬជាសាលដីកាកំបាំងមុខ តាមការវែកញែកដែលអនុវត្តចំពោះសាលក្រមដែលប្រកាសដោយតុលាការជាន់ដំបូង[38] ដូចនេះហើយប្រសិនដើមបណ្តឹងរដ្ឋប្បវេណីនៅតែមិនសុខចិត្តនិងការសម្រេចអំពីសំណងនៃការខូចខាតទៀតនោះ ដើមបណ្តឹងរដ្ឋប្បវេណីនៅមានសិទ្ធិក្នុងប្តឹងទាស់នឹងសាលដីកាកំបាំងមុខ ឬធ្វើការប្តឹងសាទុក្ខទៅតុលាការកំពូលតែម្តង។

**២.៣ បណ្តឹងទាស់ចំពោះសាលដីកាផ្នែករដ្ឋប្បវេណី**

បណ្តឹងទាស់គឺជាបណ្តឹងមួយដែលធ្វើឡើងប្រឆាំងនឹងសេចក្តីសម្រេចផ្នែកព្រហ្មទណ្ឌ ឬផ្នែករដ្ឋប្បវេណី ឬអាចប្រឆាំងទៅលើសាលដីកាទាំងមូល ក្នុងករណីដែលសាលដីកានោះជាសាលដីកាកំបាំងមុខ។ នីតិវិធីប្តឹងទាស់ត្រូវធ្វើឡើងនៅសាលាឧទ្ធរណ៍ដែលចេញសាលដីកាដដែល។ ដើមបណ្តឹងរដ្ឋប្បវេណីក៏អាចធ្វើបណ្តឹងទាស់ទៅលើសាលដីកាកំបាំងមុខបានដែរ តែបណ្តឹងនេះកំណត់ទៅលើតែសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីតែប៉ុណ្ណោះ។ ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីធ្វើការប្តឹងទាស់ទៅលើសេចក្តីសម្រេចផ្នែករដ្ឋប្បវេណី នោះសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីត្រូវចាត់ទុកជាអសាបង់ ហើយការអនុវត្តត្រូវព្យួរ។[39]

បណ្តឹងទាស់ដែលធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីត្រូវធ្វើឡើងក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ គិតពី៖

- ថ្ងៃឱ្យដំណឹងពីសាលដីកាកំបាំងមុខ កាលណាសាលដីកានោះត្រូវបានប្រគល់ឱ្យដើមបណ្តឹងរដ្ឋប្បវេណីដោយផ្ទាល់ដៃ
- ថ្ងៃដែលដើមបណ្តឹងរដ្ឋប្បវេណីបានដឹងយ៉ាងពិតប្រាកដអំពីសាលដីកា កាលណាសាលដីកានោះមិនបានប្រគល់ឱ្យដើមបណ្តឹងរដ្ឋប្បវេណីដោយផ្ទាល់ដៃទេ។

[38] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា៤០៨

[39] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា៤១៤ កថាខណ្ឌទី២

បណ្តឹងទាស់ធ្វើឡើងជាលាយលក្ខណ៍អក្សរនៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ដែលបានប្រកាសសាលដីកា។ ដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវបានតំណាងដោយមេធាវី សហព័ទ្ធ ឬដោយញាតិលោហិតផ្ទាល់។ អ្នកតំណាងត្រូវតែមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរដែលអនុញ្ញាតឱ្យប្តឹងទាស់។[40]

## ២.៤ បណ្តឹងសាទុក្ខទៅតុលាការកំពូល

តុលាការកំពូលជាសាលាជម្រះក្តីចុងក្រោយបំផុតដែលអាចឱ្យដើមបណ្តឹងរដ្ឋប្បវេណីប្តឹងតវ៉ានឹងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍។ ជាគោលការណ៍ តុលាការកំពូលសម្រេចសេចក្តីតែលើអង្គច្បាប់តែប៉ុណ្ណោះ មិនសម្រេចសេចក្តីលើអង្គហេតុទេ មានន័យថា តុលាការកំពូលមិនពិនិត្យ ឬសើរើអង្គហេតុដែលកំណត់ដោយសាលាឧទ្ធរណ៍រួចហើយនោះទេ តុលាការពិនិត្យមើលថា តើសាលាឧទ្ធរណ៍បានអនុវត្តច្បាប់ត្រឹមត្រូវដែរឬទេ ទៅតាមអង្គហេតុដែលរកឃើញនោះ។

### ក.រយៈពេលធ្វើបណ្តឹងសាទុក្ខ

ដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើបណ្តឹងសាទុក្ខចំពោះសាលដីការបស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់បានកំណត់ ដូចតទៅ៖

- ១(មួយ)ខែ កាលណាសាលដីកាដែលប្តឹងសាទុក្ខនេះ ជាសាលដីកាចំពោះមុខ រយៈពេលផ្តើមគិតចាប់ពីការប្រកាសសាលដីកា
- ១(មួយ)ខែ កាលណាសាលដីកាដែលប្តឹងសាទុក្ខ ជាសាលដីកាដែលចាត់ទុកថាចំពោះមុខ រយៈពេលត្រូវគិតពីការឱ្យដំណឹង
- ១(មួយ)ខែ កាលណាសាលដីកាដែលប្តឹងសាទុក្ខ កាលណាសាលដីកាសម្រេចដោយកំបាំងមុខ រយៈពេលត្រូវផ្តើមគិតពីការផុតរយៈពេលប្តឹងទាស់។[41]

### ខ.នីតិវិធីអនុវត្តលើបណ្តឹងសាទុក្ខ

ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវធ្វើពាក្យប្តឹងសាទុក្ខ នៅការិយាល័យក្រឡាបញ្ជីសាលាឧទ្ធរណ៍ដែលបានចេញសេចក្តីសម្រេច។ ក្នុងរយៈពេល១០(ដប់)ថ្ងៃ ក្រោយពីការជូនដំណឹងអំពីការចុះបញ្ជីនៃសំណុំរឿងនៅតុលាការកំពូល ដើមបណ្តឹងរដ្ឋប្បវេណីមានកាតព្វកិច្ចសរសេរសារណាមួយដែលត្រូវរៀបរាប់អំពីមធ្យោបាយខាងផ្លូវច្បាប់ ដើម្បីធ្វើជូនមកសភាព្រហ្មទណ្ឌតុលាការកំពូលនូវសារណានោះ តាមការឱ្យដំណឹងរបស់ក្រឡាបញ្ជី ហើយថិរវេលាសម្រាប់សរសេរសារណានេះ មានរយៈពេល២០ (ម្ភៃ) ថ្ងៃ។[42] កាលណារយៈពេល ២០(ម្ភៃ)ថ្ងៃនេះមិនគ្រប់គ្រាន់ទេ ដើមបណ្តឹងរដ្ឋប្បវេណីអាចសុំទៅដល់ប្រធានសភាព្រហ្មទណ្ឌឱ្យពន្យារពេល ដោយការ

[40] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា៤១៦

[41] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា៤២០

[42] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា៤២៧

ពន្យាពេលនេះមិនអាចលើសពី ១០(ដប់)ថ្ងៃទេ។[43] នៅក្នុងរយៈពេលសម្រាប់ធ្វើបណ្តឹងសាទុក្ខនោះ ការអនុវត្តសាលដីការបស់សាលាឧទ្ធរណ៍ត្រូវបង្អង់សិន (បណ្តឹងសាទុក្ខមានអានុភាពព្យួរ) ការអនុវត្តសេចក្តីសម្រេចដែលត្រូវតវ៉ានោះ ត្រូវតែបង្អង់ក្នុងខណៈដែលតុលាការកំពូលមិនទាន់បានសម្រេច។[44]

បន្ទាប់ពីដំណើរការនីតិវិធីចំពោះបណ្តឹងសាទុក្ខបានបញ្ចប់ សភាព្រហ្មទណ្ឌនៃតុលាការកំពូលត្រូវសម្រេចសេចក្តីក្នុងរយៈពេលយ៉ាងយូរ ៦(ប្រាំមួយ)ខែ គិតពីពេលទទួលសំណុំរឿង លើកលែងតែមានកាលៈទេសៈដែលមិនអាចជំនះបាន។[45]

**គ.ការសម្រេចសេចក្តីលើបណ្តឹងសាទុក្ខ**

សភាព្រហ្មទណ្ឌនៃតុលាការកំពូលអាចសម្រេច៖

- បដិសេធបណ្តឹងសាទុក្ខទាំងស្រុង ឬមួយផ្នែក
- បដិសេធសាលដីការបស់សាលាឧទ្ធរណ៍ដែលគេតវ៉ានេះចោលទាំងស្រុង ឬមួយផ្នែក។ ប្រសិនបើបណ្តឹងសាទុក្ខត្រូវបានបានបដិសេធ នោះសេចក្តីសម្រេចដែលតវ៉ាមានអាជ្ញាអស់ជំនុំ។ អ្នកប្តឹងសាទុក្ខមិនត្រូវបានអនុញ្ញាតឱ្យប្តឹងសាទុក្ខជាថ្មីម្តងទៀត អំពីសាលដីកាដដែលនោះទេ។

កាលណាតុលាការកំពូលបដិសេធសេចក្តីសម្រេចដែលគេតវ៉ា តុលាការកំពូលបញ្ជូនរឿងនិងគូភាគីនៅចំពោះមុខសាលាឧទ្ធរណ៍មួយផ្សេងទៀត ឬ នៅចំពោះមុខសាលាឧទ្ធរណ៍ដដែល ប៉ុន្តែមានសមាសភាពថ្មីផ្សេងពីសមាសភាពមុន។[46]

[43] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា៤២៩

[44] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា៤៣៥

[45] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា៤៣៨

[46] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា៤៣៩

# ជំពូកទី៣
# ការអនុវត្តសេចក្តីសម្រេចអំពីសំណង
# នៃការខូចខាតក្នុងរឿងក្តីព្រហ្មទណ្ឌ

# ជំពូកទី៣

# ការអនុវត្តសេចក្តីសម្រេចអំពីសំណងនៃការខូចខាតក្នុងរឿងក្តីព្រហ្មទណ្ឌ

សេចក្តីសម្រេចអំពីសំណងនៃការខូចខាតក្នុងរឿងក្តីព្រហ្មទណ្ឌអាចជា សេចក្តីសម្រេចដែលចេញពីសាលាជម្រះក្តីព្រហ្មទណ្ឌ ឬសេចក្តីសម្រេចដែលចេញពីសាលាជម្រះក្តីរដ្ឋប្បវេណី អាស្រ័យលើការប្តឹងទាមទារសំណងនៃការខូចខាតរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ទោះបីជាសេចក្តីសម្រេចអំពីសំណងនៃការខូចខាតនោះចេញពីសាលាជម្រះក្តីណាមួយក៏ដោយ ក៏ការអនុវត្តសេចក្តីសម្រេចនោះនៅតែមានគោលបំណងសងជាប្រាក់ដដែល។ ទណ្ឌិត ឬ អ្នកទទួលខុសត្រូវរដ្ឋប្បវេណី មានកាតព្វកិច្ចក្នុងការសងនូវសំណងនៃការខូចខាតដោយស្ម័គ្រចិត្ត ប៉ុន្តែក្នុងករណីដែល ទណ្ឌិត ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណីមិនព្រមអនុវត្តកាតព្វកិច្ចក្នុងការសងនូវសំណងនៃការខូចខាតតាមអំណាចនៃសេចក្តីសម្រេចរបស់តុលាការទេនោះ ដើមបណ្តឹងរដ្ឋប្បវេណីអាចដាក់ពាក្យសុំអនុវត្តសេចក្តីសម្រេចនោះ តាមប្បបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីបាន។

## ផ្នែកទី១៖ ការអនុវត្តសេចក្តីសម្រេចតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណី

ជាទូទៅ នៅពេលដែលទណ្ឌិតមិនព្រមបង់សំណង និងប្រាក់ជំងឺចិត្តជូនទៅដើមបណ្តឹងរដ្ឋប្បវេណីទេ វិធានដែលសមស្របជាងគេគឺការរឹបអូសទាំងចលនទ្រព្យ និងអចលនទ្រព្យរបស់ទណ្ឌិត។ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ មាត្រា៥៣៣ បានចែងពីការរឹបអូសទ្រព្យសម្បត្តិរបស់ទណ្ឌិត មុននឹងមានការបង្ខំដល់រូបកាយ ថា "ដើមបណ្តឹងរដ្ឋប្បវេណីត្រូវជូនភស្តុតាងថា ខ្លួនបានប្រើអស់មធ្យោបាយអនុវត្តដែលមានចែងក្នុងច្បាប់ដូចជាការរឹបអូសចលនវត្ថុ និងអចលនវត្ថុជាដើម"។ ជាគោលការណ៍ ការរឹបអូសនូវទ្រព្យសម្បត្តិនេះ គឺត្រូវធ្វើចំពោះចលនទ្រព្យ ឬអចលនទ្រព្យទាំងអស់របស់ទណ្ឌិត[47]។ ការរឹបអូសគឺធ្វើឡើងតាមរយៈការដាក់ពាក្យសុំឱ្យមានការអនុវត្តន៍ដោយបង្ខំដែលធ្វើជាលាយលក្ខ័ណ៍អក្សរ[48] ហើយនីតិវិធីក៏មានភាពប្លែកគ្នាទៅតាមទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំចំពោះចលនទ្រព្យ ឬអចលនទ្រព្យ។

***ការអនុវត្តដោយបង្ខំ*** គឺជានីតិវិធីតាមផ្លូវតុលាការ ក្នុងការសម្រេចនូវសិទ្ធិទាមទារ ដែលបានកំណត់នៅក្នុងនីតិវិធីឯកជន ដោយប្រើអំណាចរដ្ឋ។

### ១.នីតិវិធីនៃការលក់ដោយបង្ខំលើអចលនវត្ថុ

អចលនវត្ថុ គឺសំដៅទៅលើដីធ្លី និងវត្ថុជាប់នឹងដី ហើយមិនអាចផ្លាស់ប្តូរទីកន្លែងបានដូចជាអគារសំណង់ ដំណាំរុក្ខជាតិ-ល-[49]។ នៅក្នុងការលក់ដោយបង្ខំចំពោះអចលនវត្ថុ គឺជាសមត្ថកិច្ចរបស់តុលាការអនុវត្ត

[47] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ មាត្រា៣៧៩

[48] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ មាត្រា៣៤៥ កថាខណ្ឌទី១

[49] សទ្ទានុក្រម ផ្នែករដ្ឋប្បវេណី ទំព័រទី២៦

នៃទីកន្លែងអចលនវត្ថុតាំងនៅ ពោលគឺបើអចលនវត្ថុនោះតាំងនៅទីកន្លែងណា ត្រូវយកសមត្ថកិច្ចរបស់តុលាការអនុវត្តនៅទីកន្លែងនោះ[50]។

### ក.ពាក្យសុំអនុវត្តរបស់ម្ចាស់បំណុល(ដើមបណ្ដឹងរដ្ឋប្បវេណី)

វិធីដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុត្រូវធ្វើជាលាយលក្ខណ៍អក្សរ[51] ហើយនៅក្នុងពាក្យសុំដែលធ្វើជាលាយលក្ខណ៍អក្សរនោះ ត្រូវកំណត់ឱ្យច្បាស់លាស់ពីអត្តសញ្ញាណនៃអចលនវត្ថុ ដែលនឹងត្រូវក្លាយជាកម្មវត្ថុនៃការលក់ដោយបង្ខំ[52]។ ដើម្បីដាក់ពាក្យសុំនេះ ម្ចាស់បំណុលនៃការអនុវត្តដោយបង្ខំត្រូវបង់ពន្ធ ១០.០០០(មួយម៉ឺន) រៀលជូនទៅតុលាការ[53]។ ម៉្យាងវិញទៀតក្នុងពាក្យសុំអនុវត្ត ត្រូវភ្ជាប់ឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអនុភាពអនុវត្តដោយបង្ខំ។

### ខ.ដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំ

បន្ទាប់ពីមានការដាក់ពាក្យសុំអនុវត្តរបស់ម្ចាស់បំណុលរួចហើយនោះ តុលាការត្រូវធ្វើការពិនិត្យមើលថាតើលក្ខខណ្ឌដើម្បីចាប់ផ្ដើមអនុវត្តដោយបង្ខំត្រូវបានបំពេញមានលក្ខណៈគ្រប់គ្រាន់ និងមានទម្រង់ត្រឹមត្រូវដែរឬទេ? ប្រសិនបើមានលក្ខណៈគ្រប់គ្រាន់ហើយ នោះតុលាការនឹងចេញដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំតែម្ដង[54]។ ក្នុងករណីដែលពាក្យសុំអនុវត្តមិនទាន់មានលក្ខណៈគ្រប់គ្រាន់ ឬត្រឹមត្រូវទេនោះ តុលាការអាចចេញដីកាសម្រេចលើកចោលពាក្យសុំឱ្យអនុវត្តដោយបង្ខំរបស់ម្ចាស់បំណុលបាន[55]។ នៅក្នុងដីកាសម្រេចឱ្យមានការចាប់ផ្ដើមលក់ដោយបង្ខំ តុលាការមានតួនាទីត្រូវចង្អុលបញ្ជាក់អំពីម្ចាស់បំណុលនៃការអនុវត្ត កូនបំណុលនៃការអនុវត្ត និងអចលនវត្ថុដែលនឹងត្រូវរឹបអូស ហើយត្រូវប្រកាសអំពីការរឹបអូសអចលនវត្ថុនោះដើម្បីឱ្យម្ចាស់បំណុលបានអនុវត្ត។

### គ.អានុភាពនៃការរឹបអូស

ជាគោលការណ៍ អានុភាពនៃការរឹបអូស កើតមាននៅពេលដែលដីកាសម្រេចឱ្យមានការចាប់ផ្ដើមលក់ដោយបង្ខំត្រូវបានបញ្ជូនដល់ដៃកូនបំណុលនៃការអនុវត្ត[56]។ រីឯការចុះបញ្ជីរឹបអូសនឹងត្រូវធ្វើឡើងតាមរយៈក្រឡាបញ្ជី ផ្ដុកផ្ដាក់ឱ្យស្ថាប័នមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូសដែលពាក់ព័ន្ធទៅនឹងដីកាសម្រេចចាប់ផ្ដើមនោះជាបន្ទាន់ (សម្រាប់ការផ្ដុកផ្ដាក់របស់ក្រឡាបញ្ជីជាមួយស្ថាប័នមានសមត្ថកិច្ចគឺក្នុងគោលបំណងឱ្យបាន

[50] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ មាត្រា៤១៨

[51] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ មាត្រា៣៤៩

[52] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ មាត្រា៣៤៩ កថាខណ្ឌ២ ចំណុច ឃ

[53] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ មាត្រា៣៧២

[54] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ មាត្រា ៤១៩ កថាខណ្ឌទី១

[55] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ មាត្រា ៤១៩ កថាខណ្ឌទី៣

[56] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ មាត្រា៤២១ កថាខណ្ឌទី១

ដឹងច្បាស់ ថាអចលនវត្ថុដែលនឹងត្រូវធ្វើការរឹបអូបមានការចុះបញ្ជីកម្មសិទ្ធហើយឬនៅ ឬក៏ត្រួតពិនិត្យមើលថាតើអចលនវត្ថុនោះកំពុងតែស្ថិតក្នុងការរឹបអូសផ្សេងទៀតដែរឬទេ។ ក្នុងករណីមួយទៀត ប្រសិនបើដីកាសម្រេចឱ្យមានការលក់ដោយបង្ខំត្រូវបានចេញ ហើយការត្រួតពិនិត្យទៅឃើញថាអចលនវត្ថុនោះមិនទាន់ត្រូវបានចុះបញ្ជីនោះស្ថាប័នដែលពាក់ព័ន្ធត្រូវតែចុះបញ្ជីកម្មសិទ្ធិលើអចលនវត្ថុជាមុនសិន ទើបមានការចុះបញ្ជីរឹបអូសជាក្រោយ)[57]។ ក្នុងករណីនេះ ប្រសិនបើការចុះបញ្ជីនៃការរឹបអូសត្រូវបានធ្វើឡើងមុនពេលដីកាសម្រេចចាប់ផ្ដើមនៃការលក់ដោយបង្ខំនោះមានអនុភាព នឹងកើតឡើងនៅពេលបានចុះបញ្ជី ប៉ុន្តែសម្រាប់នៅក្នុងការអនុវត្តជាក់ស្ដែងគឺតែងតែមានការចុះបញ្ជីជាមុនពីព្រោះ ប្រសិនបើដីកាបានទៅដល់កូនបំណុលមុនពេលបានចុះបញ្ជីនៃការរឹបអូសនោះ ហាក់ដូចជាទុកឱកាសឱ្យកូនបំណុលអាចធ្វើអនុប្បទាននូវអចលនវត្ថុនោះឱ្យតតិយជន ហើយការចុះបញ្ជីអំពីកម្មសិទ្ធិរបស់តតិយជននោះអាចនឹងធ្វើបានមុនមានការចុះបញ្ជីរឹបអូសផងដែរ។ នេះជាកត្តាមួយដែលច្បាប់បានការពារនូវផលប្រយោជន៍ដល់ម្ចាស់បំណុលមិនឱ្យមានការបាត់បង់ ឬក៏ខូចប្រយោជន៍ដោយប្រការណាមួយនោះទេ។ ក្រោយពេលរឹបអូសរួច ម្ចាស់បំណុលគ្រាន់តែមានសិទ្ធិរាំងកូនបំណុលមិនឱ្យមានការចាត់ចែងនូវអចលនទ្រព្យតែប៉ុណ្ណោះ តែគ្មានសិទ្ធិរាំងក្នុងការកាន់កាប់របស់កូនបំណុលនោះទេ។ ម៉្យាងវិញទៀត ក្រោយពេលដែលការរឹបអូសមានអានុភាពចំពោះកូនបំណុលក៏អាចមានសិទ្ធិក្នុងការប្រើប្រាស់ ឬអាស្រ័យផលពីអចលនវត្ថុនោះបានដូចធម្មតា[58]។

## ឃ.ដីកាសម្រេចកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក

បន្ទាប់ពីអានុភាពនៃការឹបអូសបានបង្កើតដោយសារការចុះបញ្ជី ឬដោយសារការបញ្ជូនដីកាសម្រេចចាប់ផ្ដើមការលក់ទៅឱ្យកូនបំណុលនៃការអនុវត្ត តុលាការត្រូវកំណត់អំពីរយៈពេលចុងក្រោយសម្រាប់ការទាមទារឱ្យមានការចែកចំណែក ដោយគិតពិចារណានូវអំឡុងពេលចាំបាច់ដើម្បីធ្វើឯកសារលំអិតអំពីអចលនវត្ថុ[59]។ នៅក្នុងគោលការណ៍សមភាព ក៏មានចែងពីករណីដែលមានម្ចាស់បំណុលច្រើនក្នុងការអនុវត្តដោយបង្ខំផងដែរ ដែលម្ចាស់បំណុលទាំងនោះ មានសិទ្ធិក្នុងការទាមទារសំណងជាប្រាក់ពីកូនបំណុលបានគ្រប់ៗគ្នា។ ប៉ុន្តែដើម្បីជៀសវាងកុំឱ្យមានផលប៉ះពាល់អាក្រក់ដែលកើតចេញពីគោលការណ៍នេះ ដែលចេះតែមានការអនុញ្ញាតចំពោះការសងនូវបំណុលរបស់កូនបំណុល ទើបបង្កើតឱ្យមានការដាក់កម្រិតពេលវេលាដែលនឹងត្រូវធ្វើការទាមទារចែកចំណែក។ បន្ទាប់ពីមានការកំណត់ពេលវេលានៃការចែកចំណែករួចរាល់ តុលាការត្រូវមាន

[57]សេចក្ដីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ មាត្រា ៤២០ កថាខណ្ឌទី១

[58] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ មាត្រា៤២១ កថាខណ្ឌទី៣

[59] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ មាត្រា៤២២ កថាខណ្ឌទី១

ការប្រកាសជាសាធារណៈអំពីការដែលបានចេញដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំ និងការកំណត់ពីរយៈពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកនូវចំណែកទាំងនោះ[60]។

**២.ការចាប់ផ្តើមអនុវត្តដោយបង្ខំចំពោះចលនវត្ថុ**

ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ គឺជាការអនុវត្តដោយបង្ខំដែលត្រូវធ្វើឡើងនៅអាជ្ញាសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលចលនវត្ថុតាំងនៅ ហើយការអនុវត្តត្រូវធ្វើតាមវិធីដែលអាជ្ញាសាលានៃសាលាដំបូង រឹបអូសយកចលនវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត[61] ចំពោះពាក្យសុំឱ្យអនុវត្តចលនវត្ថុដោយបង្ខំត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានការបញ្ជាក់នូវលិខិតចម្លងយថាភូតនៃលិខិតដែលមានអានុភាពអនុវត្តដោយបង្ខំ[62] ចំពោះលិខិតអនុវត្ត គឺសំដៅទៅលើសាលក្រម ឬសាលដីកា បង្គាប់ឱ្យផ្តល់នូវតាវកាលិកដែលចូលជាស្ថាពរ។[63]

**ក.វិធីរឹបអូស**

នីតិវិធីនៃការដាក់ពាក្យសុំឱ្យមានការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ គឺចាប់ផ្តើមដោយមានការរឹបអូសពីអាជ្ញាសាលា ជាអ្នកមានសមត្ថកិច្ចទៅលើកម្មវត្ថុនៃពាក្យសុំរបស់ម្ចាស់បំណុល[64] ។ សម្រាប់ពាក្យសុំឱ្យមានការអនុវត្តដោយបង្ខំរបស់ម្ចាស់បំណុល ត្រូវសរសេរពីទីកន្លែងដែលចលនវត្ថុតាំងនៅដែលនឹងត្រូវសុំឱ្យមានការរឹបអូស[65] រីឯចលនវត្ថុនៅទៅតាំងដែលបានដាក់នៅក្នុងពាក្យសុំនោះនឹងត្រូវក្លាយជាកម្មវត្ថុនៃការរឹបអូសទាំងអស់។ នៅក្នុងនីតិវិធីនៃការរឹបអូសចលនវត្ថុគឺមានការបែងចែកទៅតាមការកាន់កាប់ដូចជា ការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលផ្ទាល់ ចលនវត្ថុដែលកាន់កាប់ដោយម្ចាស់បំណុល និងចលនវត្ថុដែលមានការកាន់កាប់ដោយតតិយជន[66]។

ខាងក្រោមនេះជានីតិវិធីនៃការរឹបអូស ដែលនឹងប្រព្រឹត្តតាមទៅករណីនីមួយៗដូចតទៅៈ

- **ការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុល** គឺជាអាជ្ញាសាលាអាចរឹបអូសចលនវត្ថុនោះបានក្នុងករណីដែលវត្ថុនោះជាកម្មសិទ្ធិផ្ទាល់របស់កូនបំណុល នោះអាជ្ញាសាលានឹងមានសមត្ថកិច្ចចុះរឹបអូសដោយមិនចាំបាច់សិក្សាពីការពាក់ព័ន្ធទៅនឹងកម្មវត្ថុនៃការរឹបអូសនោះទេ។ ប៉ុន្តែប្រសិនបើការរឹបអូសចលនវត្ថុនោះត្រូវបានកាន់កាប់ដោយអ្នកដទៃ នោះអាជ្ញាសាលាមិនមានសិទ្ធិក្នុងការរឹបអូសបានទេ។ ក្នុង

[60] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ មាត្រា៤២២ កថាខណ្ឌទី២
[61] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ មាត្រា ៣៨៤ កថាខណ្ឌទី១
[62] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ មាត្រា ៣៤៩
[63] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ មាត្រា៣៥០
[64] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ មាត្រា ៣៨៤ កថាខណ្ឌទី៣
[65] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ មាត្រា៣៨៤ កថាខណ្ឌទី២
[66] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ មាត្រា៣៨៥ និងមាត្រា៣៨៦

ការរឹបអូសនេះអាជ្ញាសាលា គឺអាចចូលទៅក្នុងទីកន្លែងរស់នៅរបស់កូនបំណុលឬ កន្លែងផ្សេងទៀតបាន ហើយអាចធ្វើការចាត់ចែង ដូចជាអាចបិទ ឬបើកទ្វារទូដែកជាដើម[67]។ ប៉ុន្តែនៅក្នុងការជ្រើសរើសវត្ថុដែលត្រូវរឹបអូស អាជ្ញាសាលាត្រូវតែគិតពិចារណាចំពោះផលប្រយោជន៍របស់កូនបំណុលនៃការអនុវត្ត ក្នុងលក្ខខណ្ឌមិនធ្វើឱ្យមានការចូខដល់ប្រយោជន៍របស់ម្ចាស់បំណុលឡើយ[68]។

❖ **ការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយម្ចាស់បំណុល** គឺម្ចាស់បំណុលជាអ្នកស្ម័គ្រចិត្តក្នុងការប្រគល់នូវចលនវត្ថុរបស់កូនបំណុល ដែលខ្លួនកំពុងកាន់កាប់ឱ្យទៅអាជ្ញាសាលាដើម្បីធ្វើការរឹបអូស[69]។

❖ **ការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយតតិយជន** ក្នុងករណីនេះអាជ្ញាសាលាអាចមានសិទ្ធិធ្វើការរឹបអូសទៅបាន លុះត្រាណាតែតតិយជនដែលកំពុងកាន់កាប់ចលនវត្ថុនោះមានការព្រមព្រៀង និងស្ម័គ្រចិត្តក្នុងការប្រគល់នូវចលនវត្ថុឱ្យទៅអាជ្ញាសាលាដើម្បីធ្វើការរឹបអូស ព្រោះអាជ្ញាសាលាមិនអាចបង្ខំរឹបអូសពីជនណាម្នាក់បានឡើយ លើកលែងតែចលនវត្ថុនោះជាកម្មសិទ្ធរបស់កូនបំណុលប៉ុណ្ណោះទើបអាជ្ញាសាលាមានសិទ្ធិក្នុងការបង្ខំរឹបអូសបាន។ ប្រសិនបើតតិយជនមិនព្រមក្នុងការប្រគល់ចលនវត្ថុដល់អាជ្ញាសាលាក្នុងការរឹបអូសទេ ម្ចាស់បំណុលត្រូវតែអនុវត្តនូវសិទ្ធិទាមទារឱ្យសង ឬសិទ្ធិតាមទាមទារឱ្យប្រគល់ចលនវត្ថុដែលកូនបំណុលមានចំពោះតតិយជនតាមរយៈការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល និងប្រមូល ហើយប្រគល់ចលវត្ថុនោះទៅឱ្យអាជ្ញាសាលា។ ក្រៅពីនេះ នីតិវិធីផ្សេងទៀត មានលក្ខណៈដូចតទៅនឹងករណីនៃការរឹបអូសចលនវត្ថុដែលកូនបំណុលកាន់កាប់ដែរ។

## ខ.ការថែរក្សាគ្រប់គ្រងទ្រព្យសម្បត្តិដែលបានរឹបអូស

ជាគោលការណ៍ វត្ថុដែលបានរឹបអូសត្រូវស្ថិតនៅក្រោមការគ្រប់គ្រងថែរក្សារបស់អាជ្ញាសាលា។ ប៉ុន្តែបើយល់ឃើញថាសមរម្យ អាជ្ញាសាលាអាចឱ្យកូនបំណុលជាអ្នកកាន់កាប់វត្ថុដែលបានរឹបអូសនោះបាន។ ម៉្យាងវិញទៀងការរឹបអូស មានអានុភាពលុះត្រាណាតែចលនវត្ថុដែលបានរឹបអូសនោះត្រូវបានបិទស្លាក ឬដាក់សញ្ញារឹបអូសដោយវិធីណាផ្សេង។[70]

## គ.អានុភាពនៃការរឹបអូស

នៅពេលដែលចលវត្ថុត្រូវបានរឹបអូស គឺកូនបំណុលត្រូវបានហាមឃាត់សិទ្ធិមិនឱ្យមានការចាត់ ចែងនូវទ្រព្យទាំងនោះទេ។ តែអានុភាពនៃការហាមឃាត់មិនឱ្យមានលក្ខណៈជាដាច់ខាតនោះទេ គឺត្រឹមតែកម្រិតចាំបាច់

[67] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ មាត្រា៣៨៥ កថាខណ្ឌទី២

[68] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ មាត្រា៣៨៥ កថាខណ្ឌទី៣

[69] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ មាត្រា៣៨៦

[70] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ មាត្រា៣៨៥ កថាខណ្ឌទី៤

ដើម្បីសម្រេច នូវគោលបំណងនៃការអនុវត្តដោយបង្ខំតែប៉ុណ្ណោះ។ ហើយការរឹបអូសក៏មានអានុភាពលើផលធម្មជាតិ ដែលកកើតចេញពីចលនវត្ថុដែលត្រូវបានរឹបអូសនោះដែរ[71] (ផលពីធម្មជាតិដូចជា កូនសត្វចិញ្ចឹម ឧទាហរណ៍ ប្រសិនបើមានការរឹបអូសមាន់ គឺត្រូវរឹបអូស ទាំងស៊ុតមាន់ផងដែរ)។ តែក្នុងករណីដែលអាជ្ញាសាលា ប្រគល់ឱ្យកូនបំណុលជាអ្នកកាន់កាប់វិញ នោះកូនបំណុលអាចប្រើប្រាស់ទ្រព្យនោះបានប្រសិនបើមានការអនុញ្ញាពីអាជ្ញាសាលា[72]។

ប្រសិនបើការកាន់កាប់ចលនវត្ថុស្ថិតនៅក្រោមការកាន់កាប់របស់តតិយជន នោះសាលាដំបូងដែលអាជ្ញាសាលាតាំងនៅ អាចបង្គាប់ឱ្យតតិយជននោះប្រគល់ចលនវត្ថុទៅអាជ្ញាសាលាបានតាមដីកាសម្រេចលើពាក្យសុំរបស់ម្ចាស់បំណុល[73] ក្នុងករណីនេះ តតិយជនមានសិទ្ធិក្នុងការដាក់ពាក្យប្តឹងអំពីសិទ្ធិអះអាងក្នុងការកាន់កាប់ចលនវត្ថុរបស់ខ្លួនបាន[74]។ ចំពោះការចេញដីកាសម្រេចឱ្យមានការប្រគល់ចលនវត្ថុដែលត្រូវបានរឹបអូស ត្រូវធ្វើក្នុងរយៈពេលមួយសប្តាហ៍គិតចាប់ពីថ្ងៃដែលម្ចាស់បំណុលបានដឹងថា ចលនវត្ថុដែលបានរឹបអូសត្រូវកាន់កាប់ដោយតតិយជន ហើយប្រសិនបើផុតរយៈពេលមួយសប្តាហ៍ ម្ចាស់បំណុលមិនបានអាចដាក់ពាក្យសុំបាននោះទេ[75]។

## ឃ.ការអនុវត្តការលក់ដោយបង្ខំ

ការលក់ដោយបង្ខំ គឺជាប្រភេទនៃការលក់ដែលធ្វើឡើងដោយអាជ្ញាធររដ្ឋ អនុញ្ញាតនូវសិទ្ធិចាត់ចែងដែលខ្លួនទទួលបានតាមរយៈការរឹបអូស។ ការអនុវត្តការលក់ដោយបង្ខំ ត្រូវធ្វើឡើងដោយការប្រកាសឱ្យអ្នកស្នើសុំទិញមកទិញវត្ថុ ដែលកំណត់ការលក់ឡៃឡុងដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់។ លើសពីនេះ តុលាការត្រូវកំណត់កាលបរិច្ឆេទ និងទីកន្លែងលក់ ហើយត្រូវឱ្យអាជ្ញាសាលាអនុវត្តការលក់នោះ ឬអាចឱ្យបុគ្គលផ្សេងនៅការលក់ចលនវត្ថុដែលបានរឹបអូសនោះ តែត្រូវទទួលបានការអនុញ្ញាតពីសាលាដំបូងដែលខ្លួនស្ថិតនៅ។ អ្វីដែលបានបរិយាយខាងលើនេះ គឺជាការរៀបរាប់ដោយត្រួសៗពីរបៀបនៃការរឹបអូសដើម្បីលក់ដោយបង្ខំយកប្រាក់មកសងម្ចាស់បំណុលដែលជា ដើមបណ្តឹងរដ្ឋប្បវេណី។ ប៉ុន្តែប្រសិនបើការរឹបអូសហើយនៅតែសងមិនគ្រប់ ឬមិនអាចទទួលការសងបានពីព្រោះតែមានម្ចាស់បំណុលផ្សេងៗទៀតជាច្រើន ឬក៏គ្មានទ្រព្យនិងការរឹបអូសនោះ ទើបការបង្ខំដល់រូបកាយអាចប្រព្រឹត្តទៅបាន។

[71] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ មាត្រា៣៨៩
[72] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ មាត្រា៣៨៥ កថាខណ្ឌទី៥
[73] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ មាត្រា៣៩០ កថាខណ្ឌទី១
[74] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ មាត្រា៣៦៥
[75] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ មាត្រា៣៩០ កថាខណ្ឌទី២

## ផ្នែកទី២៖ ការបង្ខំដល់រូបកាយ

កាលណាសេចក្ដីសម្រេចបានចូលជាស្ថាពរហើយនោះទណ្ឌិត ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណីមានកាតព្វកិច្ចសងនូវសំណងនៃការខូចខាតឱ្យមកជនរងគ្រោះឬ ដើមបណ្ដឹងរដ្ឋប្បវេណី តាមចំនួនទឹកប្រាក់ដែលបានកំណត់នៅក្នុងសេចក្ដីសម្រេចរបស់តុលាការ។ ជាបញ្ហាចោទ បើសិនជាទណ្ឌិតមិនព្រមសងសំណងនៃការខូចខាតដល់ជនរងគ្រោះតាមសេចក្ដីសម្រេចទេនោះ តើមានវិធានការបែបណាសម្រាប់ដោះស្រាយលើបញ្ហានេះ? នៅក្នុងករណី នេះនៅពេលដែលដំណើរការរឿងក្ដីព្រហ្មទណ្ឌត្រូវបានបញ្ចប់ដោយសេចក្ដីសម្រេចចូលជាស្ថាពរដែលបានសម្រេចអំពីពិរុទ្ធភាព និងចំនួនសំណងនៃការខូចខាតរួចមក បើសិនជាទណ្ឌិតមិនព្រមសងសំណងនៃការខូចខាតដល់ជនរងគ្រោះតាមសេចក្ដីសម្រេចទេនោះ ដើមបណ្ដឹងរដ្ឋប្បវេណីអាចស្នើសុំឱ្យទណ្ឌកម្មរដ្ឋប្បវេណីនេះ ក្លាយជាទណ្ឌកម្មព្រហ្មទណ្ឌបាន ទោះបីជានីតិវិធីក្នុងរឿងក្ដីព្រហ្មទណ្ឌត្រូវបានបញ្ចប់ទៅហើយក្ដី ដោយវិធានការនេះក្រមនីតិវិធីព្រហ្មទណ្ឌបានហៅថា **“ការបង្ខំដល់រូបកាយ”**។

ការបង្ខំដល់រូបកាយគឺជាការបង្ខំឱ្យទណ្ឌិតទទួលរងការឃុំខ្លួន បន្ថែមលើទោសជាប់ពន្ធនាគាររបស់ខ្លួនក្នុងករណីដែលមិនបានបង់៖

- ប្រាក់ពិន័យ
- ប្រាក់ពន្ធនៃនីតិវិធី
- ប្រាក់សំណង និងជម្ងឺចិត្តដែលត្រូវបង់ឱ្យដើមបណ្ដឹងរដ្ឋប្បវេណី។[76]

គួរបញ្ជាក់ផងដែរថា ការបង្ខំដល់រូបកាយនេះ ពាក់ព័ន្ធនឹងសមត្ថកិច្ចសាលាជម្រះក្ដីលើបណ្ដឹងទាមទារសំណងនៃការខូចខាតផងដែរ។ កាលណាបណ្ដឹងទាមទារសំណងនៃការខូចខាតត្រូវបានធ្វើឡើងនៅសាលាជម្រះក្ដីរដ្ឋប្បវេណី ការបង្ខំដល់រូបកាយតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌមិនអាចធ្វើបាននោះទេ គឺត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីវិញ ដូចជាការរឹបអូសចលនវត្ថុ ឬអចលនវត្ថុជាអាទិ៍។ ប៉ុន្តែ កាលណាបណ្ដឹងទាមទារសំណងនៃការខូចខាតធ្វើឡើងនៅសាលាជម្រះក្ដីព្រហ្មទណ្ឌ សេចក្ដីសម្រេចក្នុងរឿងព្រហ្មទណ្ឌមានអានុភាពបង្ខំដល់រូបកាយលើផលប្រយោជន៍ខាងរដ្ឋប្បវេណីបាន។

### ១. នីតិវិធីអនុវត្តលើទណ្ឌិតដោយការបង្ខំដល់រូបកាយ

ការបង្ខំដល់រូបកាយចំពោះប្រាក់សំណង និងជម្ងឺចិត្តត្រូវធ្វើឡើងដោយពាក្យបណ្ដឹងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។ កាលណាដើមបណ្ដឹងរដ្ឋប្បវេណីមិនបានទទួលប្រាក់សំណង និងជម្ងឺចិត្តពីទណ្ឌិត ឬពីអ្នកទទួលខុសត្រូវរដ្ឋប្បវេណីទេ ដើមបណ្ដឹងរដ្ឋប្បវេណីអាចសុំដល់ព្រះរាជអាជ្ញាបាន។ ការអនុវត្តដល់រូបកាយដើម្បីទាមទារសំណង និងជម្ងឺចិត្ត អាចអនុវត្តបានតែទៅលើទណ្ឌិតតែប៉ុណ្ណោះ។ ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវជូនភស្តុតាងថា

[76] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា៥២៣

ខ្លួនបានប្រើអស់មធ្យោបាយអនុវត្តដែលមានចែងក្នុងច្បាប់ដូចជាការរឹបអូសចលនវត្ថុ ឬអចលនវត្ថុជាដើម។ ព្រះរាជអាជ្ញាអាចហៅដើមបណ្តឹងរដ្ឋប្បវេណីឱ្យធ្វើនីតិវិធីថ្មី ដើម្បីសាកល្បងទារប្រាក់សំណង និងជម្ងឺចិត្តនេះ។ ក្នុងករណីដែលមានការប្រជែងគ្នារវាងប្រាក់ពិន័យ ប្រាក់ពន្ធនៃនីតិវិធី និងប្រាក់សំណង និងជម្ងឺចិត្ត នោះប្រាក់សំណង និងជម្ងឺចិត្ត ត្រូវមានអាទិភាពទទួលសងមុនគេ។[77]

## **១.១ ការអនុវត្តការសងដោយស្ម័គ្រចិត្ត**

ដោយគោរពទៅលើគោលការណ៍មនុស្សធម៌ ក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់ឱកាសឱ្យទណ្ឌិតអនុវត្តការបង់នូវសំណង និងជម្ងឺចិត្តដោយស្ម័គ្រចិត្ត តាមរយៈការឱ្យដំណឹងរបស់ព្រះរាជអាជ្ញា នៅពេលដែលមានពាក្យបណ្តឹងសុំឱ្យបង្ខំដល់រូបកាយរបស់ដើមបណ្តឹងរដ្ឋប្បវេណី មុនឈានដល់ការអនុវត្តការបង្ខំដល់រូបកាយ។

ព្រះរាជអាជ្ញាកំណត់រយៈពេលចុងក្រោយឱ្យទណ្ឌិត ដើម្បីបង់ប្រាក់សំណង និងជម្ងឺចិត្ត ហើយឱ្យដំណឹងថា ប្រសិនបើមិនបង់ទេនោះ សាមីខ្លួនអាចត្រូវបានបង្ខំដល់រូបកាយ។ រយៈពេលនេះមិនអាចតិចជា១០ (ដប់)ថ្ងៃ នោះទេ។ ការឱ្យដំណឹងត្រូវធ្វើ៖

- ដោយផ្ទាល់មាត់ ឬ
- តាមផ្លូវរដ្ឋបាល ឬ
- តាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។

ត្រូវតែមានធ្វើកំណត់ហេតុស្តីពីការឱ្យដំណឹងនេះ។ កំណត់ហេតុនេះត្រូវចុះហត្ថលេខាដោយទណ្ឌិត។ ប្រសិនបើទណ្ឌិតមិនចេះចុះហត្ថលេខា ទណ្ឌិតត្រូវផ្តិតម្រាមដៃ។[78]

## **១.២ ការអនុវត្តការបង្ខំដល់រូបកាយ**

ក្រោយផុតរយៈពេលចុងក្រោយដែលព្រះរាជអាជ្ញាបានកំណត់សម្រាប់ឱ្យទណ្ឌិត ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណីចូលមកបង់នូវសំណង និងជម្ងឺចិត្តហើយនោះ ប្រសិនបើទណ្ឌិត ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណីមិនបានបង់ប្រាក់នោះទេ ព្រះរាជអាជ្ញាចេញបញ្ជាឱ្យបង្ខំ និងឃុំខ្លួន។ ព្រះរាជអាជ្ញាអាចបង្អង់សេចក្តីសម្រេចនេះបានដោយមូលហេតុមនុស្សធម៌ជាអាទិ៍ ដូចជាស្ថានភាពរបស់ទណ្ឌិត។

បញ្ជាឱ្យបង្ខំ និងឃុំខ្លួនមានចុះនិទ្ទេសដូចតទៅ:

- អត្តសញ្ញាណនៃទណ្ឌិត
- ប្រភេទ និងការយោងនៃទណ្ឌកម្ម
- ការយោងនៃដីកាឱ្យដំណឹង

[77] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា៥៣៣

[78] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា៥២៥

- ចំនួនទឹកប្រាក់ដែលមិនបានបង់
- ចិរវេលានៃឃុំខ្លួនដល់រូបកាយ

បញ្ញានេះត្រូវចុះហត្ថលេខាដោយព្រះរាជអាជ្ញា និងមានបោះត្រាផង

ព្រះរាជអាជ្ញាសុំឱ្យកម្លាំងសាធារណៈចាប់ និងឃុំខ្លួនទណ្ឌិត។[79]

ព្រះរាជអាជ្ញាអាចអនុវត្តការបង្ខំដល់រូបកាយដោយពេញលក្ខណៈច្បាប់ ដោយមិនចាំបាច់មានការប្រកាសពីតុលាការទេ។[80]

ការបង្ខំដល់រូបកាយលើទណ្ឌិតនេះទៀតសោត មានលក្ខខណ្ឌដូចគ្នា ជាមួយនិងទោសដាក់ពន្ធនាគារដែរ មានន័យថា ទណ្ឌិតនឹងត្រូវចាប់ខ្លួនយកទៅឃុំនៅក្នុងពន្ធនាគារ ដូចករណីអនុវត្តទោសពន្ធនាគារតាមអំណាចនៃសេចក្តីសម្រេចរបស់តុលាការ។[81]

**ក.ចិរវេលានៃការបង្ខំដល់រូបកាយ**

ចិរវេលានៃការបង្ខំដល់រូបកាយត្រូវកំណត់ដូចខាងក្រោមៈ

- ១០(ដប់) ថ្ងៃ កាលណាទឹកប្រាក់ដែលមិនបង់នោះមានចំនួនមិនលើសពី ២៥០.០០០ (ពីរសែនប្រាំម៉ឺន)រៀល។
- ២០(ម្ភៃ) ថ្ងៃ ប្រសិនបើទឹកប្រាក់នោះមានចំនួនពី ២៥០.០០១ (ពីរសែនប្រាំម៉ឺនមួយ)រៀល ដល់ ៥០០.០០០ (ប្រាំសែន) រៀល។
- ១(មួយ) ខែ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ៥០០.០០១ (ប្រាំសែនមួយ)រៀល ដល់ ១.០០០.០០០(មួយលាន) រៀល។
- ២(ពីរ) ខែ ប្រសិនបើទឹកប្រាក់នោះមានចំនួនពី ១.០០០.០០១(មួយលានមួយ)រៀល ដល់ ២.៥០០.០០០(ពីរលានប្រាំសែន)រៀល។
- ៣(បី) ខែ ប្រសិនបើទឹកប្រាក់នោះមានចំនួនពី ២.៥០០.០០០១(ពីរលានប្រាំសែនមួយ)រៀល ដល់ ៥.០០០.០០០(ប្រាំលាន)រៀល។
- ៦(ប្រាំមួយ) ខែ ប្រសិនបើទឹកប្រាក់នោះមានចំនួនពី ៥.០០០.០០១(ប្រាំលានមួយ)រៀល ដល់ ១០.០០០.០០០(ដប់លាន)រៀល។
- ១(មួយ) ឆ្នាំ ប្រសិនបើទឹកប្រាក់នោះមានចំនួនពី ១០.០០០.០០១(ដប់លានមួយ)រៀល ដល់ ២០.៥០០.០០០(ម្ភៃលានប្រាំសែន)រៀល។

---

[79] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា៥២៦

[80] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា៥២៤

[81] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា៥២៩

- ១៨(ដប់ប្រាំបី) ខែ ប្រសិនបើទឹកប្រាក់នោះមានចំនួនពី ២០.៥០០.០០១(ម្ភៃលានប្រាំសែនមួយ) រៀល ដល់ ៥០.០០០.០០០(ហាសិបលាន)រៀល។
- ២(ពីរ)ឆ្នាំ ប្រសិនបើទឹកប្រាក់នេះមានចំនួនលើសពី ៥០.០០០.០០០(ហាសិបលាន)រៀល។
- កាលណាការបង្ខំដល់រូបកាយធានាការប្រមូលឥណទេយ្យច្រើននោះ ចិរវេលានៃការបង្ខំនេះ ត្រូវកំណត់ដោយគិតគូរតាមចំនួនសរុបនៃទណ្ឌកម្ម។

### ខ.ភាពមិនអាចរួចផុតពីបំណុល

ការបង្ខំដល់រូបកាយមិនអាចជាមធ្យោបាយសម្រាប់ការទូទាត់បំណុលនោះទេ ហេតុដូច្នេះហើយ ទោះបីជាទណ្ឌិតបានទទួលការបង្ខំដល់រូបកាយទៅហើយក៏ដោយ ក៏បំណុលនៅតែមានអត្ថិភាពជាដរាប មានន័យថា ទណ្ឌិតនៅតែជំពាក់ទឹកប្រាក់ដែលត្រូវបង់ដើមបណ្តឹងរដ្ឋប្បវេណីដដែល។ ប៉ុន្តែទណ្ឌិតនេះមិនត្រូវទទួលរងការបង្ខំដល់រូបកាយចំពោះបំណុលដដែលនេះសាជាថ្មីទៀតនោះទេ។[82]

### ២. ការរួចផុតពីការបង្ខំដល់រូបកាយ

ទោះបីជាក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ឱ្យមានការបង្ខំដល់រូបកាយទៅលើទណ្ឌិតដែលមិនបានបង់ប្រាក់សំណងនៃការខូចខាត និងជម្ងឺចិត្តទៅលើជនរងគ្រោះក៏ពិតមែន ប៉ុន្តែកាលៈទេសៈខ្លះក៏តម្រូវឱ្យមានការរួចផុតពីការបង្ខំដល់រូបកាយផងដែរ។

### ២.១ ស្ថានភាពបុគ្គលដែលមិនអាចធ្វើការបង្ខំដល់រូបកាយ

ការបង្ខំដល់រូបកាយ មិនអាចធ្វើទៅលើទណ្ឌិតដែលជា៖

- អនីតិជននៅពេលប្រព្រឹត្តបទល្មើស
- ស្ត្រីដែលមានអាយុចាប់ពី៦៥(ហុកសិបប្រាំ)ឆ្នាំ ឡើងទៅ
- និងបុរសដែលមានអាយុចាប់ពី៧០(ចិតសិប)ឆ្នាំ ឡើងទៅ
- ការបង្ខំដល់រូបកាយមិនអាចធ្វើបានព្រមជាមួយគ្នាទៅលើប្តី និងប្រពន្ធបានទេ ទោះបីជាការបង្ខំនេះធ្វើឡើង ដើម្បីប្រមូលធនទណ្ឌផ្សេងគ្នាក៏ដោយ។[83] ការធ្វើបែបបនេះ គឺផ្អែកលើគោលការណ៍មនុស្សធម៌ កត្តាសុខភាពទន់ខ្សោយ សមត្ថភាពយល់ដឹងរបស់ទណ្ឌិតដែលជាអនីតិជន និងការប៉ះពាល់ដល់ជីវភាពរស់នៅ ជាអាទិ៍។

[82] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា៥៣២

[83] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា៥៣១

### ២.២ ការដោះលែងឱ្យមានសេរីភាពវិញ

ប្រសិនបើនៅពេលចាប់ខ្លួន ឃុំខ្លួន ឬក្រោយមកទណ្ឌិតតវ៉ាអំពីសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញា ទណ្ឌិតត្រូវបានគេនាំខ្លួនទៅជូនប្រធានតុលាការ។ ប្រធានតុលាការពិនិត្យមើលនីត្យានុកូលភាពនៃបញ្ជានៃឱ្យបង្ខំ និងឱ្យឃុំខ្លួន។ ក្នុងករណីមានការបំពានច្បាប់ ប្រធានតុលាការលុបចោលបញ្ជាឱ្យបង្ខំ និងឱ្យឃុំខ្លួននេះ។ ប្រធានតុលាការត្រូវសម្រេចតាមរយៈដីកាដែលមានសំអាងហេតុ។ សេចក្តីសម្រេចរបស់ប្រធានសាលាដំបូង អាចត្រូវតវ៉ាទៅប្រធានសាលាឧទ្ធរណ៍បានក្នុងរយៈពេល ២(ពីរ)ថ្ងៃ។ បណ្តឹងតវ៉ានេះអាចធ្វើបានដោយអគ្គព្រះរាជអាជ្ញា ព្រះរាជអាជ្ញាអមសាលាដំបូង ឬទណ្ឌិត។ កាលណាប្រធានតុលាការជាន់ដំបូងលុបចោលបញ្ជាបង្ខំ និងឱ្យឃុំខ្លួន សេចក្តីសម្រេចនេះគ្មានអានុភាពអនុវត្តទេ ក្នុងរយៈពេល ២(ពីរ)ថ្ងៃ។ ប្រសិនបើមានការតវ៉ា សេចក្តីសម្រេចនេះគ្មានអានុភាពអនុវត្ត រហូតដល់មានដីការបស់ប្រធានសាលាឧទ្ធរណ៍។ ប្រធានសាលាឧទ្ធរណ៍សម្រេចតាមដីកាដែលមានសំអាងហេតុ និងមិនអាចតវ៉ាបាន។[84] ក្នុងករណីលុបចោលបញ្ជាឱ្យបង្ខំ និងឱ្យឃុំខ្លួននោះ ទណ្ឌិតត្រូវដោះលែងឱ្យមានសេរីភាពវិញ។[85]

ក្នុងករណីដែលថិរវេលានៃការអនុវត្តការបង្ខំ ឬឃុំខ្លួនទណ្ឌិតបានបញ្ចប់ ទណ្ឌិតត្រូវដោះលែងឱ្យមានសេរីភាពវិញ ហើយមិនត្រូវអនុវត្តការបង្ខំ ឬឃុំខ្លួនចំពោះបំណុលដែលនោះទេ។

[84] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា៥២៧

[85] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧ មាត្រា៥២៨

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

# សេចក្តីសន្និដ្ឋាន

ជារួមមក ដើម្បីទទួលបាននូវសំណងនៃការខូចខាត ដែលកើតឡើងពីបទល្មើសព្រហ្មទណ្ឌ ចាំបាច់ត្រូវតែមានគ្រប់លក្ខខណ្ឌដូចជា ចារីមានកំហុស, ជនរងគ្រោះបង្ហាញពីព្យសនកម្មដែលបណ្តាលមកពីបទល្មើស និងជាពិសេសត្រូវតែបង្ហាញអំពីសិទ្ធិក្នុងការទាមទារសំណងនៃការខូចខាតតាមផ្លូវច្បាប់ផងដែរ សម្រាប់ជាភស្តុតាងជូនតុលាការក្នុងការវិនិច្ឆ័យសេចក្តីអំពីសំណងនៃការខូចខាតនោះ។ ប្រសិនបើលក្ខខណ្ឌនៃការទទួលបានសំណងនៃការខូចខាតមិនបានបំពេញទេនោះ ការទទួលបានសំណងនៃការខូចខាតមិនអាចប្រព្រឹត្តទៅបាននោះទេ។ នាងខ្ញុំកត់សម្គាល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីមិនបានបង្ហាញពីព្យសនកម្មទាំងផ្នែកសម្ភារៈ ព្យសនកម្មរូបកាយ និងព្យសនកម្មផ្លូវចិត្ត ឱ្យបានច្បាស់លាស់ទៅតុលាការនោះទេ ជាហេតុនៃឱ្យចៅក្រមមានភាពលំបាកចំពោះការសម្រេចសេចក្តីអំពីសំណងនៃការខូខាត ធ្វើយ៉ាងណាឱ្យធនល្មមទៅនឹងទំហំនៃព្យសនកម្ម ហើយចំណុចនេះក៏បានបង្ហាញពីភាពកង្វះនៃការយល់ដឹងរបស់ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។

ប្រធានបទស្តីពី ***ការទាមទារសំណងការខូចខាតក្នុងរឿងក្តីព្រហ្មទណ្ឌ*** ក៏បានបង្ហាញពីនីតិវិធីនៃការទាមទារសំណងការខូចខាតផងដែរ ដែលចាប់ផ្តើមឡើងពីការដាក់ពាក្យបណ្តឹងទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណី។ លក្ខណៈពិសេសនៃបណ្តឹងទាមទារសំណងការខូចខាតនេះ គឺសាលាជម្រះក្តីរដ្ឋប្បវេណីក៏មានសមត្ថកិច្ចក្នុងការជម្រះក្តីលើសំណងការខូចខាតបានដែរទោះបីជាការខូចខាតនោះកើតឡើងដោយសារបទល្មើសព្រហ្មទណ្ឌយ៉ាងណាក្តី។ ចំពោះនីតិវិធីដែលអនុវត្តនៅសាលាជម្រះក្តីព្រហ្មទណ្ឌវិញ ឃើញថាដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិក្នុងការទាមទារសំណងនៃការខូចខាត ចាប់តាំងពីដំណាក់កាលដំបូងនៃនីតិវិធីរហូតដល់ ការជំនុំជម្រះលើបទល្មើសព្រហ្មទណ្ឌត្រូវបានបញ្ចប់ តាមរយៈសាលក្រម ឬសាលដីកាស្ថាពរ។ ចំណុចជាសារវន្តនៃប្រធានបទនេះ គឺឆ្លុះបញ្ចាំង ព្រមទាំងបើកបង្ហាញពីការអនុវត្តសិទ្ធិ និងការប្រើប្រាស់ដ៏មានសារៈសំខាន់របស់ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទាមទារនូវសំណងការខូចខាតរបស់ខ្លួនដែលបណ្តាលមកពីបទល្មើសព្រហ្មទណ្ឌ បាននៅចំពោះមុខយុត្តាធិការគ្រប់ជាន់ថ្នាក់ ដែលការអនុវត្តនេះដូចគ្នានឹងសាលាជម្រះក្តី អង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកម្ពុជាផងដែរ។

ក្នុងកាលៈទេសៈមួយចំនួន ការទទួលបានសំណងនៃការខូចខាតតាមរយៈការបង់ដោយស្ម័គ្រចិត្តដោយចារី មិនអាចប្រព្រឹត្តទៅបាននោះទេ ជាហេតុនាំឱ្យដើមបណ្តឹងរដ្ឋប្បវេណីអាចដាក់ពាក្យសុំអនុវត្តសេចក្តីសម្រេច សុំឱ្យរឹបអូសនូវចលនវត្ថុ ឬអចលនវត្ថុរបស់ចារីផ្ទាល់តែម្តង បើក្នុងករណីដែលការរឹបអូសមិនអាចធ្វើទៅបានទៀតនោះ ដើមបណ្តឹងរដ្ឋប្បវេណីអាចប្រើប្រាស់សិទ្ធិក្នុងការទទួលបានសំណងនៃការខូចខាតរបស់ខ្លួន សុំឱ្យអនុវត្តដោយបង្ខំលើរូបកាយ លើទណ្ឌិតបាន ប៉ុន្តែការបង្ខំដល់រូបកាយនេះមិនអាចឱ្យទណ្ឌិតរួចផុតពីការសងប្រាក់នោះទេ។

# អនុសាសន៍

ជាចុងក្រោយ នាងខ្ញុំសូមស្នើនូវអនុសាសន៍ចំនួន ០២(ពីរ)ចំណុច ក្នុងគោលបំណងបំពេញបន្ថែម ដូចតទៅ៖

១.ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីគប្បីបង្ហាញតុលាការនូវភស្តុតាងច្បាស់លាស់ដែលអាចបញ្ជាក់ពីព្យសនកម្មដែរខ្លួនទទួលរង ដើម្បីផ្តល់ជាមធ្យោបាយដល់ចៅក្រមក្នុងការកំណត់នូវទំហំនៃសំណងធនល្មមដែលជនរងគ្រោះអាចទទួលបាន។

២.ចំពោះករណីដែលឈានដល់ការបង្ខំដល់រូបកាយ ហាក់មានភាពលំបាកក្នុងការរងចាំឱ្យទណ្ឌិតសងសំណងមកឱ្យដើមបណ្តឹងរដ្ឋប្បវេណីណាស់ ព្រោះទណ្ឌិតស្ថិតនៅក្នុងពន្ធនាគារមិនមានឱកាសរកប្រាក់មកសងដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។ ក្នុងកាលៈទេសៈនៃបទល្មើសមួយចំនួនដែលមិនតម្រូវឱ្យមានទោសដាក់ពន្ធនាគារ ឬទណ្ឌិតទទួលបានការព្យួរទោស ឬក្នុងករណីដែលទណ្ឌិតត្រូវបានដោះលែងទៅហើយនោះ ដើមបណ្តឹងរដ្ឋប្បវេណីគប្បីទុកលទ្ធភាពឱ្យទណ្ឌិតរកប្រាក់មកសងខ្លួន ព្រោះការធ្វើបែបនេះបានផ្តល់ប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណីផង និងទណ្ឌិតផង ដោយសារតែដើមបណ្តឹងរដ្ឋប្បវេណីនឹងទទួលបានប្រាក់សំណង ហើយទណ្ឌិតមិនចាំបាច់ត្រូវបង្ខំរូបកាយ ហើយអាចមានលទ្ធភាពក្នុងការរកប្រាក់មកសងសំណងការខូចខាតទាំងនោះបាន។ ផ្ទុយមកវិញប្រសិនបើអនុវត្តការបង្ខំដល់រូបកាយ បើទណ្ឌិតត្រូវស្ថិតនៅក្នុងពន្ធនាគារនោះ ទណ្ឌិតនឹងគ្មានលទ្ធភាពអាចរកប្រាក់មកសងម្ចាស់បំណុលវិញនោះទេ ហើយទោះបីជាអនុវត្តការបង្ខំដល់រូវកាយរួចក៏ដោយ ការជំពាក់នៅតែជំពាក់ដដែល ពេលខ្លះអាចនឹងគ្មានលទ្ធភាពក្នុងការសងសំណងនៅថ្ងៃមុខទៀតផង៕

# ឯកសារយោង

## ១.ក្រម

- ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧
- ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦
- ក្រមរដ្ឋប្បវេណី,លេខ នស/រកម១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

## ២.ច្បាប់

- ច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧ មាត្រា៣៦៨ មាត្រា៣៧២ និងមាត្រា៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ
- សេចក្តីពន្យល់នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា៖ សេចក្តីពន្យល់ចំពោះករណីយុត្តិសាស្រ្ត អ.វ.ត.ក និងអន្តរជាតិ បោះពុម្ពផ្សាយលើកទី១ នៅខែមិនា ឆ្នាំ២០១៤
- សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

## ៣.សៀវភៅ

- សៀវភៅ "នីតិវិធីព្រហ្មទណ្ឌ" រៀបរៀងដោយលោកសាស្រ្តាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្រ្តាចារ្យ ចាំង ស៊ីណាត
- សាយ បូរី, នីតិរដ្ឋបាលទូទៅ បោះពុម្ពលើកទី៣ ឆ្នាំ២០០៦

## ៤.វចនានុក្រម និង សទ្ទានុក្រម

- សទ្ទានុក្រម ផ្នែករដ្ឋប្បវេណី

# ឧបសម្ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា
**ជាតិ សាសនា ព្រះមហាក្សត្រ**

ចូល
លេខ: ២៥៩៦ ន.ប
ថ្ងៃទី ២៧ ខែ ១១ ឆ្នាំ ២០១៥
ម៉ោង: ៤" ២៥ នាទី

## ពាក្យបណ្តឹង

ខ្ញុំបាទឈ្មោះ [redacted] ភេទប្រុស អាយុ ៧៥ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅក្រុម៤ ភូមិ៣ សង្កាត់២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។

**សូមគោរពចូលមក**
**ចៅក្រមជំនុំជម្រះនៃសាលាដំបូងខេត្តព្រះសីហនុ** [redacted]

**កម្មវត្ថុ** : សុំប្តឹងឈ្មោះ [redacted] ពីបទ បើកបរម៉ូតូបុកខ្ញុំបណ្តាលឲ្យមានរបួសរហូតដល់ពិការ រហូតដល់សព្វថ្ងៃ ។

**យោង**: សំណុំរឿងព្រហ្មទណ្ឌលេខ ២៣៧ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៣ របស់សាលាដំបូងខេត្តព្រះសីហនុ ។

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូនលោកចៅក្រមថា កាលពីថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៣ ឈ្មោះ [redacted] បានបើកបរម៉ូតូបណ្តាលឲ្យរូបខ្ញុំបាទរងរបួសធ្ងន់ធ្ងរ ដែលពេលកើតហេតុនោះ គឺខ្ញុំបាទបានជិះម៉ូតូម៉ាកសេ១២៥ជាមួយឈ្មោះ [redacted] លុះមកដល់ចំណុចកើតហេតុស្រាប់តែមានម៉ូតូមួយគ្រឿងដែលបើកបរដោយឈ្មោះ [redacted] បានបើកបរម៉ូតូមកប៉ះជាមួយម៉ូតូខ្ញុំបាទ បណ្តាលឲ្យខ្ញុំបាទរងរបួសជាទម្ងន់ ដោយខ្ញុំបាទបានទៅដេកសម្រាកនៅមន្ទីរពេទ្យរុស្ស៊ីប្រហែលជាជាងមួយខែអស់ទឹកប្រាក់ប្រហែលជា ១០០០០$ ហើយសព្វថ្ងៃនេះធ្វើឲ្យខ្ញុំបាទពិការភាពទៀតផង ។

ក្នុងរឿងនេះខ្ញុំបាទសូមសំណូមពរដល់តុលាការឲ្យផ្តន្ទាទោសជនល្មើសទៅតាមច្បាប់ និងថ្លៃថ្នាំព្យាបាល និងជំងឺចិត្តសរុបចំនួន ១៥០០០$ (មួយម៉ឺនប្រាំពាន់ ) ដុល្លាសហរដ្ឋអាមេរិក ព្រមទាំងសុំឲ្យតុលាការសម្រេចប្រគល់ម៉ូតូម៉ាក ហុងដាសេ១២៥ ដែលជាកម្មសិទ្ធិរបស់ខ្ញុំបាទ មកឲ្យខ្ញុំបាទវិញផង ។

អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សូមលោកចៅក្រម មេត្តាជួយរកយុត្តិធម៌ឲ្យខ្ញុំបាទផង។ សូមលោកចៅក្រម មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ដោយក្តីអនុគ្រោះ ។

ព្រះសីហនុ , ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៥

ស្នាមមេដៃ

[redacted]

15/6

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តព្រះសីហនុ**

*សំណុំរឿងព្រហ្មទណ្ឌ*

លេខ : **២៣៧**

ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០១៣

*សាលក្រម*

លេខ : **៥០ "ខ"**

ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១៥

## គោរពនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តព្រះសីហនុ

បានបើកសវនាការជាសាធារណៈ នៅសាលសវនាការ នៃសាលាដំបូងខេត្តព្រះសីហនុ នាថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១៥ ដោយមានសមាសភាពជំនុំជម្រះដូចតទៅ ៖

*ចៅក្រមជំនុំជម្រះ*

លោក **ជា សុខហៀង** ចៅក្រមសាលាដំបូងខេត្តព្រះសីហនុ

*តំណាងអយ្យការ*

លោក **គៀង សុន្ធរោ** ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តព្រះសីហនុ

*ក្រឡាបញ្ជីសវនាការ*

លោក **ហុង សុល** ក្រឡាបញ្ជីសាលាដំបូងខេត្តព្រះសីហនុ

*ដើម្បីជំនុំជម្រះ*

លើសំណុំរឿងព្រហ្មទណ្ឌលេខ **២៣៧** ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ **២០១៣** ដែលមាន ៖

-ជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរ កម្មករ ទីកន្លែងកំណើតភូមិ៣ សង្កាត់១ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ មានទីលំនៅបច្ចុប្បន្នភូមិ៣ សង្កាត់១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ឪពុកឈ្មោះ ង៉ែត ធូ "រ" ម្តាយឈ្មោះ ហ៊ឹម ខន "រ" ។ មានលោក

ជាប់ចោទពីបទ **បើកបរបង្កអោយរបួសដល់អ្នកដទៃ** ប្រព្រឹត្តនៅភូមិ៣ សង្កាត់៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី ១៩ ខែមេសា ឆ្នាំ២០១៣ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៨១ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

ដោយមានលោក ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ។

-ដើមបណ្តឹងរដ្ឋប្បវេណី៖

១.ឈ្មោះ ភេទប្រុស អាយុ ៤៦ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅក្រុម៣៣ ភូមិ៥ សង្កាត់៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។

២.ឈ្មោះ ភេទប្រុស អាយុ ៧៥ឆ្នាំ ជនជាតិខ្មែរ ទីលំនៅក្រុម៤ ភូមិ៣ សង្កាត់២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។

-អ្នកទទួលខុសត្រូវរដ្ឋប្បវេណីឈ្មោះ ភេទប្រុស អាយុ ៥២ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅក្រុម ៤ ភូមិ១ សង្កាត់៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។

- សាក្សីឈ្មោះ ភេទប្រុស កើតឆ្នាំ ១៩៦៧ ជនជាតិខ្មែរ មុខរបរ មន្ត្រីនគរបាលចរាចរណ៍ មានទីលំនៅភូមិ២ សង្កាត់២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ២៩៧០ អ.ក/១៤ ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ របស់លោក ហួត វិចិត្រ ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តព្រះសីហនុ។

-បានឃើញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ ៧៥ ត.ព/១៥ ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៥ របស់លោកស្រី លី សុដាណែត ចៅក្រមស៊ើបសួរសាលាដំបូងខេត្តព្រះសីហនុ។

## អង្គហេតុនៃរឿងមានដូចតទៅ ៖

កាលពីថ្ងៃទី ១៩ ខែមេសា ឆ្នាំ២០១៣ វេលាម៉ោង ១៤ និង ៣០នាទី នៅលើវិថី ១៩មិថុនា មុខមន្ទីរបរិស្ថានខេត្ត ត្រង់កូអរដោនេភូមិសាស្ត្រ X០៣៣៧៤៥០ Y១១៧៦២៦៥ ស្ថិតក្នុងភូមិ៣ សង្កាត់៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ឈ្មោះ ជាអ្នកបើកបរម៉ូតូម៉ាក CITY C១០០ កូរ៉េ ពណ៌ក្រហម គ្មានស្លាកលេខ មានទិសដៅពីជើងទៅត្បូង លុះដល់កន្លែងកើតហេតុក៏បានបុកម៉ូតូមួយគ្រឿងម៉ាក Honda C១២៥ ពណ៌ខ្មៅ ពាក់ស្លាកលេខ ១C-៨៩៤៤ បើកបរដោយឈ្មោះ ភេទប្រុស អាយុ ៤៤ឆ្នាំ មានអ្នករួមដំណើរម្នាក់ឈ្មោះ ភេទប្រុស អាយុ ៧៥ឆ្នាំ ។ ក្នុងករណីគ្រោះថ្នាក់ចរាចរនេះបណ្តាលអោយមនុស្សរងរបួសចំនួន ០៣នាក់ ក្នុងនោះមានរងរបួសធ្ងន់ ០១នាក់ និងស្រាល ០២នាក់ ។

## នាពេលសវនាការ

- ក្រឡាបញ្ជីអានកំណត់ហេតុស្តាប់ចម្លើយឈ្មោះ កាលពីថ្ងៃទី១៦ ខែមេសា ឆ្នាំ២០១៣ នៅសមត្ថកិច្ច (ឯកសារលេខ ១/៦ , ១/៧ , ១/៨) ដែលបានឆ្លើយថា មុនពេលកើតហេតុ ខ្លួនបានបើកបរម៉ូតូដឹកកកទៅដាក់នៅម៉ុំឧត្តនិយម រួចហើយខ្លួនក៏បើកបរម៉ូតូត្រឡប់ទៅផ្ទះវិញនៅភូមិ១ សង្កាត់៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ដោយខ្លួនបានបើកបរក្នុងល្បឿនពី ៤០ ទៅ ៥០ Km/h លុះដល់ចំណុចកើតហេតុ ខ្លួនឃើញម៉ូតូមួយគ្រឿងបើកបរពីមុខម៉ូតូខ្លួន រួចហើយម៉ូតូនោះបានបត់ត្រឡប់ក្រោយ ពេលនៅចំងាយពី៤ទៅ៥ម៉ែត្រ ខ្លួនក៏បានជាន់ហ្វ្រាំងមិនជាប់ក៏បុកម៉ូតូនោះតែម្តង ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ បានឆ្លើយថា ថ្ងៃកើតហេតុ ខ្លួនបានបើកម៉ូតូម៉ាកសង់ស៊េរីឆ្នាំ ២០០៤ ឌុបឈ្មោះ ចេញពីកំពង់ផែមកបង់ពន្ធនៅពន្ធដាខេត្តព្រះសីហនុ លុះមកដល់ចំណុចពន្ធដា ឈប់ម៉ូតូអែបខាងរួចហើយ ស្រាប់តែម៉ូតូម៉ាកសង់កូរ៉េ ពណ៌ក្រហមជិះគ្នាម្នាក់ឯង បុកខ្លួន និងឈ្មោះ ខ្ទាតចេញពីកន្លែងម៉ូតូប្រហែល ៣ម៉ែត្រ ។ ម៉ូតូនោះដឹកទឹកកកបើកបរលឿន ពេលកើតហេតុខ្លួនត្រូវរបួសជើងខាងស្តាំខ្លាំង ស៊ើយសាច់ឡើងលើ តែត្រូវមួយកន្លែងទេ ដោយបានសន្លប់មួយភ្លែតដឹងខ្លួនឡើងវិញ ។ រីឯឈ្មោះ គាត់ត្រូវក្បាលធ្ងន់ធ្ងរចេញឈាម ។ ក្រោយពេលកើតហេតុមិនដឹងថាអ្នកណាជាអ្នកហៅឡានពេទ្យមកទេ ទៅដេកនៅពេទ្យ ៨៨៨ ជាមួយឈ្មោះ ដែរ ខ្លួនដេកពេទ្យ ៨៨៨ ចំនួន ២ថ្ងៃ ក្រៅពីនេះមកដេកព្យាបាលនៅផ្ទះបន្ថែមទៀត លុះបាន២ខែកន្លះ ទើបជាសះស្បើយវិញ

ព្យាបាលអស់ប្រាក់ប្រហែល ១២០០$ ក្នុងរឿងនេះខ្លួនសុំទាមទារថ្លៃថ្នាំព្យាបាល និងជំងឺចិត្តសរុបចំនួន ២០០០$ ។ ពេលឈប់នោះ ពេលកើតហេតុខ្លួនបានឈប់ម៉ូតូ រួចហើយ ដោយឈ្មោះ គាត់មិនបានចុះនៅឡើយទេ ពេលឈប់នោះ ខ្លួននៅឈប់ខាងស្តាំដៃ និងមានការបើកភ្លើងសញ្ញាត្រឹមត្រូវ ពេលកើតហេតុជនជាប់ចោទពុំមានរបួសអ្វីនោះទេ ចំណែក ម៉ូតូមិនដឹងខូចខាតអ្វីខ្លះទេ ហើយម៉ូតូពុំទាន់បានយកត្រឡប់ទៅវិញទេ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ បានឆ្លើយថា ថ្ងៃកើតហេតុខ្លួនជិះម៉ូតូមកជាមួយឈ្មោះ ជាអ្នកឌុប ជិះចេញមកពីផែមកកាន់ពន្ធដាខេត្តដើម្បីបង់ពន្ធ ជិះម៉ូតូម៉ាកសង់ ១២៥ ជាកម្មសិទ្ធិរបស់ខ្លួន លុះមកដល់មុខពន្ធដាខេត្តមានម៉ូតូឌុបដឹកទឹកកកម៉ាកសង់កូរ៉េ C ១០០ មកបុកម៉ូតូរបស់ខ្លួនបណ្តាលឲ្យមានរបួសក្បាល និងជើង ដោយជើងបានជាសះស្បើយហើយ តែក្បាលនៅធ្វើទុក្ខម្តងម្កាលដែរ ។ មុនពេលកើតហេតុជើងខ្លួនដើរបានត្រង់ធម្មតាទេ លុះក្រោយពេលកើតហេតុជើងខ្លួនដើរមិនបានត្រង់ដូចមុនទេ។ ក្រោយពេលកើតហេតុទៅព្យាបាលនៅពេទ្យ ៨៨៨ ដោយខ្លួនសន្លប់មិនដឹងខ្លួននោះទេ ដោយសន្លប់មិនដឹងខ្លួនរយៈពេល ១២ថ្ងៃ ទើបដឹងខ្លួនវិញ ខ្លួនព្យាបាលអស់រយៈពេលយូរ អស់ទឹកប្រាក់ប្រហែលជា ១៥០០០$ សូមសំណូមពរទាមទារប្រាក់ចំនួន ១៥០០០$ វិញ។ ខ្លួនមានលិខិតថ្លៃថ្នាំព្យាបាលដែរ តែពុំបានយកមកទេ ពេលបុកនោះ ខ្លួនពុំបានដឹងខ្លួនទេ។

-អ្នកទទួលខុសត្រូវរដ្ឋប្បវេណីឈ្មោះ បានឆ្លើយថា ខ្លួនមិនជាប់សាច់ឈាមជាមួយឈ្មោះ ទេ តែមុនពេលកើតហេតុឈ្មោះ ជាកម្មករដឹកទឹកកកឲ្យខ្លួនបាន ប្រហែលជា ២ខែ ជាអ្នកដឹកទឹកកកចែកចាយឲ្យម៉ូយ ចូលធ្វើការដំបូងឲ្យប្រាក់ខែ ៣០ម៉ឺនរៀល លុះក្រោយមកឲ្យប្រាក់ខែពី ៤០ ទៅ ៥០ម៉ឺនរៀល ។ ថ្ងៃកើតហេតុខ្លួនបានប្រើរតនា ឲ្យដឹកទឹកកកយកទៅឲ្យម៉ូយដូចសព្វដងអីចឹង ដោយដឹកទឹកកកដើមធំៗវែង តែកាត់ខ្លីៗ ។ ម៉ូតូដែលឈ្មោះ ពេជ្រ រតនា ជិះឌុបដឹកទឹកកកម៉ាកសង់ C ១០០កូរ៉េ ពណ៌ក្រហម ជាកម្មសិទ្ធិរបស់ខ្លួន ។ ពេលមកធ្វើការ វាប្រាប់ថាមានអាយុ ២៥ឆ្នាំ ពេលមកធ្វើការពុំបានធ្វើកិច្ចសន្យាការងារអ្វីទេ ។ ពេលកើតហេតុខ្លួនពុំបានឃើញផ្ទាល់ភ្នែកទេ ក្រោយកើតហេតុទើបខ្លួនដឹង។ នៅសមត្ថកិច្ចខាងជនរងគ្រោះធ្លាប់ទាមទារប្រហែលជា ២០០០$ ដែរ តែខ្លួនថាមានលទ្ធភាពត្រឹម ៣០០$ ទៅ ៣៥០$ ប៉ុណ្ណោះ តែចចារគ្នាមិនត្រូវនោះទេ ។ ខ្លួននៅជាប់លុយធនាគារ ខ្លួនសុំជួយចេញសងថ្លៃថ្នាំព្យាបាលទៅ ឈ្មោះ គុយ សែ ចំនួន ៦០ម៉ឺនរៀល ដោយសុំសងក្នុងមួយខែ ២០ម៉ឺនរៀល ចំនួន ០៣ខែ ។ ឈ្មោះ ធ្លាប់ប្រាប់ខ្លួនថាវាមានអាយុ ២៥ឆ្នាំ ហើយតាមខ្លួនមើលនឹងភ្នែកអាយុរបស់ឈ្មោះ រតនា មានអាយុលើសពី ២០ឆ្នាំ ។ ពេលខ្លួនទៅដល់កន្លែងកើតហេតុ ឃើញម៉ូតូ រតនា ជិះខ្វេចខាងមុខ ចំណែកម៉ូតូ គុយ សែ បុកចំម៉ាស៊ីនម៉ូតូ ។

-ក្រឡាបញ្ជីអានរបាយការណ៍លេខ ២០៧ រ.ប.ក ចុះថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០១៣ របស់ការិយាល័យនគរបាលចរាចរណ៍ផ្លូវគោកនៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ ( ១/១៨, ១/១៩) ត្រង់ចំណុចសេចក្តីសន្និដ្ឋានថា៖ ឈ្មោះ ពេជ្រ រតនា បានបំពារបំពាននៅជំពូក ៣ មាត្រា ១៧ និងជំពូក ១០ មាត្រា ៨០ ចំណែកឈ្មោះ (កម្មសិទ្ធិករ) បានបំពារបំពាននៅជំពូក ១០ និងមាត្រា ៧០ និងឈ្មោះ បានបំពារបំពាននៅជំពូក ៣ មាត្រា ២៦ និងជំពូក ១០ មាត្រា ៨០ នៃច្បាប់ចរាចរណ៍ផ្លូវគោក។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី , អ្នកទទួលខុសត្រូវរដ្ឋប្បវេណី និងឯកសារផ្សេងទៀត ឃើញថាជនជាប់ចោទពិតជាបានជិះម៉ូតូដឹកទឹកកក ម៉ាកសង់កូរ៉េ C ១០០ បណ្តាលឲ្យបុកម៉ូតូដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ហើយតាមការពិនិត្យជាក់ស្តែងគាត់មានភាពពិការ ហើយការពិការនេះមិនដឹងថាបណ្តាលមកពីគ្រោះថ្នាក់ចរាចរណ៍នេះ រឺក៏បណ្តាលមកពីជរាភាពរបស់គាត់នោះទេ ចំណែកឈ្មោះ ក៏បណ្តាលឲ្យមានរបួសដែរ ។ ជនជាប់ចោទពុំបានចូលមកធ្វើការដោះស្រាយនោះទេ បទល្មើសមានលក្ខណៈធ្ងន់ធ្ងរ សូមឲ្យតុលាការសម្រេចដាក់ទោសជនជាប់ចោទឲ្យដល់កំរិតអតិបរមា រឺក៏អាចសុំឲ្យមានការចាប់ខ្លួន ។

-លោក ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា ឆ្លងតាមរយៈការស្តាប់ចម្លើយឈ្មោះ និង អំណានចម្លើយកូនក្តីខ្លួន ឃើញថារឿងនេះបង្កឡើងដោយភាគីទាំងសងខាងទេ

តែធ្វើការចោទប្រកាន់តែភាគីម្ខាង ដោយភាគីខាងជនរងគ្រោះក៏ជាជនល្មើសដែរ ។ របាយការណ៍របស់សមត្ថកិច្ចថាខុសទាំងសងទេ ហើយសាក្សីបញ្ជាក់ថា បុកចំម៉ាស៊ីនម៉ូតូ គឺមានភាពស៊ីសង្វាក់គ្នា និងចម្លើយរបស់ឈ្មោះ ដែលបានឆ្លើយលើកមុនថា ខ្លួនបានបត់ម៉ូតូ ។ ទាក់ទងសំណាងសូមឲ្យតុលាការពិនិត្យទៅលើវិកយប័ត្រផង ហើយការផ្តន្ទាទោសក៏សូមតុលាការពិនិត្យផងដែរ ។

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ

- ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងពីរនាក់

- ក្រោយពីបានស្តាប់ចម្លើយរបស់អ្នកទទួលខុសត្រូវរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ឯកសារ ភស្តុតាង

-ក្រោយពីបានពិនិត្យ ពិចារណា និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## **សំអាងហេតុ**

១.តុលាការបានទទួលសំណុំរឿងព្រហ្មទណ្ឌពីចៅក្រមស៊ើបសួរសាលាដំបូងខេត្តព្រះសីហនុ ដែលមានជនជាប់ចោទឈ្មោះ អាយុ ១៧ឆ្នាំ ពីបទ បើកបរបង្កអោយរបួសដល់អ្នកដទៃ តុលាការធ្វើការជំនុំជម្រះលើជនជាប់ចោទ យោងតាមមាត្រា ២៨៩ , ២៩១ និងមាត្រា ៣៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២.ផ្អែកតាមរបាយការណ៍លេខ ២០៧ រ.ប.ក/១៣ ចុះថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០១៣ របស់ការិយាល័យនគរបាលចរាចរណ៍ផ្លូវគោកនៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ ឃើញថា កាលពីថ្ងៃទី ១៩ ខែមេសា ឆ្នាំ២០១៣ វេលាម៉ោង ១៤ និង ៣០នាទី ស្ថិតនៅភូមិ៣ សង្កាត់៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ពិតជាមានករណីគ្រោះថ្នាក់ចរាចរមួយកើតឡើង ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ បានបើកបរម៉ូតូម៉ាក CITY C100 កូរ៉េ ពណ៌ក្រហម គ្មានស្លាកលេខ លុះមកដល់ចំណុចកើតហេតុក៏បានបុកម៉ូតូ ០១គ្រឿងម៉ាក Honda C125 ពណ៌ខ្មៅ ពាក់ស្លាកលេខ ព្រះសីហនុ 1C-8944 ដែលបើកបរដោយឈ្មោះ ភេទប្រុស អាយុ ៤៥ឆ្នាំ បណ្តាលឲ្យមានរបួសមធ្យម និងមានអ្នករួមដំណើរ ០១នាក់ ឈ្មោះ ភេទប្រុស អាយុ ៧៥ឆ្នាំ ជនជាតិខ្មែរ បណ្តាលឲ្យរបួសធ្ងន់ ។

៣. តាមចម្លើយរបស់ជនជាប់ចោទនៅសមត្ថកិច្ច , ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំង២នាក់ , ចម្លើយរបស់សាក្សី , ចម្លើយរបស់អ្នកទទួលខុសត្រូវរដ្ឋប្បវេណី , របាយការណ៍របស់សមត្ថកិច្ច , គំនូសស្នាមនៃគ្រោះថ្នាក់ចរាចរណ៍ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៣ , កំណត់ហេតុត្រួតពិនិត្យកន្លែងកើតហេតុចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៣ របស់ការិយាល័យនគរបាលចរាចរណ៍ផ្លូវគោក និងភស្តុតាងផ្សេងទៀត បង្ហាញឲ្យឃើញថា កាលពីថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៣ ជនជាប់ចោទឈ្មោះ ពិតជាបានបើកបរម៉ូតូល្បឿនលឿនខ្វះការប្រុងប្រយ័ត្ន បានបុកបណ្តាលឲ្យឈ្មោះ មានរបួសរហូតដល់សន្លប់ និងឈ្មោះ មានរបួសធ្ងន់ធ្ងរសន្លប់ ១២ថ្ងៃ បច្ចុប្បន្នឈ្មោះ ក្លាយជាជនពិការ

ប្រាកដមែន ដែលអំពើរបស់ជនជាប់ចោទនេះមានធាតុផ្សំជាបទល្មើស បើកបរបង្កអោយមានរបួសដល់អ្នកដទៃ ដែលមានចែងតាមបញ្ញត្តិមាត្រា ៨១ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

៤.ជនជាប់ចោទ គឺជាជនដែលមានសតិសម្បជញ្ញៈ និងសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌនូវទង្វើរបស់ខ្លួន។

៥.សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការបានចោទប្រកាន់លើឈ្មោះ ភេទប្រុស អាយុ ១៧ឆ្នាំ ពីបទបើកបរបង្កឲ្យមានរបួសដល់អ្នកដទៃ គឺមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។ ចំណែកឯការស្នើសុំឲ្យផ្តន្ទាទោសលើជនជាប់ចោទដាក់ទោសធ្ងន់ធ្ងរ និងចេញដីកាបង្គាប់ឲ្យចាប់ខ្លួន តុលាការនឹងពិនិត្យពិចារណា ។

៦.មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ភេទប្រុស អាយុ ១៧ឆ្នាំ ពីបទ បើកបរបង្កឲ្យមានរបួសដល់អ្នកដទៃ ប្រព្រឹត្តនៅភូមិ៣ សង្កាត់៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី ១៩ ខែមេសា ឆ្នាំ ២០១៣ ដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៨១ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

៧. អំពើដែលជនជាប់ចោទបានប្រព្រឹត្ត គឺបានធ្វើឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ មានរបួសរហូតបណ្តាលឲ្យសន្លប់ និងឈ្មោះ របួសធ្ងន់ធ្ងរសន្លប់ ១២ ថ្ងៃ និងក្លាយជាជនពិការ ជនជាប់ចោទមិនបានផ្តល់សំណងសមស្របដល់ដើមបណ្តឹងរដ្ឋប្បវេណី ធ្វើឲ្យប៉ះពាល់ដល់របៀបរៀបរយសាធារណៈ និងសណ្តាប់ធ្នាប់សង្គម ។ ប៉ុន្តែអំពើដែលជនជាប់ចោទបានប្រព្រឹត្ត គឺជាបទមជ្ឈឹម ទើបតែបានប្រព្រឹត្តបទល្មើសជាលើកដំបូង ពុំដែលមានការផ្តន្ទាទោសពីតុលាការពីមុននោះទេ ជនជាប់ចោទជាអនីតិជន ដូច្នេះទណ្ឌកម្មដែលត្រូវ អនុវត្តលើជនជាប់ចោទ តុលាការនឹងពិចារណា ។

៨. ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ បានប្តឹងទាមទារសំណងថ្លៃថ្នាំព្យាបាល និងជំងឺចិត្តសរុបចំនួន ២០០០$ (ពីរពាន់ដុល្លា) សហរដ្ឋអាមេរិក គឺមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។ រីឯដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ បានប្តឹងទាមទារសំណងថ្លៃថ្នាំព្យាបាល និងជំងឺចិត្តសរុបចំនួន ១៥០០០$ (មួយម៉ឺនប្រាំពាន់ដុល្លា) សហរដ្ឋអាមេរិក តុលាការពិនិត្យពិចារណាតាមភាពសមរម្យ និងជាក់ស្តែង ។ សំណងទាំងនេះជនជាប់ចោទក៏ដូចជាអ្នកទទួលខុសត្រូវរដ្ឋប្បវេណីឈ្មោះ ត្រូវទទួលបន្ទុករួមគ្នាសងទៅដើមបណ្តឹងរដ្ឋប្បវេណី យោងតាមមាត្រា ២១ , ៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ , មាត្រា ៧៤៧ នៃក្រមរដ្ឋប្បវេណី និងមាត្រា ៧០ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

៩. វត្ថុចាប់យកតាមកំណត់ហេតុទទួលវត្ថុតាងចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៣ របស់អយ្យការរួមមាន: ម៉ូតូម៉ាកស៊ីធី ១០០កុង គ្មានផ្លាកលេខ ចំនួន ០១គ្រឿង និងម៉ូតូម៉ាកហុងដាសេ១២៥ ពណ៌ខ្មៅ មានផ្លាកលេខ ១សេ-៨៩៤៤ ចំនួន ០១គ្រឿង ជាទ្រព្យសម្បត្តិផ្ទាល់ខ្លួន គប្បីប្រគល់ឲ្យទៅម្ចាស់ដើមវិញ ។

## ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោសឈ្មោះ **ភេទប្រុស អាយុ ១៧ឆ្នាំ** ដាក់ពន្ធនាគារកំណត់រយៈពេលពេល **១០ (ដប់) ខែ** ពីបទ **បើកបរបង្កអោយរបួសដល់អ្នកដទៃ** ប្រព្រឹត្តនៅភូមិ៣ សង្កាត់៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី ១៩ ខែមេសា ឆ្នាំ២០១៣ តាមបញ្ញត្តិមាត្រា ៨១ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ ។

២- បង្គាប់ឲ្យជនជាប់ចោទឈ្មោះ និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីឈ្មោះ រួមគ្នាសងថ្លៃថ្នាំព្យាបាល និងជំងឺចិត្ត ឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណី៖

ក. ឈ្មោះ **ចំនួន ២០០០$ (ពីរពាន់)** ដុល្លារសហរដ្ឋអាមេរិក ។

ខ. ឈ្មោះ **ចំនួន ១០០០០$ (មួយម៉ឺន)** ដុល្លារសហរដ្ឋអាមេរិក ការទាមទារលើសពីនេះត្រូវច្រានចោល ។

៣- ប្រគល់វត្ថុចាប់យកឲ្យទៅម្ចាស់ដើមវិញតាមកំណត់ហេតុទទួលវត្ថុតាងចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៣ របស់អយ្យការអមសាលាដំបូងខេត្តព្រះសីហនុ រួមមាន៖ ម៉ូតូម៉ាកស៊ុីធី ១០០គូប៍ គ្មានផ្លាកលេខ ចំនួន ០១គ្រឿង និងម៉ូតូម៉ាកហុងដាសេ១២៥ ពណ៌ខ្មៅ មានផ្លាកលេខ ១សេ-៨៩៤៤ ចំនួន ០១គ្រឿង ។

-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១៥ កំបាំងមុខជនជាប់ចោទ ចំពោះមុខអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ចំពោះមុខមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ និងចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី រក្សាសិទ្ធិប្តឹងទាស់ ឬឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជី** **ចៅក្រមជំនុំជម្រះ**

ហុង_សុល ង:-សុខហៀង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ការិយាល័យមេធាវី**

**ពាក្យសុំអនុវត្តសាលដីកាស្ថាពរ**

ខ្ញុំមេធាវី ........... អត្តលេខ ............. ការិយាល័យនៅផ្ទះលេខ ........... មហាវិថីសហព័ន្ធរុស្ស៊ី ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។ ជាមេធាវីតំណាងឱ្យលោក .................... និងលោក .................... តាមរយៈលិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១១ ។

**សូមគោរពជូន**

**ឯកឧត្តមព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញ**

*សូមមេត្តាជ្រាប។*

**កម្មវត្ថុ**: សុំអនុវត្តសាលដីកាព្រហ្មទណ្ឌស្ថាពរលេខ ២១៥ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ របស់តុលាការកំពូល។

**យោង**: -សម្រង់សាលដីកាព្រហ្មទណ្ឌលេខ ២១៥ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ របស់តុលាការកំពូល (ច្បាប់ដើមភ្ជាប់)

-សាលដីកាលេខ ៥៤ "ស" ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១០ របស់សាលាឧទ្ធរណ៍ (ថតចម្លងភ្ជាប់)

-សាលក្រមលេខ ៥១ "ដ" ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ (ថតចម្លងភ្ជាប់)

-លិខិតប្រគល់សិទ្ធិរបស់លោក ................. និងលោក ................ ជូនមេធាវី ................ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១១ (ច្បាប់ដើមភ្ជាប់)។

សេចក្តីដូចបានជម្រាបជូនក្នុងកម្មវត្ថុ និងយោងខាងលើ ការិយាល័យមេធាវី ..................... សូមជម្រាបជូនឯកឧត្តមព្រះរាជអាជ្ញា មេត្តាជ្រាបថា៖ កាលពីថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ តុលាការកំពូលបានសម្រេចសេចក្តីដោយតំកល់សាលដីកាលេខ ៥៤ "ស" ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១០ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទី៤ នៃសាលក្រមលេខ ៥១ "ដ" ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ។ ខ្លឹមសារនៃចំណុចទី៤ របស់សាលក្រមលេខ ៥១ "ដ" ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ គឺបានបង្គាប់ឱ្យជនជាប់ចោទឈ្មោះ ....................... ឈ្មោះ ....................... និងឈ្មោះ ...................... រួមគ្នាសងថ្លៃសេវាផ្លូវច្បាប់ និងផលរបរចំណោញសុទ្ធរយៈពេល ១១ឆ្នាំ (ដប់មួយឆ្នាំ) ជាប្រាក់សរុបចំនួន

២០០.០០០.០០០រៀល (ពីររយលានរៀលគត់) ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ .................... នៅពេលសាលក្រមចូលជាស្ថាពរ។

ដូច្នេះ ដើម្បីការពារផលប្រយោជន៍ដល់កូនក្តីរបស់ខ្ញុំ សូមឯកឧត្តមព្រះរាជអាជ្ញា មេត្តាមានវិធានការណ៍អនុវត្តសាលដីកាស្ថាពររបស់តុលាការកំពូលដូចខាងក្រោម៖

**១.ម្ចាស់បំណុលនៃការអនុវត្ត**

ឈ្មោះ .......... ជាប្រធានក្រុមហ៊ុន .................. មានទីតាំងផ្ទះលេខ ....... ផ្លូវ .......... សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ បានប្រគល់សិទ្ធិជាផ្លូវការពេញលេញជូនលោក ........................ មានទីតាំងនៅផ្ទះលេខ .............. ភូមិចម្រើនផល សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដែលមានរូបខ្ញុំមេធាវី ........... ជាតំណាងក្នុងការអនុវត្ត។

**២.កូនបំណុលនៃការអនុវត្ត**

១. ឈ្មោះ ................ ភេទប្រុស អាយុ ...... ឆ្នាំ ជាតិខ្មែរ អាសយដ្ឋានផ្ទះលេខ ......... សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

២. ឈ្មោះ .................. ភេទប្រុស អាយុ ........ ឆ្នាំ ជាតិខ្មែរ អាសយដ្ឋានផ្ទះលេខ ......... សង្កាត់ផ្សារថ្មីទី ១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

៣.ឈ្មោះ ................. ភេទប្រុស អាយុ ......... ឆ្នាំ ជាតិខ្មែរ អាសយដ្ឋានផ្ទះលេខ .......... សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

**៣.សញ្ញាណនៃលិខិតអនុវត្ត**

សម្រង់សាលដីកាព្រហ្មទណ្ឌស្ថាពរលេខ .......... ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ របស់តុលាការកំពូល។

**៤.សេចក្តីសុំអនុវត្ត**

សុំឱ្យឯកឧត្តមព្រះរាជអាជ្ញា មេត្តាបង្គាប់ឱ្យកូនបំណុលនៃការអនុវត្តទាំងបីខាងលើរួមគ្នា សងថ្លៃសេវាផ្លូវច្បាប់ និងផលរបរចំណេញសុទ្ធរយៈពេល ១១ឆ្នាំ (ដប់មួយឆ្នាំ) ២០០.០០០.០០០រៀល (ពីររយលានរៀលគត់) ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ .............. ដែលមានរូបខ្ញុំមេធាវី .............. ជាតំណាង។

អាស្រ័យហេតុនេះ សូមឯកឧត្តម មេត្តាជួយអនុវត្តសាលដីកាស្ថាពររបស់តុលាការកំពូលដោយក្តីអនុគ្រោះ។

សូមឯកឧត្តម ទទួលនូវការគោរពដោយស្មោះយើងខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ..... ខែ ..... ឆ្នាំ ........

**ការិយាល័យមេធាវី** ..............

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

### ការិយាល័យមេធាវី

**គោរពជូន**
**លោកប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និង សុរិយោដីរាជធានីភ្នំពេញ**

*សូមជ្រាប។*

**កម្មវត្ថុ**: បញ្ជាក់អំពីទ្រព្យសម្បត្តិជាអចលវត្ថុ ឬធ្វើចំណារលើឯកសារភ្ជាប់ស្តីពីទីតាំងអចលនទ្រព្យរបស់លោក ................ ដើម្បីតុលាការចេញដីការឹបអូសលក់ឡាយឡុងដោយបង្ខំស្របតាមនីតិវិធីច្បាប់។

**យោង**: -សម្រង់សាលដីកាព្រហ្មទណ្ឌលេខ ២១៥ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ របស់តុលាការកំពូល (ថតចម្លងភ្ជាប់)

-សាលក្រមលេខ ៥១ (ដ) ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ (ថតចម្លងភ្ជាប់)

-ដីកាកោះចុងក្រោយ ទទួលចុះហត្ថលេខាដោយឈ្មោះ ................ ប៉ុន្តែមិនព្រមចូលខ្លួនទៅទូទាត់សំណង តាមអំណាចនៃសាលដីកា (ថតចម្លងភ្ជាប់)

តបតាមកម្មវត្ថុ និងយោងខាងលើ ការិយាល័យមេធាវី ...................... ដែលជាតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមជម្រាបជូនលោកប្រធានមន្ទីរថា សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានចេញដីកាកោះលោក ................ ជាច្រើនលើកច្រើនសារ ដើម្បីចូលខ្លួនទៅទូទាត់សំណងរដ្ឋប្បវេណីជូនម្ចាស់បំណុល តាមអំណាចនៃសាលដីការព្រហ្មទណ្ឌលេខ ...... ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ របស់តុលាការកំពូល ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ......... ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១០ របស់តុលាការកំពូល។ ចំពោះដីកាកោះទាំងនេះ សាមីខ្លួនតែងបានចុះហត្ថលេខាទទួល ប៉ុន្តែពុំព្រមចូលខ្លួនទៅទូទាត់សំណងជូនជនរងគ្រោះជាម្ចាស់បំណុលឡើយ។ បច្ចុប្បន្នជាដំណាក់កាលចុងក្រោយ ដើម្បីអនុវត្តការលក់ឡាយឡុងអចលនទ្រព្យរបស់លោក ................ ដែលមានទីតាំងនៅផ្ទះលេខ ............. ផ្លូវ...... ភូមិរោងចក្រ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ជាទ្រព្យអំណូស ប៉ុន្តែតុលាការមានតម្រូវការចាំបាច់ ឲ្យមានសេចក្តីបញ្ជាក់ពីមន្ទីរ ដែលជាអង្គភាពជំនាញទទួលចុះបញ្ជីអចលនវត្ថុ ដែលមានទីតាំងខាងលើនេះ ជាទ្រព្យសម្បត្តិរបស់ឈ្មោះ ............... ឬជារបស់អ្នកដទៃ។ តើឈ្មោះ ................ មានទ្រព្យសម្បត្តិផ្សេងទៀតសម្រាប់លក់ឡាយឡុងសងបំណុលដែរឬទេ? មានទីតាំងនៅកន្លែងណាខ្លះ។

អាស្រ័យហេតុនេះ សូមលោកប្រធានមន្ទីរ មេត្តាធ្វើសេចក្តីបញ្ជាក់ជូនអង្គតុលាការ ដើម្បីជាមូលដ្ឋានសម្រាប់អនុវត្តការលក់ឡាយឡុងដោយបង្ខំ ស្របតាមនីតិវិធីច្បាប់ តាមការគួរ។

សូមលោកប្រធាន ទទូលនូវការគោរពរាប់អានដោយស្មោះអំពីយើងខ្ញុំ។

ធ្វើរាជធានីភ្នំពេញ,ថ្ងៃទី ......... ខែ ........ ឆ្នាំ .............

**ការិយាល័យមេធាវី** .............

<u>ចម្លងជូន៖</u>

-សាលាដំបូងរាជធានីភ្នំពេញ

-អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

"ដើម្បីជូនជ្រាប"

-ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ
លេខ .................. វ.ប/១២

ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ
ជម្រាបមក
លោកប្រធានមន្ទីររៀបចំដែនដី
នគរូបនីយកម្មសំណង់និងសុរិយោដីរាជធានីភ្នំពេញ

**កម្មវត្ថុ**: សំណើសុំជួយបញ្ជាក់អំពីអចលនទ្រព្យរបស់ឈ្មោះ ............... ភេទប្រុស អាយុ .....ឆ្នាំ មុខរបរ ................ មានទីលំនៅផ្ទះលេខ .............. សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

**យោង**: -សំណុំរឿងអនុវត្តលេខ ០៨ អ.វ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១១

-លិខិតជូនដំណឹងលេខ ២៧៩ ក.ម.អ/ភវ.២០១២ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១២ របស់លោកមេធាវី .................

-លិខិតសុំអន្តរាគមន៍លេខ ២៨៥ ក.ម.អ/ភវ.២០១២ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១២ របស់លោកមេធាវី ............

តបតាមកម្មវត្ថុ និងយោងខាងលើ យើងសូមជម្រាបមកលោកប្រធានបានជ្រាបថាៈ សាលាដំបូងរាជធានីភ្នំពេញ បានទទួលចាត់ការលើសំណុំរឿងរដ្ឋប្បវេណីលេខ ............. ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១១ ដែលមានដើមបណ្តឹងលោកមេធាវី .................បានប្តឹងសុំអនុវត្តដោយបង្ខំលើអចលនវត្ថុរបស់ឈ្មោះ ............ គឺផ្ទះលេខ .......... សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

មកដល់ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១២ លោកមេធាវី ................. បានធ្វើលិខិតជូនដំណឹងលេខ២៧៩ ក.ម.អ/ភវ.២០១២ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១២ និងមកដល់ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១២ លោកមេធាវី ............. បានធ្វើលិខិតសុំអន្តរាគមន៍លេខ ២៨៥ ក.ម.អ/ភវ.២០១២ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១២ មកសាលាដំបូងរាជធានីភ្នំពេញ ដើម្បីសុំឱ្យសាលាដំបូងរាជធានីភ្នំពេញ ជួយសួរទៅមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ បញ្ជាក់ឱ្យបានច្បាស់ពីអចលនទ្រព្យ របស់ឈ្មោះ ............. ភេទប្រុស អាយុ ....ឆ្នាំ មុខរបរ ............ មានទីលំនៅផ្ទះលេខ ............. សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

ដូច្នេះ ដើម្បីឲ្យមានមូលដ្ឋានក្នុងការអនុវត្តសាលដីកាព្រហ្មទណ្ឌរបស់តុលាការកំពូល លេខ ........... ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឱ្យបានត្រឹមត្រូវ សូមលោកជួយចាត់មន្ត្រីជំនាញ ដើម្បីចុះពិនិត្យ និងជួយបំភ្លឺពីអចលនទ្រព្យរបស់ឈ្មោះ ..................... ខាងលើនេះ ហើយសូមលោកជួយបញ្ជូនរបាយការណ៍លទ្ធផលឆ្លើយតបឱ្យបានច្បាស់លាស់ មកសាលាដំបូងរាជធានីភ្នំពេញវិញឱ្យបានឆាប់តាមការគួរ។

សូមលោកទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

រាជធានីភ្នំពេញ,ថ្ងៃទី ...... ខែ ......... ឆ្នាំ ...........

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់
និង សុរិយោដីរាជធានីភ្នំពេញ

ភ្នំពេញ,ថ្ងៃទី ....... ខែ ......... ឆ្នាំ .............

**ជម្រាបជូន**
**លោកចៅក្រមសាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុ**: ករណីស្នើសុំជួយបញ្ជាក់អំពីអចលនទ្រព្យរបស់ឈ្មោះ .......... ភេទប្រុស អាយុ ......ឆ្នាំ មុខរបរ ....... មានទីលំនៅផ្ទះលេខ ...... សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

**យោង**: -លិខិតលេខ ៤៧៧០ រប/១២ ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ

-លិខិតរបស់ការិយាល័យសុរិយោដី

-លិខិតរបស់កម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី រាជធានីភ្នំពេញ

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោកចៅក្រមជ្រាបថា៖ មន្ទីរបានឱ្យការិយាល័យសុរិយោដី និងកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លីរាជធានីភ្នំពេញ ពិនិត្យស្រាវជ្រាវអំពីអចលនទ្រព្យរបស់លោក .......... ភេទប្រុស អាយុ ........ឆ្នាំ ជា.......... រួចហើយ។ ប៉ុន្តែពុំមានលទ្ធផលវិជ្ជមានទេ ពោលគឺគ្មានឯកសារតម្កល់ទុកនៅការិយាល័យសុរិយោដីទេ និងពុំមានទិន្នន័យក្បាលដីរបស់លោក ................... ដែលបានចុះបញ្ជីនៅក្នុងកម្មវិធីវិស័យរដ្ឋបាលដីធ្លីឡើយ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមលោកចៅក្រមជ្រាប។

សូមលោកចៅក្រមទទួលនូវការរាប់អានពីខ្ញុំ។

**ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់**
**និង សុរិយោដីរាជធានីភ្នំពេញ**

<u>ចម្លងជូន</u>
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-សាលារាជធានីភ្នំពេញ
-ការិយាល័យសុរិយោដី
-កម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី រាជធានីភ្នំពេញ
*"ដើម្បីជូនជ្រាបជាព័ត៌មាន"*
-កាលប្បវត្ត -ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ការិយាល័យមេធាវី**

**ពាក្យសុំអនុវត្តបង្ខំដល់រូបកាយ**
**គោរពជូន**
**ឯកឧត្តមព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញ**

*សូមមេត្តាជ្រាប។*

**កម្មវត្ថុ**: សុំអនុវត្តបង្ខំដល់រូបកាយលើឈ្មោះ ............. លើឈ្មោះ ............. និងលើឈ្មោះ ............ ក្នុងសំណុំរឿងអនុវត្តដោយបង្ខំលេខ ០៨ អ.វ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១២ របស់ សាលាដំបូងរាជធានីភ្នំពេញ។

**យោង**: -សំណុំរឿងអនុវត្តដោយបង្ខំលេខ ០៨ អ.វ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ

-លិខិតលេខ ៣៧៩ ក.ម.អ/ករ.២០១២ ចុះថ្ងៃទី៣០ ខែ សីហា ឆ្នាំ ២០១២ របស់ការិយាល័យមេធាវី ............. (ថតចម្លងភ្ជាប់)

-លិខិតលេខ ៧៨០ ដនសស.រប ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ របស់មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ (ថតចម្លងភ្ជាប់)

-លិខិតលេខ ០០២/១២ ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១២ របស់ចៅសង្កាត់ផ្សារថ្មីទី ១ (ថតចម្លងភ្ជាប់)

-លិខិតលេខ ០៤/២០១២ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១២ របស់ចៅសង្កាត់មនោរម្យ (ថតចម្លងភ្ជាប់)

តបតាមកម្មវត្ថុ និងយោងខាងលើ ការិយាល័យមេធាវី ............. សូមជម្រាបជូនឯកឧត្តមព្រះរាជអាជ្ញា មេត្តាជ្រាបថា៖ ក្រោយពីបានធ្វើការស្រាវជ្រាវតាមរយៈអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ការិយាល័យមេធាវី ............ ក៏ដូចជាចៅក្រមទទួលបន្ទុកកិច្ចការអនុវត្តឃើញថា ឈ្មោះ ..................... ក្តីឈ្មោះ ........... ក្តី និងឈ្មោះ ............. ក្តី ពុំមានទ្រព្យសម្បត្តិសម្រាប់ការអនុវត្តលក់ឡាយឡុងឡើយ ដូចដែលមានបញ្ជាក់ក្នុងលិខិតលេខ ៧៨០ ដនសស.រប ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ របស់មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ និងលិខិតលេខ ០០២/១២ ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១២ របស់ចៅសង្កាត់មនោរម្យភ្ជាប់មកជាមួយស្រាប់។

អាស្រ័យហេតុនេះ សូមឯកឧត្តមព្រះរាជអាជ្ញា មេត្តាមានវិធានការអនុវត្តការបង្ខំដល់រូបកាយលើះ

១. ឈ្មោះ .......... ភេទប្រុស ស្នាក់នៅផ្ទះលេខ ......... ផ្លូវលំ ភូមិរោងចក្រ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

២. ឈ្មោះ ............... ភេទប្រុស ស្នាក់នៅផ្ទះលេខ ............ ផ្លូវលេខ ..... សង្កាត់ផ្សារថ្មីទី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

៣. ឈ្មោះ ............. ភេទប្រុស គ្មានអាសយដ្ឋាន (កំពុងគេចខ្លួន) តាមច្បាប់តាមការគួរ។

សូមឯកឧត្តមព្រះរាជអាជ្ញាមេត្តាទទួលនូវការគោរពដោយស្មោះអំពីយើងខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ...... ខែ ......... ឆ្នាំ ...........

**ការិយាល័យមេធាវី** ............

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូង.................
លេខ ..........................

# ដីកាបង្គាប់ឱ្យអនុវត្តសាលដីកា
# ដោយស្ម័គ្រចិត្ត

**យើង ...................... ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

-បានឃើញក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម លេខនស.រកម.០៧០៦.០២១ ចុះថ្ងៃទី ០៦-០៧-២០០៦ ។

-បានឃើញប្រកាសលេខ ៣០ កយប្រក ០៧ ចុះថ្ងៃទី ១៩-០៧-២០០៧ របស់ក្រសួងយុត្តិធម៌ ស្តីពីមន្ត្រីទទួលបន្ទុកអាជ្ញាសាលា ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ៨១ ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ របស់តុលាការកំពូល ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ......... ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ របស់តុលាការកំពូល ។

-បានឃើញលិខិតលេខ ៧៨០ ដនសស.រប ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ ។

-បានឃើញលិខិតលេខ ០០២/១២ ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១២ របស់ចៅសង្កាត់ផ្សារថ្មី១ ខណ្ឌដូនពេញ ។

-បានឃើញលិខិតលេខ ០៤/២០១២ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១២ របស់ចៅសង្កាត់មនោរម្យ ខណ្ឌ៧មករា ។

-បានឃើញពាក្យសុំអនុវត្តបង្ខំដល់រូបកាយរបស់លោក .................... មេធាវីតំណាងឱ្យលោក ................. និងលោក .................. ចុះថ្ងៃទី ០៦-កញ្ញា-២០១២ ។

-បានឃើញពាក្យសុំបន្តអនុវត្តដោយបង្ខំដល់រូបកាយរបស់លោក .................. មេធាវីតំណាងឱ្យលោក .................... និងលោក .................... ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៣ ។

## <u>យល់ឃើញថា</u>

សាលដីកាព្រហ្មទណ្ឌលេខ ២១៥ ចុះថ្ងៃទី ២៥-វិច្ឆិកា-២០១១ និងសាលដីកាព្រហ្មទណ្ឌលេខ ៨១ ចុះថ្ងៃទី ២០-មីនា-២០១៣ របស់តុលាការកំពូល មានប្រសិទ្ធភាពអនុវត្តដោយបង្ខំ។

## ហេតុដូច្នេះសម្រេច

បង្គាប់ឱ្យឈ្មោះ ................ ភេទប្រុស អាយុ ៣៩ឆ្នាំ មានទីលំនៅសព្វថ្ងៃ ផ្ទះលេខ ........ ផ្លូវលេខ .............. សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ និងឈ្មោះ ................ ភេទប្រុស អាយុ ២១ឆ្នាំ ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃ ផ្ទះលេខ ........... សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ (គេចខ្លួន) រួមគ្នាសងថ្លៃសេវាផ្លូវច្បាប់ និងផលរបរចំណេញ សុទ្ធរយៈពេល ១១ (ដប់មួយ) ឆ្នាំ ជាប្រាក់សរុបចំនួន ២០០.០០០.០០០រៀល (ពីររយលានរៀលគត់) ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ................. ដែលមានលោក .............. ជាមេធាវីតំណាង ក្នុងរយៈពេល ០៧ថ្ងៃ (ប្រាំពីរថ្ងៃ) គិតចាប់ពីថ្ងៃទទួលដីកានេះ។

ករណីមិនអនុវត្តតាមដីកាបង្គាប់នេះទេ យើងនឹងចេញដីកាបង្គាប់ឱ្យចាប់ខ្លួន ដើម្បីដាក់គុកបង្ខំដល់រូបកាយ តាមមាត្រា ៥២៦, ៥៣០ និងមាត្រា ៥៣៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ ។

**ជ.ព្រះរាជអាជ្ញា**

**មន្ត្រីទទួលបន្ទុកអនុវត្ត**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូង.................
លេខ .........................

# ដីកាបង្គាប់ឱ្យចាប់ខ្លួន

**យើង ................. ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

-បានឃើញមាត្រា ៤៩៦, មាត្រា ៥២៣, មាត្រា ៥៣០, មាត្រា ៥៣៣ និងមាត្រា ១៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

-បានឃើញសំណុំរឿងអនុវត្តលេខ ......... ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ........... ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ .......... ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១០ របស់សាលាឧទ្ធរណ៍។

-បានឃើញសម្រេចសាលដីកាព្រហ្មទណ្ឌលេខ ........ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ របស់តុលាការកំពូល។

-បានឃើញពាក្យសុំអនុវត្តសាលដីកាស្ថាពររបស់លោក ........................ មេធាវីតំណាងឱ្យលោក ..................... និងលោក ..................... ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១ ។

-បានឃើញពាក្យសុំអនុវត្តដោយបង្ខំរបស់លោក ...................... មេធាវីតំណាងឱ្យលោក ......... និងលោក ..................... ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១២ ។

-បានឃើញពាក្យសុំអនុវត្តបង្ខំដល់រូបកាយរបស់លោក ................ មេធាវីតំណាងឱ្យលោក ........................ និងលោក .................... ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១២ ។

-បានឃើញដីកាបង្គាប់ឲ្យអនុវត្តសាលដីកាដោយស្ម័គ្រចិត្តលេខ ...................... របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដោយមានចុះហត្ថលេខាទទួលរបស់ឈ្មោះ .............. ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១២ ។

## ក្រោយពីបានពិនិត្យសព្វគ្រប់ឃើញថា:

-តាមសាលដីកាព្រហ្មទណ្ឌលេខ ............. ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ បានសម្រេចបង្គាប់ឱ្យឈ្មោះ ........... ភេទប្រុស អាយុ ............ឆ្នាំ ជាតិខ្មែរ កើតនៅភូមិក្បាលកោះ ឃុំកោះដាច់ ស្រុកមុខកំពូល ខេត្តកណ្តាល ទីលំនៅសព្វថ្ងៃផ្ទះលេខ ....... សង្កាត់ភ្នំពេញថ្មី

ខណ្ឌសែនសុខ រាជធានីភ្នំពេញ មុខរបរ ............. ឪពុកឈ្មោះ .............. "រ" ម្ដាយឈ្មោះ ............. "ស" ប្រពន្ធឈ្មោះ ................. មានកូន ០៦នាក់ ជានីតិជន, ឈ្មោះ ..................... ភេទប្រុស អាយុ ........ឆ្នាំ និងឈ្មោះ .................... ភេទប្រុស អាយុ .......ឆ្នាំ រួមគ្នាសងថ្លៃសេវាផ្លូវច្បាប់ និងផលរបរចំណេញសុទ្ធរយៈពេល ១១ឆ្នាំ ជាប្រាក់សរុបចំនួន ២០០.០០០.០០០រៀល (ពីររយលានរៀល) ឱ្យទៅដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ................... ។

-តាមការបញ្ជាក់របស់អាជ្ញាធរមូលដ្ឋាន និងមន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដីថា៖ ឈ្មោះ ................ ពុំមានទ្រព្យសម្បត្តិសម្រាប់លក់ឡាយឡុងជានាសំណងទេ។

-ឈ្មោះ ................. បានទទួលដីកាបង្គាប់ឱ្យអនុវត្តដោយស្ម័គ្រចិត្តរួចហើយ តែឈ្មោះ .................. មានចេតនាគេចវេះពុំព្រមសងសំណងទៅដើមបណ្ដឹងរដ្ឋប្បវេណី។

**<u>ហេតុដូច្នេះសម្រេច</u>**

-បង្គាប់មកមន្ត្រីនគរបាលយុត្តិធម៌ចាប់ខ្លួនឈ្មោះ .................. ភេទប្រុស អាយុ .......ឆ្នាំ ជាតិខ្មែរ កើតនៅភូមិក្បាលកោះ ឃុំកោះដាច់ ស្រុកមុខកំពូល ខេត្តកណ្ដាល ទីលំនៅសព្វថ្ងៃផ្ទះលេខ ........... សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ មុខរបរ ................... ឪពុកឈ្មោះ ..........."រ" ម្ដាយឈ្មោះ ................... "ស" ប្រពន្ធឈ្មោះ ..................... មានកូន ០៦នាក់ ជានីតិជន យកមកបង្ខំដល់រូបកាយទារប្រាក់សំណង ទៅដើមបណ្ដឹងរដ្ឋប្បវេណី។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ........ ខែ ......... ឆ្នាំ ............

**ជ.ព្រះរាជអាជ្ញា**